

# តិកមាតិកាវណ្ណនា

រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ មហាវណ្ណរ័ត្នខ្មែរ

ព.ស.២៥៦៤

# តិកមាតិកាវណ្ណនា

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ

មហាវណ្ណរ័ត្នខ្មែរ (Maha Vannrat Khmer)

**ព.ស.២៥៦៥**

សៀវភៅឈ្មោះ : **និគមាតិកាវណ្ណនា**

រៀបរៀងដោយ : **មហាវណ្ណរ័ត្នខ្មែរ (Maha Vannrat Khmer)**

ពិនិត្យដោយ : ភិក្ខុរតននាថ **មាស សាពួន**

ភិក្ខុអាយុទីឃោ **ឈួន សាវឿន**

ភិក្ខុតុលធម្មោ **ស៊ិន ម៉ុនឡុង**

ភិក្ខុសទ្ធាធនោ **ឈាត ឈឿន**

ភិក្ខុបញ្ញាបទីបោ **ស្វ ឆត**

រចនាសៀវភៅ និងក្រប : ភិក្ខុវិមលោ **សាន ថាវីន**

ទីកន្លែងធ្វើ : វត្តឃោសិតារាម ហៅតាទក ភូមិគោកដូន ឃុំពួក ស្រុកពួក ខេត្តសៀមរាប

កាលបរិច្ឆេទ : **ព.ស.២៥៦៥ គ.ស.២០២១**

# អារម្ភកថា

ព្រះពុទ្ធសាសនានៃយើងទាំងឡាយ ជាសាសនាសម្ដែងដល់ធម្មជាតិ ឬសភាវៈធម៌តាមសេចក្ដីពិតដែលប្រាកដក្នុងសាកលលោក បានដល់ចិត្ត ចេតសិក រូប និងព្រះនិព្វាន ហើយធម៌ទាំងអស់នេះនឹងប្រាកដបានត្រូវតែអាស្រ័យសព្វញ្ញុតញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធតែម្យ៉ាងប៉ុណ្ណោះ ក៏ព្រះពុទ្ធសាសនា គឺ ព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់សត្វទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបថា ព្រះពុទ្ធសាសនានេះ បែកជា ៣ ប្រភេទ គឺ បរិយត្តិ បដិបត្តិ និងបដិវេធៈ ។

១.**បរិយត្តិ** បានដល់ ធម៌ និង វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងដល់បុគ្គលទាំងឡាយក្នុងស្ថាននានាអស់រយៈកាល ៤៥ ព្រះវស្សា ក្រោយអំពីព្រះដ៏មានព្រះភាគបានរលត់ខន្ធចូលកាន់ព្រះនិព្វាន ហើយព្រះអដ្ឋកថាចារ្យទាំងឡាយបានរួបរួម ឬ សង្គាយនាទុកជាគម្ពីរដែលមានឈ្មោះថា **ព្រះត្រៃបិដក** សម្រាប់ពួកយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវតែសិក្សាឱ្យយល់តាមសមគួរ ព្រោះព្រះបរិយត្តិជាឫសគល់នៃព្រះពុទ្ធសាសនា ។

២.**បដិបត្តិ** គឺ ការបំពេញសីល សមាធិ និងបញ្ញា ធ្វើឱ្យកើតឡើងដោយការយកខន្ធ ធាតុ អាយតនៈ ជាដើមដែលជាចំណែកនៃព្រះបរិយត្តិនោះ មកធ្វើកិច្ចក្នុងអរិយសច្ចៈទាំង ៤ មានទុក្ខសច្ចៈជាដើម ព្រោះថាបុគ្គលនឹងរួចផុតបាកទុក្ខទាំងពួងបាន ដោយមិនមានការកំណត់ដឹងទុក្ខសច្ចៈជាដើមមិនមានឡើយ ។

៣.**បដិវេធៈ** គឺ ការបាក់ធ្លុះ ឬ ការត្រាស់ដឹងធម៌ ៩ ប្រការ គឺ មគ្គ ៤ ផល ៤ និងព្រះនិព្វាន ១ ដោយអាស្រ័យការកំណត់ដឹងទុក្ខសច្ចៈជាដើមនោះឯង ។ ក៏ធម៌ទាំង ៩ ប្រការនេះ បុគ្គលណាបាក់ធ្លុះបានហើយ នឹងធ្វើឱ្យបុគ្គលនោះ រួចផុតបាកទុក្ខតាមសមគួរដោយអំណាចនៃមគ្គនោះៗ ។

ក្នុងការរៀបរៀង**តិកមាតិកាវណ្ណនា**នេះ ខ្ញុំព្រះករុណាអាស្រ័យហេតុខាងដើម គឺ យល់ឃើញថា មានតែការសិក្សាព្រះបរិយត្តិប៉ុណ្ណោះ ជាហេតុនៃការតាំងនៅនៃព្រះសាសនា ទើបបានរួបរួមសៀវភៅនេះឡើងមកជាឧបករណ៍នៃការសិក្សាដោយអាស្រ័យគម្ពីរព្រះត្រៃបិដក អដ្ឋកថា និងដីកាជាដើម ។

ម្យ៉ាងវិញទៀត ការរួបរួម**តិកមាតិកាវណ្ណនា**នេះ អាចនឹងមានសេចក្តីភ្លាំងភ្លាត់ ឬ ការខ្វះខាតយ៉ាងណាមួយ សូមខន្តីអភ័យទោសអំពីសម្នាក់បណ្ឌិតទាំងឡាយ និងសូមជួយកែតម្រូវដើម្បីជាប្រយោជន៍រួមតទៅ ។

ទីបញ្ចប់នេះ ខ្ញុំព្រះករុណា សូមប្រមូលបុណ្យទាំងអស់នេះ ឧទ្ទិសបំពោះក្រុមជំនុំព្រះត្រៃបិដក ហើយសូមប្រគេនបុណ្យ និងជូនបុណ្យដល់អ្នកមានគុណទាំងឡាយ ជាពិសេសគឺព្រះអាចារ្យមហាទួន ឧត្តមប្បញ្ញោ ជាគ្រូបង្រៀនគម្ពីរ **បទរូបសិទ្ធិ, បទរូបសិទ្ធិដីកា, វុត្តោទ័យ, វុត្តោទយដីកា, សុពោធាលង្ការ, សុពោធាលង្ការដីកា**ជាដើម ។ ព្រះអាចារ្យមហាភូរិវឌ្ឍកោ ជាគ្រូបង្រៀនគម្ពីរ**ព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ** ។ លោកគ្រូសមពរ បញ្ញាធរ ជាគ្រូបង្រៀនគម្ពីរ**ព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ, មាតិកា, វិភង្គ, មហាបដ្ឋាន, វិសុទ្ធិមគ្គ** ជាដើម

សូមពុទ្ធបរិស័ទទាំងអស់  បានចំណែកនៃបុណ្យនេះ  នឹងជាបច្ច័យនៃការអស់ទៅនៃអាសវក្កិលេសកុំបីអាក់ខានឡើយ ។

*សូមអនុមោទនា. !!!*

**វត្តឃោសិតារាម ហៅតាងក**

ថ្ងៃសុក្រ ១៤ កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២១

**មហាចណ្ណារ័ត្នខ្មែរ**

# មាតិកានុក្រម

ឈ្មោះមាតិកា ទំព័រ

សម្ដែងហេតុនៃការប្រាកដឡើងព្រះអភិធម្ម ............ ១
អធិប្បាយមាតិកា និងប្រភេទនៃមាតិកា ............ ២
សម្ដែងកណ្ឌទាំង ៤ ............ ៤
បិដ្ឋប្បាទកណ្ឌ ............ ៥
មាតិកា មាន ២ យ៉ាង ............ ៥

តិកមាតិកា

១. កុសលត្តិកៈ ............ ៦
អធិប្បាយកុសលត្តិកៈ ............ ៩
សម្ដែងអង្គធម៌ និងការលះរបស់កុសលមាន ៣ ប្រភេទ ............ ១០
ហេតុផលនៃការសម្ដែងកុសលត្តិកៈ មុនតិកៈដទៃៗ ............ ១១
អធិប្បាយមគ្គសច្ចៈ និងសច្ចវិមុត្តក្នុងកុសលត្តិកៈ ............ ១៤
២. វេទនាត្តិកៈ ............ ១៦
៣. វិបាកត្តិកៈ ............ ២០
៤. ឧបាទិន្នត្តិកៈ ............ ២៣
៥. សង្កិលិដ្ឋត្តិកៈ ............ ២៨
៦. សវិតក្កត្តិកៈ ............ ៣១
៧. បីតិត្តិកៈ ............ ៣៦
៨. ទស្សនត្តិកៈ ............ ៣៨
សម្ដែងការលះអកុសលធម៌ដោយមគ្គទាំង ៤ ............ ៤០

ការលះកិលេសដោយលំដាប់នៃមគ្គ.................................................................... ៤២
ការលះសំយោជនៈដោយលំដាប់នៃកិលេស .................................................... ៤៣
ការលះសំយោជនៈដោយលំដាប់នៃមគ្គ .......................................................... ៤៣
៩. ទស្សនហេតុត្តិកៈ.......................................................................................៥៤
១០. អាចយគាមិត្តិកៈ .....................................................................................៥៧
១១. សេក្ខត្តិកៈ ...............................................................................................៥៩
១២. បរិត្តត្តិកៈ................................................................................................៦១
១៣. បរិត្តារម្មណត្តិកៈ .....................................................................................៦៤
១៤. ហីនត្តិកៈ ..................................................................................................៦៦
១៥. មិច្ឆត្តិកៈ....................................................................................................៦៨
១៦. មគ្គារម្មណត្តិកៈ.......................................................................................... ៧៨
១៧. ឧប្បន្នត្តិកៈ ..............................................................................................៩២
១៨. អតីតត្តិកៈ.................................................................................................. ៩៤
១៩. អតីតារម្មណត្តិកៈ.......................................................................................៩៥
២០. អជ្ឈត្តត្តិកៈ................................................................................................៩៧
២១. អជ្ឈត្តារម្មណត្តិកៈ..................................................................................... ៩៩
២២. សនិទស្សនត្តិកៈ.......................................................................................១០១
បែកតិកៈ ២២ ដោយអាទិលទ្ធនាមត្តិកៈនិងសព្វលទ្ធនាមត្តិកៈ ...........................១០២
បែកតិកៈ ២២ ដោយសប្បទេសត្តិកៈ និងនិប្បទេសត្តិកៈ.....................................១០២

**<u>បករណ៍ជំនួយក្នុងការរៀបរៀងសៀវភៅនេះ</u>**

១. ព្រះត្រៃបិដក និងសេចក្តីប្រែជាភាសាខ្មែរ

២. អដ្ឋកថា ច្បាប់ពុទ្ធិកបណ្ឌិតសភា

៣. ដីកា ច្បាប់ពុទ្ធិកបណ្ឌិតសភា

៤. អត្ថយោជនាបញ្ជិកា

៥. យោជនាអដ្ឋសាលិនី

៦. មោហវិច្ឆេទនី

៧. អភិធម្មត្ថសង្គហៈ

៨. វចនានុក្រមខ្មែរ ។

# សម្ដែងហេតុនៃការប្រាកដឡើងព្រះអភិធម្ម

ទយាយ តាយ សត្តេសុ    សមុស្សាហិតមានសោ
បាដិហីរាវសានម្ហិ    វសន្តោ តិទសាលយេ
បារិច្ឆត្តកមូលម្ហិ    បណ្ឌុកម្ពលនាមកេ
សិលាសនេ សន្និសិន្នោ    អាទិច្ចោវ យុគន្ធរេ
ចក្កវាឡសហស្សេហិ    ទសហាគម្ម សព្វសោ
សន្និសិន្នេន ទេវានំ    គណេន បរិវារិតោ
មាតរំ បមុខំ កត្វា    តស្សា បញ្ញាយ តេជសា
អភិធម្មកថាមគ្គំ    ទេវានំ សម្បវត្តយិ
ឥតិ មេ ភាសមានស្ស    អភិធម្មកថំ ឥមំ
អវិក្ខិត្តា និសាមេថ    ទុល្លភា ហិ អយំ កថា ។

ព្រះសម្មាសម្ពុទ្ធអង្គណា មានព្រះទ័យដែលព្រះករុណានោះឱ្យឧស្សាហ៍ល្អ ហើយក្នុងសត្វលោក ទ្រង់គង់ប្រថាប់ចាំព្រះវស្សាស្ថានជាន់តាវត្តិង្ស កាលព្រះអង្គទ្រង់សម្ដែងយមកប្បាដិហារ្យហើយទ្រង់គង់ប្រថាប់លើសិលាសនៈ ដែលមានឈ្មោះថាបណ្ឌុកម្ពល នៅក្រោមដើមបារិច្ឆត្តកៈ[១] ដូចជាព្រះអាទិត្យរះលើកំពូលភ្នំយុគន្ធរ មានពួកទេវតាទាំងឡាយដែលមកអំពីម៉ឺនចក្រវាឡ បានប្រជុំគ្នាអង្គុយគ្រៀបគ្រា ព្រះពុទ្ធអង្គទ្រង់ធ្វើសន្តុសិតទេវបុត្រ ដែលធ្លាប់ជាពុទ្ធមាតាឱ្យជាប្រមុខ ហើយទ្រង់សម្ដែងលំដាប់អភិធម្មកថា (ព្រះអភិធម្ម ៧ គម្ពីរ) ដល់ទេវតា និងព្រហ្មទាំងឡាយ ដោយតេជានុភាពនៃព្រះសព្វញ្ញុតញ្ញាណ សូមសាធុជនទាំងឡាយ កុំមានចិត្តរាយមាយ

---

(១) ដើមរលួសផ្អុង ។

ចូរតាំងចិត្តស្តាប់ព្រះអភិធម្មកថានេះរបស់ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ព្រោះកថានេះកម្របានស្តាប់ណាស់ ⁽¹⁾ ។

# អធិប្បាយមាតិកា និងប្រភេទនៃមាតិកា

**មាតា វិយាតិ មាតិកា** ឈ្មោះថា **មាតិកា** ព្រោះអត្ថថាប្រៀបដូចជាម៉ែ បទពួកនោះ បានដល់ កុសលា ធម្មាជាដើម ។

ពាក្យថា **មាតិកា**នេះ គឺ **ឧទ្ទេស** បានដល់ តិកមាតិកា ៦៦ បទ, ទុកមាតិកា ២៨៤ បទ, សរុបមកបាន ៣៥០ បទនុ៎ះឯង ។ បទ ៣៥០ បទ មាន **កុសលា ធម្មា** ជាដើម ដែលជា **ឧទ្ទេស** ឈ្មោះថា មាតិកា ព្រោះជាឋានៈឱ្យនិទ្ទេសកើតឡើង ប្រៀបដូចជាម៉ែដែលជាឋានៈឱ្យកូនកើតឡើង (ដូចម៉ែជាអ្នកសម្រាលនូវកូន) លោកសម្តែងទុកក្នុងគម្ពីរ**វិមតិវិនោទនីដីកា**ថា ៖

**មាតិកាតិ ឧទ្ទេសោ, សោ ហិ និទ្ទេសបទានំ ជននិដ្ឋានេ ឋិតត្តា មាតា វិយាតិ មាតិកាតិ វុច្ចតិ ។**

ប្រែថា ឈ្មោះថា **មាតិកា** គឺ **ឧទ្ទេស**, ព្រោះថាឧទ្ទេសនេះ លោកហៅថា **មាតិកា** ព្រោះមានអត្ថថាដូចជាម៉ែ ព្រោះតាំងនៅក្នុងឋានៈនៃការកើតឡើងរបស់បទនិទ្ទេសទាំងឡាយ (ជាមេបទ⁽²⁾របស់និទ្ទេសទាំងឡាយ) **ឧទ្ទេស** បានដល់ កុសលា ធម្មា ជាដើម, **និទ្ទេស** បានដល់ អង្គធម៌របស់ឧទ្ទេសនុ៎ះឯង ។

---

⁽¹⁾ អស់ ៤ អសង្ខេយ្យ ១ សែនមហាកប្ប ។

⁽²⁾ **មេបទ** គឺមេសេចក្តីដែលឱបក្រសោបបំនួននិទ្ទេសបទឲ្យឋិតនៅក្នុងអំណាចខ្លួន ( ទុកដូចជាមាតាដែលជាមេបន្ទុករបស់កូន ) ខសំខាន់, គោលសង្ខេប ។ (វចនានុក្រមខ្មែរ)

តិកមាតិកា និងទុកមាតិកានេះ ពោលដោយប្រភេទនៃឈ្មោះមាន ២ យ៉ាងគឺ **អាទិលទ្ធនាមត្តិកៈ អាទិលទ្ធនាមទុកៈ សព្វលទ្ធនាមត្តិកៈ សព្វលទ្ធនាមទុកៈ** ។

ការកំណត់ឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** ឬ **អាទិលទ្ធនាមទុកៈ**នោះ ព្រោះអាស្រ័យសព្ទដែលតាំងនៅក្នុងបទដំបូងរបស់តិកៈ ឬ ទុកៈ នោះ ជាហេតុនៃការតាំងឈ្មោះ ដូចជា **កុសលត្តិកៈ** ជាដើម ។

ការកំណត់ឈ្មោះថា **សព្វលទ្ធនាមត្តិកៈ** ឬ **សព្វលទ្ធនាមទុកៈ**នោះ ព្រោះអាស្រ័យសព្ទដែលតាំងនៅក្នុងបទទាំង ៣ ឬ បទទាំង ២ នោះ ជាហេតុនៃការតាំងឈ្មោះ ដូចជា **វេទនាត្តិកៈ**ជាដើម ។

ពោលដោយបរមត្ថធម៌ដែលសង្គ្រោះចូលបាន មាន ២ យ៉ាង គឺ **និប្បទេសត្តិកៈ និប្បទេសទុកៈ** និង**សប្បទេសត្តិកៈ សប្បទេសទុកៈ** ។

ការកំណត់ឈ្មោះថា **និប្បទេសត្តិកៈ** ឬ **និប្បទេសទុកៈ** នោះ ព្រោះអាស្រ័យតិកៈ ឬ ទុកៈ ដែលព្រះពុទ្ធអង្គទ្រង់សម្តែងបរមត្ថធម៌ ៤ ទាំងអស់មិនមានសេសសល់ ដូចជា **កុសលត្តិកៈ**ជាដើម ។

ការកំណត់ឈ្មោះថា **សប្បទេសត្តិកៈ** ឬ **សប្បទេសទុកៈ** នោះ ព្រោះអាស្រ័យតិកៈ ឬ ទុកៈ ដែលព្រះពុទ្ធអង្គទ្រង់សម្តែងបរមត្ថធម៌ទាំង ៤ ដែលមិនទាន់អស់ គឺ នៅមានសេសសល់ ដូចជា **វេទនាត្តិកៈ** ជាដើម ។

# សម្តែងកណ្ឌទាំង ៤

គម្ពីរធម្មសង្គណី ជាគម្ពីរទី ១ បណ្តាព្រះអភិធម្មទាំង ៧ គម្ពីរដែលព្រះពុទ្ធអង្គទ្រង់ទេសនានេះ ក្នុងគម្ពីរធម្មសង្គណី ពោលដោយកណ្ឌហើយ ក៏មាន ៤ កណ្ឌ គឺះ

១. **ចិត្តុប្បាទកណ្ឌ** ជាកណ្ឌដែលសម្តែងការបែកតិកមាតិកា និងទុកមាតិកា ដោយបរមត្ថធម៌ទាំង ៤ មានចិត្ត និងចេតសិកដោយពិស្តារ ។

២. **រូបកណ្ឌ** ជាកណ្ឌដែលសម្តែងការបែករូប ដោយន័យថា ធម៌ពួក ១, ធម៌ពួក ២, ជាដើមរហូតដល់ធម៌ពួក ១១ ដោយពិស្តារ ។

៣. **និក្ខេបកណ្ឌ** ជាកណ្ឌដែលសម្តែងបរមត្ថធម៌យ៉ាងកណ្តាលៗ គឺសម្តែងដោយមូលខ្លះ ដោយខន្ធខ្លះ ដោយទ្វារខ្លះជាដើម ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យបានពោលទុកថា៖

**មូលតោ ខន្ធតោ ចាបិ ទ្វារតោ ចាបិ ភូមិតោ**
**អត្ថតោ ធម្មតោ ចាបិ នាមតោ ចាបិ លិង្គតោ**
**និក្ខិបិត្វា ទេសិតត្តា និក្ខេបោតិ បវុច្ចតិ** (១) ។

ប្រែថា និក្ខេបរាសិនោះ លោកហៅថា និក្ខេបៈ ព្រោះព្រះអង្គទ្រង់សម្តែងដោយសង្ខេប គឺ ដោយមូលខ្លះ ដោយខន្ធខ្លះ ដោយទ្វារខ្លះ ដោយភូមិខ្លះ ដោយអត្ថខ្លះ ដោយធម៌ខ្លះ ដោយឈ្មោះខ្លះ ដោយភេទខ្លះ ។

៤. **អដ្ឋកថាកណ្ឌ** ជាកណ្ឌដែលសម្តែងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកយ៉ាងសង្ខេប ។

---

(១) អដ្ឋសាលិនី ។

# ចិត្តុប្បាទកណ្ឌ

ក្នុងកណ្ឌទាំង ៤ នោះ ចិត្តុប្បាទកណ្ឌ មាន ២ យ៉ាង គឺ៖

១. **មាតិកា** ជាការសម្តែងមេបទ ឬ ឧទ្ទេស បានដល់ **កុសលា ធម្មា អកុសលា ធម្មា**ជាដើមរហូតដល់ **ខយេ ញាណំ, អនុប្បាទេ ញាណំ** ។

២. **បទភាជនីយ៍** ជាការសម្តែងពន្យល់សេចក្តីមេបទ គឺ **កតមេ ធម្មា កុសលា** ជាដើមរហូតដល់ **អមោហោ អព្យាកតមូលំ ។ល។ ឥមេ ធម្មា អព្យាកតា** ។

<u>**បំណាំ**</u> ក្នុងគម្ពីរនេះ បានសម្តែងមាតិកា និងបទភាជនីយ៍ព្រមគ្នាទាំង ២ យ៉ាង ដូចជា **កុសលា ធម្មា** ព្រមទាំងពាក្យប្រែនោះ**ជាបទមាតិកា**, អង្គធម៌ និងការចែកខន្ធ, អាយតនៈ, ធាតុ, សច្ចៈ, **ជាបទភាជនីយ៍** ។

# មាតិកា មាន ២ យ៉ាង

១. **តិកមាតិកា** ជាមាតិកាដែលចែកបរមត្ថធម៌ទាំង ៤ ដោយចែកចេញជា ៣ បទ មាន ២២ តិកៈ គឺ **កុសលត្តិកៈ** ជាដើម រហូតដល់ **សនិទស្សនត្តិកៈ** ជាទីបំផុត ។

២. **ទុកមាតិកា** ជាមាតិកាដែលចែកបរមត្ថធម៌ទាំង ៤ ដោយចែកចេញជា ២ បទ មាន ២ យ៉ាង គឺ អភិធម្មទុកមាតិកា មាន ១០០ ទុកៈគឺ **ហេតុទុកៈ** ជាដើម រហូតដល់ **សរណទុកៈ** ជាទីបំផុត, សុត្តន្តិកទុកមាតិកា មាន ៤២ ទុកៈ គឺ **វិជ្ជាភាគីទុកៈ** ជាដើម រហូតដល់ **ខយេញាណទុកៈ** ជាទីបំផុត ។

# តិកមាតិកា

## ១. កុសលត្តិកៈ

បឋមបទ. **កុសលា ធម្មា** ពួកធម៌ជាកុសល (១) បានដល់ កុសលចិត្ត ២១, ចេតសិក ៣៨ ។

ទុតិយបទ. **អកុសលា ធម្មា** ពួកធម៌ជាអកុសល (២) បានដល់ អកុសលចិត្ត ១២, ចេតសិក ២៧ ។

តតិយបទ. **អព្យាកតា ធម្មា** ពួកធម៌ជាអព្យាក្រឹត (៣) បានដល់ វិបាកចិត្ត ៣៦, កិរិយាចិត្ត ២០, ចេតសិក ៣៨, រូប ២៨, និព្វាន ។

**<u>អង្គធម៌របស់បឋមបទ</u>** បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបាន ខន្ធ ៤, អាយតនៈ ២, ធាតុ ២, សច្ចៈ ២ ។

**ខន្ធ ៤ គឺ** ក្នុងចេតសិក ៣៨ នោះ វេទនាចេតសិកជាវេទនាខន្ធ, សញ្ញាចេតសិកជាសញ្ញាខន្ធ,ចេតសិកដ៏សេស ៣៦ ជាសង្ខារក្ខន្ធ, កុសលចិត្ត ២១ ជា វិញ្ញាណក្ខន្ធ ។

---

(១) ធម៌ ក្នុងទីនេះ សំដៅយកសភាវៈមិនមែនសត្វ មិនមែនជីវិត (ស្វាយមិធាបិ និស្សត្ត-និជ្ជីវតាយមេវ វដ្តតិ), កុសល ក្នុងទីនេះ ប្រែថា ធម្មជាតមិនមានរោគ មិនមានទោស មាន ផលជាសុខ ( ស្វាយមិធ អារោគ្យេបិ អនវជ្ជេបិ សុខវិបាកេបិ វត្តតិ ) ។

(២) អកុសល ប្រែថា ធម្មជាតប្រកបដោយទោស មានផលជាទុក្ខ (សាវជ្ជទុក្ខវិបាក-លក្ខណា អកុសលា) ។

(៣) អព្យាក្រឹតនេះ ព្រះដ៏មានព្រះភាគមិនសម្តែងដោយសភាពជាកុសល និងអកុសល គឺ មានលក្ខណាឥតផល ។

**អាយតនៈ ២ គឺ** កុសលចិត្ត ២១ ជាមនាយតនៈ, ចេតសិក ៣៨ ជាធម្មាយតនៈ ។

**ធាតុ ២ គឺ** កុសលចិត្ត ២១ ជាមនោវិញ្ញាណធាតុ, ចេតសិក ៣៨ ជាធម្មធាតុ ។

**សច្ចៈ ២ គឺ** លោកិយកុសលចិត្ត ១៧ ចេតសិក ៣៨ ក្នុងលោកិយកុសលចិត្តជាទុក្ខសច្ចៈ, អង្គមគ្គ ៨ ក្នុងបឋមជ្ឈានមគ្គចិត្ត និងអង្គមគ្គ ៧ (វៀរសម្មាសង្កប្បៈ) ក្នុងទុតិយជ្ឈានមគ្គចិត្តជាដើម ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៩ ជាសច្ចវិមុត្ត ។

<u>**អង្គធម៌របស់ទុតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបាន ខន្ធ ៤, អាយតនៈ ២, ធាតុ ២, សច្ចៈ ២ ។

**ខន្ធ ៤ គឺ** ក្នុងចេតសិក ២៧ នោះ វេទនាចេតសិកជាវេទនាខន្ធ, សញ្ញាចេតសិក ជាសញ្ញាខន្ធ, ចេតសិកដ៏សេស ២៥ ជាសង្ខារក្ខន្ធ, អកុសលចិត្ត ១២ ជាវិញ្ញាណក្ខន្ធ ។

**អាយតនៈ ២ គឺ** អកុសលចិត្ត ១២ ជាមនាយតនៈ, ចេតសិក ២៧ ជាធម្មាយតនៈ ។

**ធាតុ ២ គឺ** អកុសលចិត្ត ១២ ជាមនោវិញ្ញាណធាតុ, ចេតសិក ២៧ ជាធម្មធាតុ ។

**សច្ចៈ ២ គឺ** អកុសលចិត្ត ១២ ចេតសិក ២៦ (វៀរលោភៈ) ជាទុក្ខសច្ចៈ, លោភចេតសិកជាសមុទយសច្ចៈ ។

<u>**អង្គធម៌របស់តតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបាន ខន្ធ ៥, អាយតនៈ ១២, ធាតុ ១៨, សច្ចៈ ២ ។

**ខន្ធ ៥ គឺ** រូប ២៨ ជារូបក្ខន្ធ, ក្នុងចេតសិក ៣៨ នោះ វេទនាចេតសិក ជាវេទនាខន្ធ, សញ្ញាចេតសិក ជាសញ្ញាខន្ធ, ចេតសិកដ៏សេស ៣៦ ជាសង្ខារក្ខន្ធ,

វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ជាវិញ្ញាណក្ខន្ធ, និព្វាន ជាខន្ធវិមុត្ត ។

**អាយតនៈ ១២ គឺ** ក្នុងរូប ២៨ នោះ ចក្ខុបសាទ ជាចក្ខាយតនៈ, សោតបសាទ ជាសោតាយតនៈ, ឃានបសាទ ជាឃានាយតនៈ, ជិវ្ហាបសាទ ជាជិវ្ហាយតនៈ, កាយ-បសាទ ជាកាយាយតនៈ, រូបារម្មណ៍ ជារូបាយតនៈ, សទ្ទារម្មណ៍ ជាសទ្ទាយតនៈ, គន្ធា-រម្មណ៍ ជាគន្ធាយតនៈ, រសារម្មណ៍ ជារសាយតនៈ, ផោដ្ឋព្វារម្មណ៍ ជាផោដ្ឋព្វាយតនៈ, វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ជាមនាយតនៈ, ចេតសិក ៣៨ សុខុមរូប ១៦ និព្វាន ជាធម្មាយតនៈ ។

**ធាតុ ១៨ គឺ** ក្នុងរូប ២៨ នោះ ចក្ខុបសាទ ជាចក្ខុធាតុ, សោតបសាទ ជាសោត-ធាតុ, ឃានបសាទ ជាឃានធាតុ, ជិវ្ហាបសាទ ជាជិវ្ហាធាតុ, កាយបសាទ ជាកាយធាតុ, រូបារម្មណ៍ ជារូបធាតុ, សទ្ទារម្មណ៍ ជាសទ្ទធាតុ, គន្ធារម្មណ៍ ជាគន្ធធាតុ, រសារម្មណ៍ ជារសធាតុ, ផោដ្ឋព្វារម្មណ៍ ជាផោដ្ឋព្វធាតុ, ចក្ខុវិញ្ញាណចិត្ត ២ ជាចក្ខុវិញ្ញាណធាតុ, សោតវិញ្ញាណចិត្ត ២ ជាសោតវិញ្ញាណធាតុ, ឃានវិញ្ញាណចិត្ត ២ ជាឃានវិញ្ញាណ-ធាតុ, ជិវ្ហាវិញ្ញាណចិត្ត ២ ជាជិវ្ហាវិញ្ញាណធាតុ, កាយវិញ្ញាណចិត្ត ២ ជាកាយវិញ្ញាណ-ធាតុ, បញ្ចទ្វារាវជ្ជនចិត្ត ១ សម្បដិច្ឆនចិត្ត ២ ជាមនោធាតុ, វិបាកចិត្តដ៏សេស ២៤ និងកិរិយាចិត្តដ៏សេស ១៩ ជាមនោវិញ្ញាណធាតុ, ចេតសិក ៣៨ សុខុមរូប ១៦ និព្វាន ជាធម្មធាតុ ។

**សច្ចៈ ២ គឺ** លោកិយវិបាកចិត្ត ៣២ កិរិយាចិត្ត ២០ ចេតសិក ៣៥ (វៀរវិរតិ ៣) រូប ២៨ ជាទុក្ខសច្ចៈ, និព្វាន ជានិរោធសច្ចៈ, ផលចិត្តុប្បាទ ៣៧ ជាសច្ចវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** ព្រោះអាស្រ័យពាក្យថា**កុសល** ដែលតាំងនៅខាងដើម ជាហេតុនៃការតាំងឈ្មោះ និងឈ្មោះថា **និប្បទេសត្តិកៈ** ព្រោះសម្ដែងបរមត្ថធម៌ទាំងអស់មិនមានសេសសល់ ។

# អធិប្បាយកុសលត្តិកៈ

**១. កុច្ឆិតេ បាបធម្មេ សលយន្តិ កម្បេន្តិ ចាលេន្តិ អបគមេន្តីតិ កុសលានិ**
ធម្មជាតិណា រមែងធ្វើបាបធម៌ដែលបណ្ឌិតទាំងឡាយគួរខ្ពើមឱ្យញាប់ញ័រ, បៀតបៀន, បានដល់ធ្វើឱ្យវិនាសទៅឱ្យអស់ទៅ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា កុសល ។ ឬ ធម្មជាតិណា រមែងធ្វើបាបធម៌ដែលបណ្ឌិតទាំងឡាយគួរខ្ពើមឱ្យញាប់ញ័រ គឺ ឱ្យវិនាសទៅ ឈ្មោះថា កុសល ។

ម្យ៉ាងទៀត កុសៈ គឺ បញ្ញា ព្រោះធ្វើបាបធម៌ដែលគួរខ្ពើម ឱ្យខ្សោយកម្លាំងដោយតទង្គប្បហានៈ (លះដោយអង្គនោះៗ), វិក្ខម្ភនប្បហានៈ (លះដោយការគ្របសង្កត់), ឬឱ្យអស់ទៅ គឺ ឱ្យវិនាសទៅ ដោយសមុច្ឆេទប្បហានៈ (លះដោយការកាត់ផ្ដាច់) ។

កុសល គឺ ជាសភាវដែលគប្បីកាន់យក ពោលគឺ ឱ្យប្រព្រឹត្តទៅជាមួយគ្នានឹងបញ្ញា ព្រោះបញ្ញាជាឧបនិស្សយប្បច្ច័យដល់ធម៌ដែលមិនប្រកបដោយបញ្ញា ។ ពាក្យថា **ឱ្យប្រព្រឹត្តទៅជាមួយគ្នានឹងបញ្ញា** អធិប្បាយថា ធ្វើចិត្តដែលប្រកបដោយបញ្ញា ឱ្យប្រព្រឹត្តទៅក្នុងសន្ដាន ដោយការកើតរួមគ្នា និងដោយអាការៈជាឧបនិស្សយប្បច្ច័យ ។ ពិតណាស់ បញ្ញាជាឧបនិស្សយប្បច្ច័យដល់ធម៌ដែលមិនប្រកបដោយបញ្ញា គឺ ញាណវិប្បយុត្ត ព្រោះជាហេតុធ្វើឱ្យបញ្ញាកើតឡើងតមក ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើកុសលទាំង ២ បំណែក គឺ កុសលដែលមានបញ្ញាកើតរួម និងកុសលដែលមានបញ្ញាជាឧបនិស្សយប្បច្ច័យ ឱ្យកើតឡើងជាប្រចាំដោយមានសទ្ធាជាដើមជាប្រធាន [១] ។

---

[១] អត្ថយោជនា ។

# សម្តែងអង្គធម៌ និងការលះរបស់កុសល មាន ៣ ប្រភេទ

គ្រាដំបូង បណ្ឌិតគប្បីជ្រាបវិបនត្ថៈនីមួយៗ ព្រមទាំងអង្គធម៌ដូចតទៅ៖

-**សលយន្តិ កម្បេន្តិ** ប្រែថា ធ្វើឱ្យញាប់ញ័រ ឬធ្វើឱ្យកម្រើក ជាបទសម្តែងការលះដោយតទង្គប្បហានៈ បានដល់ មហាកុសលចិត្តុប្បាទ ៨ ដួង ។

-**សលយន្តិ ហឹសេន្តិ** ប្រែថា ធ្វើនូវការបៀតបៀន ជាបទសម្តែងការលះដោយវិក្ខម្ភនប្បហានៈ បានដល់ មហគ្គតកុសលចិត្តុប្បាទ ៩ ដួង ។

-**សលយន្តិ អបគមេន្តិ** ប្រែថា ធ្វើឱ្យវិនាសទៅ ឱ្យអស់ទៅ ជាបទសម្តែងការលះដោយសមុច្ឆេទប្បហានៈ បានដល់ មគ្គចិត្តុប្បាទ ៤ ដួង (១) ។

២. **ន កុសលំ អកុសលំ** ធម្មជាតិដែលមិនមែនជាកុសល គឺ បដិបក្ខចំពោះកុសល ឈ្មោះថា អកុសល ដូចជាអមិត្ត បដិបក្ខចំពោះមិត្ត (បដិបក្ខា អមិត្តា វិយ) ។ ពាក្យថា អលោភៈជាដើមនេះ ក៏មានន័យដូចគ្នា ។

៣. **ន ព្យាកតោ អព្យាកតោ** (កុសលាកុសលភាវេន អកថិតោ អញ្ញភាវេន កថិតោ) ធម្មជាតិដែលទ្រង់មិនបានសម្តែងដោយភាពជាកុសល និងអកុសល តែទ្រង់សម្តែងយ៉ាងដទៃ ឈ្មោះថា អព្យាក្រឹត ។

---

(១) អត្ថយោជនាថា៖ កម្បេន្តិ ហឹសេន្តិ អបគមេន្តីតិ បទត្តយំ សលយន្តីតិ បទស្ស អត្ថវិវរណំ ។ តត្ថ តីសុ បទេសុ **កម្បេន្តីតិ** បទំ តទង្គវសេន បាបធម្មេ បជហន្តំ កាមាវចរកុសលំ សន្ធាយ វិវរតិ ។ **ហឹសេន្តីតិ** វិក្ខម្ភនវសេន បាបធម្មេ បជហន្តំ មហគ្គតកុសលំ សន្ធាយ វិវរតិ ។ **អបគមេន្តីតិ** សមុច្ឆេទវសេន បាបធម្មេ បជហន្តំ លោកុត្តរកុសលំ សន្ធាយ វិវរតិ ។

## ហេតុផលនៃការសម្តែងកុសលត្តិកៈ មុនតិកៈដទៃៗ

ប្រសិនបើមានសំណួរសួរថា ព្រោះហេតុអ្វី បានជាព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងតិកៈមាតិកាមុនទុកៈមាតិកា? ហើយទ្រង់សម្តែងកុសលត្តិកៈប៉ុណ្ណោះ មុនតិកៈដទៃៗទៀត ?

ខ្ញុំព្រះដីកាចារ្យ (អាចារ្យធម្មបាលៈ) នឹងឆ្លើយសំណួរនេះទៅតាមលំដាប់ ។

ហេតុផលដែលព្រះពុទ្ធអង្គទ្រង់សម្តែងតិកៈមាតិកាដំបូងគេទាំងអស់នោះ ព្រោះជាធម៌កាន់យកបាន**ដោយស្រួល** (សុខគ្គហណតោ) និងមាន**ប្រភេទតិច** (អប្បភេទ-តោ) ។ ព្រោះហេតុជាដើមដែលមានបំណែកផ្សេងៗគ្នានោះ ក្នុងប្រភេទមានកុសលជាដើម គឺ បណ្ឌិតអាចជ្រាបបានដោយកុសលត្តិកៈនុ៎ះឯងថា ជាធម៌ដឹងបានដោយងាយ ។ ពិតណាស់ លោកចែកហេតុជាដើម ដោយការកាន់យកកុសលហេតុជាដើមជាប្រធាន ដោយន័យថា **តយោ កុសលហេតូ** ប្រែថា កុសលហេតុ មាន ៣ ប្រការជាដើម ។ តិកៈមាតិកាក៏មានប្រភេទតិច ព្រោះមានត្រឹមតែ ២២ តិកៈប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគសម្តែងកុសលត្តិកៈមុនតិកៈផ្សេងៗ ដោយសភាពនៃកុសលជាធម៌ដ៏ល្អ មានការមិនប្រឫកប្របល់ដោយការរួបរួមបរមត្ថធម៌ទាំង ៤ បានទាំងអស់ ។ ពិតណាស់ លោកសម្តែងនាមធម៌ និងរូបធម៌ (បរមត្ថធម៌ទាំង ៤) ដោយមិនមានសេសសល់ទុកក្នុងកុសលត្តិកៈនេះបានទាំងអស់ មិនបានសម្តែងដោយវេទនាត្តិកៈជាដើមទេ ។

សួរថា សូម្បីវិបាកត្តិកៈជាដើម លោកក៏សម្តែងបរមត្ថធម៌បានទាំងអស់ មិនមែនទេឬ ? ឆ្លើយថា ពាក្យនេះ ត្រឹមត្រូវណាស់, ប៉ុន្តែ បណ្តាវិបាកត្តិកៈជាដើមនោះ លោកពោលដល់ធម៌ដែលមិនមានទោស និងមានទោសប៉ុណ្ណោះ មិនមែនសម្តែងព្រោះការមិនលាយឡំគ្នា ដូចជាកុសលត្តិកៈនោះទេ ។ សួរទៀតថា សូម្បីក្នុងសង្កិ-

លិង្គសង្កិលេសិកត្តិកៈជាដើម លោកក៏សម្ដែងដោយមិនមានការលាយឡំដូចគ្នា មិនមែនទេឬ ? ឆ្លើយថា ពាក្យនេះ ត្រឹមត្រូវដូចគ្នា, ប៉ុន្តែ ធម៌ទាំងអស់នេះលោកសម្ដែងអកុសលធម៌ទុកខាងដើមដែលជាធម៌មិនល្អ, មិនដូចជាកុសលត្តិកៈនេះឡើយ ។ ព្រោះថា លោកសម្ដែងកុសលធម៌ដែលធ្វើឱ្យសម្រេចដល់នូវការអស់ទៅនៃភព ជាធម៌សមគួរដល់ការបូជាទុកជាខាងដើម ។ ព្រះដ៏មានព្រះភាគ កាលនឹងប្រារព្ធនាមរូបដ៏ល្អិតសុខុមនេះ ក៏ទ្រង់សម្ដែងកុសលត្តិកៈទុកជាខាងដើម ព្រោះប្រកបដោយគុណដ៏ល្អមានការមិនលាយឡំគ្នា ដោយការរួបរួមបរមត្ថធម៌បានទាំងអស់ ។

ម្យ៉ាងវិញទៀត សូម្បីក្នុងកុសលត្តិកៈ លោកក៏សម្ដែងកុសលធម៌ទុកជាខាងដើម ព្រោះដើម្បីជាប្រយោជន៍ទាំង ២ ចំណែក គឺ ជាប្រធាន (បធានៈ) និងជាធម៌គួរសរសើរ (បាសំសៈ) ។

ពិតណាស់ កុសលធម៌ជាធម្មជាតិខ្ពង់ខ្ពស់ជាងសង្ខតធម៌ទាំងអស់ ព្រោះឱ្យវិបាកជាសុខ, ជាធម៌បណ្ឌិតគួរសរសើរ ព្រោះកំចាត់ធម៌ដែលមានទោស, ជាធម៌នាំប្រយោជន៍មកឱ្យទាំងលោកនេះនិងបរលោក, ហើយទីបំផុតនឹងនាំសត្វឱ្យចេញពីវដ្ដៈ គឺ ចេញពីសង្សារទុក្ខ ។ ព្រោះហេតុនោះ បានជាលោកសម្ដែងកុសលធម៌ជាលំដាប់ទី ១ ដោយភាវៈជាប្រធានជាដើម ។ ឯអកុសលវិញ ទ្រង់សម្ដែងក្នុងលំដាប់នៃកុសលនោះ ព្រោះជាធម៌បដិបក្ខចំពោះកុសល, ទ្រង់សម្ដែងអព្យាកតៈធម៌ជាទីបំផុត ព្រោះមានសភាវៈផ្ទុយគ្នានឹងធម៌ទាំង ២ នោះ ។

ឬមួយវិញទៀត ទ្រង់សម្ដែងតាមលំដាប់នៃអស្សាទៈ គឺ សេចក្ដីពេញចិត្ត, អាទីនវៈ គឺ ទោស, និងនិស្សរណៈ គឺ ព្រះនិព្វាន ធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកលោកនុ៎ះឯង ។

អធិប្បាយថា សភាពរបស់កុសលធម៌ទាំងនេះ មានការប្រព្រឹត្តិទៅដែលសត្វទាំងឡាយ គប្បីត្រេកអរពេញចិត្ត (កុសលវិសេន អស្សាទោ) ទើបទ្រង់សម្ដែងកុសលធម៌ជាខាងដើម, ការប្រព្រឹត្តិទៅរបស់អកុសលធម៌ មានទោសដែលមិនគប្បីត្រេកអរពេញចិត្ត (អកុសលវិសេន អាទីនវោ) ទើបទ្រង់សម្ដែងអកុសល បន្ទាប់អំពីកុសលធម៌, បំណែកឯ ក្នុងអព្យាកតធម៌ បំពោះព្រះនិព្វានប៉ុណ្ណោះ មានសភាពដែលរួចផុតបាកវដ្តទុក្ខ (អព្យាកតធម្មេសុ និព្វានវិសេន និស្សរណំ) ព្រោះហេតុនោះ ទើបទ្រង់សម្ដែងអព្យាកតធម៌ជាទីបំផុត ។

មួយន័យទៀត ទ្រង់សម្ដែងកុសល អកុសល និងអព្យាកតធម៌តាមលំដាប់នៃការបដិបត្តិនោះឯង គឺ បណ្ឌិតទាំងឡាយ រមែងតាំងនៅក្នុងកុសលធម៌ ហើយប្រហារអកុសល ធ្វើមគ្គផលដែលជាអព្យាកតធម៌ និងព្រះនិព្វានឱ្យប្រាកដ ព្រោះហេតុនោះ ទើបទ្រង់សម្ដែងកុសល អកុសល និងអព្យាកតធម៌មកតាមលំដាប់ [១] ។

ឬម្យ៉ាងទៀត ព្រោះព្រះអភិធម្មនេះ ព្រះអង្គទ្រង់សម្ដែងឱ្យទេវតាទាំងឡាយស្ដាប់មុនគេទាំងអស់ ជាប្រក្រតីអធ្យាស្រ័យរបស់ទេវតានោះដោយច្រើនចូលចិត្តក្នុងហេតុនៃសេចក្ដីចម្រើន ដូចជាទេវតាទាំងឡាយសាកសួរបញ្ហាមានមង្គលសូត្រជាដើម ។ អាស្រ័យហេតុដូចបានពោលមកនេះ ព្រះសម្មាសម្ពុទ្ធ ទើបទ្រង់សម្ដែង **កុសលត្តិកៈ** មុនតិកៈដទៃៗ ។

---

[១] ធម្មសង្គណីអនុដីកា ទំព័រ ៥៧ ជាដើម ។

# អធិប្បាយមគ្គសច្ចៈ និងសច្ចវិមុត្តក្នុងកុសលត្តិកៈ

ធម៌ដែលជាមគ្គសច្ចៈរមែងមាន ៨ ប្រការគឺ បញ្ញា វិតក្កៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ វីរិយៈ សតិ ឯកគ្គតាចេតសិក ដែលប្រកបក្នុងមគ្គចិត្តទាំង ៤, មគ្គចិត្តនេះ បើចែកដោយប្រភេទនៃឈានមាន ៥ យ៉ាងគឺ បឋមជ្ឈានមគ្គចិត្ត ទុតិយជ្ឈានមគ្គចិត្ត តតិយជ្ឈានមគ្គចិត្ត ចតុត្ថជ្ឈានមគ្គចិត្ត និង បញ្ចមជ្ឈានមគ្គចិត្ត ។

ក្នុងបឋមជ្ឈានមគ្គចិត្តនោះ មានអង្គមគ្គ ៨, ទុតិយជ្ឈានមគ្គចិត្តជាដើមរហូតដល់ បញ្ចមជ្ឈានមគ្គចិត្តនោះមានអង្គមគ្គ ៧ វៀរវិតក្កចេតសិកដែលហៅថា សម្មាសង្កប្បៈ ព្រោះហេតុនោះដែលសម្តែងទុកក្នុងកុសលបទថា អង្គមគ្គ ៨ ដែលនៅក្នុងបឋមជ្ឈានមគ្គចិត្ត និងអង្គមគ្គ ៧ ដែលនៅក្នុងទុតិយជ្ឈានមគ្គចិត្តជាដើម ឈ្មោះថា មគ្គសច្ចៈ បណ្ឌិតគប្បីជ្រាបដូចបានពោលមកនេះ ។

ធម៌ដែលជាសច្ចៈវិមុត្តនោះ គឺ ធម៌ដែលមិនបានចាត់ចូលក្នុងទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និងមគ្គសច្ចៈនុ៎ះឯង សម្រាប់មគ្គចិត្ត ៤ ចេតសិកដ៏សេស ២៨ (វៀរអង្គមគ្គ ៨) និងផលចិត្ត ៤ ចេតសិកដែលប្រកប ៣៦ ទាំងអស់នេះ មិនបានចាត់ចូលក្នុងសច្ចៈទាំង ៤ ណាមួយឡើយ ទើបឈ្មោះថាសច្ចៈវិមុត្ត ។

ក្នុងកុសលបទដែលពោលថា មគ្គចិត្តុប្បាទដ៏សេស ២៩ ព្រោះមគ្គចិត្ត ៤ ដួងនោះបើពោលដោយលក្ខណៈហើយមានការដឹងអារម្មណ៍ជាលក្ខណៈដូចគ្នាទាំងអស់ ព្រោះហេតុនោះ ទើបរាប់មគ្គចិត្តទាំង ៤ ថាមានតែ ១, ព្រមទាំងចេតសិកដែលប្រកបដ៏សេស ២៨ ទៀត រួមជា ២៩ នេះឯងហៅថា **មគ្គចិត្តុប្បាទដ៏សេស ២៩** ។

មួយវិញទៀត ការកើតឡើងរបស់ចិត្តនោះ ខណៈនីមួយៗ រមែងកើតឡើងបានត្រឹមតែមួយដួងប៉ុណ្ណោះ មិនដូចជាចេតសិកធម៌ឡើយ កើតឡើងព្រមគ្នាក្នុងខណៈតែមួយបានច្រើនដួង ក្នុងខណៈនីមួយៗ រមែងមានមគ្គចិត្តកើតឡើងបានត្រឹម

តែ ១ ដួង និងចេតសិក ៣៦ ដួងទៀត រួមជា ៣៧ ឬ ហៅថា មគ្គបិត្តុប្បាទ ៣៧ ក៏បាន ក្នុងបំនួន ៣៧ នោះ វៀរអង្គមគ្គ ៨ ដែលជាមគ្គសច្ចៈចេញហើយ នៅសល់ត្រឹមតែ ២៩ នេះឯង ហៅថា មគ្គបិត្តុប្បាទដ៏សេស ២៩ ។

ក្នុងអព្យាកតបទដែលពោលថា ផលបិត្តុប្បាទ ៣៧ នោះ ក៏មានទំនងដូចគ្នានឹងមគ្គបិត្តុប្បាទ ២៩ នេះឯង ខុសគ្នាត្រឹមតែមិនចាំបាច់វៀរអង្គមគ្គ ៨ ប៉ុណ្ណោះ ។

## ចប់ កុសលត្តិកៈ

# ២. វេទនាត្តិកៈ

បឋមបទ. **សុខាយ វេទាយ សម្បយុត្តា ធម្មា** ពួកធម៌ដែលប្រកបដោយសុខវេទនា [១] បានដល់ សុខសហគតចិត្ត ៦៣ ចេតសិក ៤៦ (វៀរវេទនា) ។

ទុតិយបទ. **ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ដែលប្រកបដោយទុក្ខវេទនា បានដល់ ទុក្ខសហគតចិត្ត ៣ ចេតសិក ២១ (វៀរវេទនា) ។

តតិយបទ. **អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ដែលប្រកប ដោយវេទនាមិនជាទុក្ខមិនជាសុខ បានដល់ ឧបេក្ខាសហគតចិត្ត ៥៥ ចេតសិក ៤៦ (វៀរវេទនា) ។

**<u>អង្គធម៌របស់បឋមបទ</u>** បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈ ហើយបាន ខន្ធ ៣, អាយតនៈ ២, ធាតុ ៣, សច្ចៈ ៣ ។

**ខន្ធ ៣ គឺ** ក្នុងចេតសិក ៤៦ នោះ សញ្ញាចេតសិក ជាសញ្ញាខន្ធ, ចេតសិកដ៏សេស ៤៥ ជាសង្ខារក្ខន្ធ, សុខសហគតចិត្ត ៦៣ ជាវិញ្ញាណក្ខន្ធ ។

**អាយតនៈ ២ គឺ** សុខសហគតចិត្ត ៦៣ ជាមនាយតនៈ, ចេតសិក ៤៦ ជាធម្មាយតនៈ ។

**ធាតុ ៣ គឺ** សុខសហគតកាយវិញ្ញាណចិត្ត ១ ជាកាយវិញ្ញាណធាតុ, សុខសហគតចិត្តដ៏សេស ៦២ ជាមនោវិញ្ញាណធាតុ, ចេតសិក ៤៦ ជាធម្មធាតុ ។

---

[១] ពាក្យថា សម្បយុត្តក្នុងទីនេះ បានដល់ ប្រកបដោយលក្ខណៈទាំង ៤ មានការកើតឡើងព្រមគ្នាជាដើម ។

**សច្ចៈ ៣ គឺ** លោកិយសុខសហគតចិត្ត ៣១ ចេតសិក ៤៥ (វៀរលោភៈ) ជាទុក្ខសច្ចៈ, លោភចេតសិកជាសមុទយសច្ចៈ,អង្គមគ្គ ៨ ឬ ៧ ក្នុងមគ្គសុខសហគតចិត្ត ១៦ ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៨ និងផលចិត្តុប្បាទ ៣៦ ជាសច្ចវិមុត្ត ។

<u>**អង្គធម៌របស់ទុតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបាន ខន្ធ ៣, អាយតនៈ ២, ធាតុ ៣, សច្ចៈ ១ ។

**ខន្ធ ៣ គឺ** ក្នុងចេតសិក ២១ នោះ សញ្ញាចេតសិកជាសញ្ញាខន្ធ, ចេតសិកដ៏សេស ២០ ជាសង្ខារក្ខន្ធ, ទុក្ខសហគតចិត្ត ៣ ជាវិញ្ញាណក្ខន្ធ ។

**អាយតនៈ ២ គឺ** ទុក្ខសហគតចិត្ត ៣ ជាមនាយតនៈ, ចេតសិក ២១ ជាធម្មាយតនៈ ។

**ធាតុ ៣ គឺ** ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ ជាកាយវិញ្ញាណធាតុ, ទោសមូលចិត្ត ២ ជាមនោវិញ្ញាណធាតុ, ចេតសិក ២១ ជាធម្មធាតុ ។

**សច្ចៈ ១ គឺ** ទុក្ខសហគតចិត្ត ៣ ចេតសិក ២១ ជាទុក្ខសច្ចៈ ។

<u>**អង្គធម៌របស់តតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបាន ខន្ធ ៣, អាយតនៈ ២, ធាតុ ៧, សច្ចៈ ៣ ។

**ខន្ធ ៣ គឺ** ក្នុងចេតសិក ៤៦ នោះ សញ្ញាចេតសិកជាសញ្ញាខន្ធ, ចេតសិកដ៏សេស ៤៥ ជាសង្ខារក្ខន្ធ, ឧបេក្ខាសហគតចិត្ត ៥៥ ជាវិញ្ញាណក្ខន្ធ ។

**អាយតនៈ ២ គឺ** ឧបេក្ខាសហគតចិត្ត ៥៥ ជាមនាយតនៈ, ចេតសិក ៤៦ ជាធម្មាយតនៈ ។

**ធាតុ ៧ គឺ** ក្នុងឧបេក្ខាសហគតចិត្ត ៥៥ នោះ ចក្ខុវិញ្ញាណចិត្ត ២ ជាចក្ខុវិញ្ញាណធាតុ, សោតវិញ្ញាណចិត្ត ២ ជាសោតវិញ្ញាណធាតុ, ឃានវិញ្ញាណចិត្ត ២ ជាឃានវិញ្ញាណធាតុ, ជិវ្ហាវិញ្ញាណចិត្ត ២ ជាជិវ្ហាវិញ្ញាណធាតុ, បញ្ចទ្វារាវជ្ជនចិត្ត ១ សម្ប-

ដិប្ចនចិត្ត ២ ជាមនោធាតុ, ឧបេក្ខាសហគតចិត្តដ៏សេស ៤៤ ជាមនោវិញ្ញាណធាតុ, ចេតសិក ៤៦ ជាធម្មធាតុ ។

**សច្ចៈ ៣ គឺ** លោកិយឧបេក្ខាសហគតចិត្ត ៤៧ ចេតសិក ៤៥ (វៀរលោភៈ) ជាទុក្ខសច្ចៈ, លោភចេតសិកជាសមុទយសច្ចៈ, អង្គមគ្គ ៧ (វៀរសម្មាសង្កប្បៈ) ក្នុងមគ្គឧបេក្ខាសហគតចិត្ត ៤ ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៦ ផលចិត្តុប្បាទ ៣៣ ជាសច្ចវិមុត្ត ។

សុខវេទនាចេតសិក ៦៣, ទុក្ខវេទនាចេតសិក ៣, ឧបេក្ខាវេទនាចេតសិក ៥៥, រូប ២៨, និព្វាន ជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **សព្វលទ្ធនាមត្តិកៈ** ព្រោះអាស្រ័យពាក្យថា **វេទនា** ដែលតាំងនៅក្នុងបទទាំង ៣ ជាហេតុនៃការតាំងឈ្មោះ និងឈ្មោះថា **សប្បទេសត្តិកៈ** ព្រោះទ្រង់សម្តែងបរមត្ថធម៌មិនអស់ គឺ នៅមានសេសសល់ ។

# អធិប្បាយវេទនាត្តិកៈ

ក្នុងវេទនាតិកៈនេះ ព្រះពុទ្ធអង្គទ្រង់សម្តែងថា **សុខាយ វេទនាយ សម្បយុត្តា ធម្មា, ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា, អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** គឺទ្រង់សំដៅយកធម៌ដែលប្រកបដោយសុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនាប៉ុណ្ណោះ ទ្រង់មិនបានសម្តែងថា **សុខវេទនា ធម្មា, ទុក្ខវេទនា ធម្មា, អទុក្ខមសុខវេទនា ធម្មា** ។

អធិប្បាយថា សុខវេទនា នឹងប្រកបជាមួយសុខវេទនាមិនបាន ទុក្ខវេទនា និងឧបេក្ខាវេទនាក៏ដូចគ្នា ដោយហេតុនេះ វេទនាចេតសិក ទើបមិនអាចរាប់ចូលក្នុងបទទាំង ៣ នេះបាន អាស្រ័យហេតុដូចបានពោលមកនេះ ក្នុងបឋមបទដែល

ហៅថា មគ្គចិត្តុប្បាទដ៏សេស ២៨ ក្តី ផលចិត្តុប្បាទ ៣៦ ក្តី គឺ វៀរវេទនាចេតសិក នោះឯង ។

# អធិប្បាយតិកវិមុត្ត

ពាក្យថា **តិកវិមុត្ត** ប្រែថា ផុតចាកតិកៈ មានសេចក្តីថា អង្គធម៌ទាំងនោះ មិនបាននៅក្នុងបទទី ១ ទី ២ ឬទី ៣ ដូច្នោះ សុខវេទនាចេតសិក ៦៣ ដែលប្រកប ជាមួយសុខសហគតចិត្ត ៦៣, ទុក្ខវេទនាចេតសិក ៣ ដែលប្រកបជាមួយទុក្ខសហ-គតចិត្ត ៣, និងឧបេក្ខាវេទនាចេតសិក ៥៥ ដែលប្រកបជាមួយឧបេក្ខាសហគតចិត្ត ៥៥ ទើបជាតិកវិមុត្ត បំណែកឯ រូប ២៨ និងនិព្វាននោះ ជាតិកវិមុត្តស្រេចហើយ។

# ចប់ វេទនាត្តិកៈ

# ៣. វិបាកត្តិកៈ

បឋមបទ. **វិបាកា ធម្មា** ពួកធម៌ជាវិបាក បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ ។

ទុតិយបទ. **វិបាកធម្មធម្មា** ពួកធម៌មានវិបាកជាប្រក្រតី បានដល់ អកុសល-ចិត្ត ១២ កុសលចិត្ត ២១ ចេតសិក ៥២ ។

តតិយបទ. **នេវវិបាកនវិបាកធម្មធម្មា** ពួកធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី បានដល់ កិរិយាចិត្ត ២០ ចេតសិក ៣៥ រូប ២៨ និព្វាន ។

# អធិប្បាយវិបាកត្តិកៈ

វចនត្ថៈរបស់ពាក្យថា វិបាក ៖

**អញ្ញមញ្ញវិសិដ្ឋានំ កុសលាកុសលានំ បាកាតិ វិបាកា** ធម៌ទាំងឡាយជាផលរបស់កុសល និងអកុសលដែលពិសេសជាងគ្នានឹងគ្នា ឈ្មោះថា វិបាក ។

ពាក្យថា **ពិសេសជាងគ្នានឹងគ្នានោះ** បានដល់ ឱ្យផលមិនដូចគ្នានុ៎ះឯង ពោលគឺ កុសលឱ្យផលជាសុខ, អកុសលឱ្យផលជាទុក្ខ ។

## ផលមាន ២ ប្រការ

១. **មុខ្យផល** ជាផលដោយត្រង់ បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ ។

២. **សាមញ្ញផល** ជាផលដោយសាមញ្ញ គឺ ដោយអម បានដល់ កម្មជរូប ២០ ។

ក្នុងបឋមបទ ពាក្យថា **វិបាក**នោះ សំដៅយកមុខ្យផលដោយត្រង់ បានដល់ វិបាក-ចិត្ត ៣៦ ចេតសិក ៣៨, សម្រាប់សាមញ្ញផលនោះ បានដល់ កម្មជរូបប៉ុណ្ណោះ សូម្បី

ជាផលដែលកើតពីកុសលនិងអកុសលក៏ពិតមែន តែមិនឈ្មោះថា វិបាក ហៅបាន ត្រឹមតែជាផលរបស់កម្មប៉ុណ្ណោះ ។

កម្មជរូបដែលជាផលរបស់កុសល និងអកុសលនេះ មិនឈ្មោះថា វិបាក ព្រោះ ធម៌ដែលជាហេតុ (គឺ ចេតនាជានាមធម៌ ផលត្រូវតែជានាមធម៌ដូចគ្នានឹងហេតុ) បានដល់ កុសល និងអកុសលនោះ ជានាមធម៌ និងជាសារម្មណធម៌ (គឺ ដឹងអារម្មណ៍) បំណែកឯ ធម៌ដែលជាផល បានដល់ កម្មជរូប ជារូបធម៌ និងជាអនារម្មណធម៌ (គឺ មិនដឹងអារម្មណ៍) មិនដូចគ្នានឹងហេតុរបស់ខ្លួន ដូច្នោះហើយ ទើបមិនបានឈ្មោះថា វិបាក ។

សម្រាប់វិបាកចិត្ត និងចេតសិក ដែលជាផលរបស់កុសល និងអកុសលនោះ ជានាមធម៌ និងជាសារម្មណធម៌ដូចគ្នា ទើបហៅថា វិបាកបាន ។

ឧបមាដូចជា ការព្រោះគ្រាប់ស្រូវក្នុងស្រែ ខណៈដែលគ្រាប់ស្រូវដុះឡើងមក ជាដើម និងស្លឹកនោះៗ កើតឡើងមកពីគ្រាប់ស្រូវដែលព្រោះចុះទៅនោះក៏ពិតមែន តែមិនទាន់ឈ្មោះថា បានផលដែរ ព្រោះសភាពដែលប្រាកដនោះមិនទាន់ដូចគ្នា (គឺ គ្រាប់ស្រូវដូចគ្នា) នៅពេលដើមស្រូវនោះបេញកួរមានគ្រាប់ស្រូវហើយ នេះឯងទើប ហៅថា បានផលហើយ ព្រោះមានសភាពដូចគ្នា ។

ព្រោះហេតុនោះ ពាក្យថា **វិបាក** បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ នុ៎ះ ឯង សមដូចព្រះអដ្ឋកថាចារ្យពោលទុកថា **វិបក្កភាវមាបន្នានំ អរូបធម្មានមេតំ អធិវចនំ** ប្រែថា ពាក្យថាវិបាកនេះ ជាឈ្មោះរបស់នាមធម៌ ដែលជាផលដ៏ឆ្អិន [១] ។ ពាក្យថា **ជាផលដ៏ឆ្អិននេះ** ជាឈ្មោះទៅតាមសេចក្ដីពិតនៃហេតុរបស់ខ្លួន ។

---

[១] អដ្ឋសាលិនី ។

<u>អធិប្បាយបទថា ធម្មធម្មា ក្នុងទុតិយបទដូចតទៅ៖</u>

ពាក្យថា **ធម្មសត្ថ** ដែលតាំងនៅខាងដើមនោះ ប្រែថាធម៌ដែលទ្រទ្រង់ទុក គឺធម៌ដែលជាហេតុ កាលបើរួមជាមួយគ្នានឹងពាក្យថាវិបាកហើយ ប្រែថាធម៌ដែលទ្រទ្រង់ទុក ឬ ធម៌ដែលជាហេតុឱ្យវិបាកកើតឡើងនុ៎ះឯង មានវិបនត្ថៈថា **វិបាកំ ធារេតីតិ វិបាកធម្មោ** ធម៌ឯណាទ្រទ្រង់នូវវិបាក គឺជាហេតុឱ្យវិបាកកើតឡើង ព្រោះហេតុនោះ ធម៌នោះឈ្មោះថា វិបាក បានដល់ ធម៌ដែលជាហេតុធ្វើឱ្យវិបាកកើតឡើងនុ៎ះឯង ។

បំណែកឯ បទថា **ធម្មា** ខាងចុងនោះ ប្រែថា សភាវៈមិនមែនសត្វ មិនមែនជីវៈ សមដូចព្រះអដ្ឋកថាចារ្យសម្តែងទុកថា **សភាយមិធាបិ និស្សត្តនិជ្ជីវតាយមេវ វត្តតិ** (១) ។ ព្រោះហេតុនោះ ពាក្យថា **ធម្មា** ក្នុងទីនេះ សំដៅយកក្នុងសេចក្តីថា មិនមែនសត្វ មិនមែនជីវៈប៉ុណ្ណោះ ។

សម្រាប់តតិយបទនោះ ព្រះពុទ្ធអង្គទ្រង់សម្តែង ក្នុងឋានៈជាបទបដិសេធទាំងបឋមបទ និងទុតិយបទនុ៎ះឯង ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** ព្រោះអាស្រ័យពាក្យថា **វិបាក** ដែលតាំងនៅក្នុងបទដំបូងជាហេតុនៃការតាំងឈ្មោះ និងឈ្មោះថា **និប្បទេសត្តិកៈ** ព្រោះសម្តែងបរមត្ថធម៌ទាំងអស់មិនមានសេសសល់ ។

## ចប់វិបាកត្តិកៈ

---

(១) អដ្ឋសាលិនី ។

# ៤. ឧបាទិន្នត្តិកៈ

បឋមបទ. **ឧបាទិន្នុបាទានិយា ធម្មា** ពួកធម៌ដែលមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ [១] (គឺ កម្មដែលត្រូវតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយសភាពជាផលរបស់ខ្លួន) ទាំងជាប្រយោជន៍ដល់ឧបាទាន [២] (គឺ ជាអារម្មណ៍របស់ឧបាទាន) បានដល់ លោកិយវិបាកចិត្ត ៣២, ចេតសិក ៣៨, កម្មជរូប ២០ (ឬកម្មដែលត្រូវតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយអាការៈធ្វើឱ្យជាអារម្មណ៍) ។

ទុតិយបទ. **អនុបាទិន្នុបាទានិយា ធម្មា** ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ (គឺមិនមែនជាផលរបស់កម្មដែលប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យក) តែជាប្រយោជន៍ដល់-

---

[១] ពាក្យថា ឧបាទិន្ន មានវិបគ្គហៈថា **អារម្មណករណវសេន តណ្ហាទិដ្ឋីហិ ឧបេតេន កម្មុនា អាទិន្នា, ផលភាវេន គហិតាតិ ឧបាទិន្នា** ប្រែថា ឈ្មោះ ឧបាទិន្នព្រោះមានអត្ថថា ធម៌ទាំងឡាយដែលកម្មមានតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ គឺ កាន់យកដោយសភាពជាផល (របស់ខ្លួន) ។

[២] ពាក្យថា ឧបាទានិយៈ មានវិបគ្គហៈថា **អារម្មណភាវំ ឧបគន្ត្វា ឧបាទានសម្ពន្ធេន ឧបាទានានំ ហិតាតិ ឧបាទានិយា** ប្រែថា ឈ្មោះថា ឧបាទានិយៈ ព្រោះមានអត្ថថា ជាប្រយោជន៍ដល់ឧបាទាន ព្រោះជាប់ទាក់ទងជាមួយនឹងឧបាទាន ដោយចូលទៅកាន់យក គឺ ធ្វើឲ្យជាអារម្មណ៍ ។ ព្រោះហេតុនោះ ពាក្យនេះ ជាឈ្មោះនៃសភាវធម៌ដែលជាអារម្មណ៍របស់ឧបាទាន ។

ឧបាទាន (១) (គឺជាអារម្មណ៍របស់ឧបាទានបាន) បានដល់ អកុសលចិត្ត ១២, លោកិយកុសលចិត្ត ១៧, កិរិយាចិត្ត ២០, ចេតសិក ៥២, ចិត្តជរូប ១៧, ឧតុជរូប ១៥, អាហារជរូប ១៤, ឬហៅថាតិជរូប ១៧ ក៏បាន ។

តតិយបទ. **អនុបាទិន្នានុបាទានិយា ធម្មា** ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ (គឺមិនមែនជាផលរបស់កម្មដែលមានតណ្ហានិងទិដ្ឋិចូលទៅកាន់យក) ទាំងមិនជាប្រយោជន៍ដល់ឧបាទាន (គឺមិនជាអារម្មណ៍របស់ឧបាទាន) បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និព្វាន ។

# អធិប្បាយឧបាទិន្នត្តិកៈ

## បឋមបទ

គប្បីជ្រាបបទថា **ឧបាទិន្នុបាទានិយា ធម្មា** ជួបតទៅមាន ៣ បទគឺ **ឧបាទិន្ន + ឧបាទានិយៈ + ធម្មា** ។

ពាក្យថា **ឧបាទិន្ន** ប្រែថា កម្មដែលត្រូវតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយអាការៈធ្វើឱ្យជាអារម្មណ៍ ហើយកាន់យកដោយសភាពជាផលរបស់ខ្លួន ឬ ប្រែមួយន័យទៀតថា ធម៌ដែលជាផលរបស់លោកិយកម្មនុ៎ះឯង មានវចនត្ថៈថា **ឧបេតេន កម្មុនា អាទិន្នា ឧបាទិន្នា** (២) កម្មដែលត្រូវតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយអាការ

---

(១) អធិប្បាយថា ធម៌ដែលមិនមែនជាផលរបស់កម្មមានកុសលជាដើម តែជាអារម្មណ៍របស់ឧបាទានបាន ។

(២) អដ្ឋសាលិនី ។

ធ្វើឱ្យជាអារម្មណ៍កាន់យកដោយសភាពជាផលរបស់ខ្លួន ឈ្មោះថា ឧបាទិន្ន បានដល់ លោកិយវិបាកចិត្ត ៣២, ចេតសិក ៣៥, កម្មជរូប ២០ ។

ពាក្យថា **ឧបាទានិយៈ** ប្រែថា ធម៌ដែលជាប្រយោជន៍ដល់ឧបាទាន គឺ ជាអារម្មណ៍របស់ឧបាទានបានដល់ លោកិយចិត្ត ៨១, ចេតសិក ៥២, រូប ២៨ ។

ពាក្យថា **ធម្មា** ប្រែថា ធម៌ទាំងឡាយមិនមែនសត្វមិនមែនជីវៈ បានដល់ បរមត្ថធម៌ ៤ ទាំងអស់, អង្គធម៌របស់បឋមបទនេះ បានដល់ លោកិយវិបាកចិត្ត ៣២ ចេតសិក ៣៥ កម្មជរូប ២០ ប៉ុណ្ណោះ ព្រោះអង្គធម៌ដែលសំដៅយកក្នុងបឋមបទនេះប្រកបដោយអង្គ ២ គឺ ធម៌ដែលជា**ឧបាទិន្ន**ផង ជា**ឧបាទានិយ**ផង ដូច្នោះហើយ អង្គធម៌បានត្រឹមតែលោកិយវិបាកចិត្ត ៣២, ចេតសិក ៣៥ និងកម្មជរូប ២០ ប៉ុណ្ណោះ ។

ពាក្យនេះ ជាឈ្មោះនៃរូបធម៌ (កម្មជរូប) និងនាមធម៌ (លោកិយវិបាក) ដែលកើតអំពីកម្ម ហើយជាអារម្មណ៍របស់អាសវៈបានទៀត ។

# ទុតិយបទ

គប្បីជ្រាបបទថា **អនុបាទិន្នុបាទានិយា ធម្មា** តទៅមាន ៣ បទ គឺ **អនុបាទិន្ន + ឧបាទានិយៈ + ធម្មា** ។

ពាក្យថា **អនុបាទិន្ន** ប្រែថា ធម៌ដែលកម្មមានតណ្ហានិងទិដ្ឋិចូលទៅកាន់យកដោយអាការធ្វើឱ្យជាអារម្មណ៍មិនបាន ហើយកាន់យកដោយសភាពជាផល (របស់ខ្លួន) ឬ ប្រែមួយន័យទៀតថា ធម៌ដែលមិនមែនជាផលរបស់លោកិយកម្មនុ៎ះឯងមានវិចនត្ថៈថា **ឧបេតេហិ នាទិន្នំ អនុបាទិន្នំ** ប្រែថា ធម៌ដែលកម្ម មានតណ្ហា និងទិដ្ឋិចូលទៅកាន់យកដោយអាការៈធ្វើឱ្យជាអារម្មណ៍, មិនបានកាន់យកដោយសភាពជាផលរបស់ខ្លួន, ឈ្មោះថា អនុបាទិន្ន បានដល់ អកុសលចិត្ត ១២, កុសលចិត្ត ២១,

កិរិយាចិត្ត ២០, ផលចិត្ត ៤, ចេតសិក ៥២, ចិត្តជរូប ១៧, ឧតុជរូប ១៥, អាហារជរូប ១៤, និព្វាន ។

ពាក្យថា **ឧបាទានិយៈ** និង **ធម្មា** នោះ ពាក្យប្រែ និងអង្គធម៌ដូចគ្នានឹងបឋមបទនុ៎ះឯង ។

អង្គធម៌របស់ទុតិយបទ បានដល់ អកុសលចិត្ត១២, លោកិយកុសលចិត្ត ១៧, កិរិយាចិត្ត ២០, ចេតសិក ៥២, ចិត្តជរូប ១៧, ឧតុជរូប ១៥, អាហារជរូប ១៤ ព្រោះអង្គធម៌ដែលសំដៅយកក្នុងទុតិយបទនេះ ប្រកបដោយអង្គ ២ គឺ ធម៌ដែលជា**អនុបាទិន្ន** ផង ជា**ឧបាទានិយៈ**ផង ព្រោះហេតុនោះ អង្គធម៌បានត្រឹមតែអកុសលចិត្ត ១២, លោកិយកុសលចិត្ត ១៧, កិរិយាចិត្ត ២០, ចេតសិក ៥២, ចិត្តជរូប ១៧, ឧតុជរូប ១៥, អាហារជរូប ១៤ ប៉ុណ្ណោះ ។

## តតិយបទ

គប្បីជ្រាបបទថា **អនុបាទិន្នានុបាទានិយា ធម្មា**តទៅ មាន ៣ បទ គឺ **អនុបាទិន្ន + អនុបាទានិយ + ធម្មា** ។

ពាក្យថា **អនុបាទិន្ន** និង **ធម្មា** ពាក្យប្រែ និងអង្គធម៌ដូចគ្នានឹងទុតិយបទនុ៎ះឯង ។

ពាក្យថា **អនុបាទានិយៈ** ប្រែថា មិនជាប្រយោជន៍ដល់ឧបាទាន គឺ មិនជាអារម្មណ៍របស់ឧបាទាន បានដល់ លោកុត្តរចិត្ត ៨, ចេតសិក ៣៦, និព្វាន ។

សូម្បីឧបាទានក្ខន្ធរបស់ព្រះអរហន្ត ដល់ភាពជាបច្ច័យ គឺ ជាអារម្មណ៍ឱ្យឧបាទានដល់ជនដទៃបាន ក៏ពិតមែន តែលោកុត្តរចិត្ត និងព្រះនិព្វាននេះ មិនជា

អារម្មណាប្បច្ច័យឱ្យឧបាទានបានឡើយ ដូចជាដុំភ្លើងដែលសត្វរុយមិនអាចតោងយកបានក៏ដូច្នោះឯង⁽១⁾ ។

អង្គធម៌របស់តតិយបទ បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និព្វាន ព្រោះសភាវធម៌ដែលសំដៅយកក្នុងតតិយបទនេះ ប្រកបដោយអង្គ ២ គឺ ធម៌ដែលជា **អនុបាទិន្ន**ផង ជា**អនុបាទានិយៈ**ផង ដូច្នោះហើយ អង្គធម៌ទើបបានត្រឹមតែលោកុត្តរចិត្ត ៨, ចេតសិក ៣៦, និព្វានប៉ុណ្ណោះ ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និងឈ្មោះថា **និប្បទេសត្តិកៈ** ។

## ចប់ ឧបាទិន្នត្តិកៈ

⁽១⁾ មោហវិច្ឆេទនី ។

# ៩. សង្កិលិដ្ឋត្តិកៈ

បឋមបទ. **សង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌ដែលសៅហ្មង (គឺ កិលេសនិងធម៌ដែលសម្បយុត្តជាមួយកិលេស)ទាំងគួរដើម្បីដល់នូវសេចក្តីសៅហ្មង (គឺ ជាអារម្មណ៍របស់កិលេសបាន) បានដល់ អកុសលចិត្ត ១២ ចេតសិក ២៧ ។

ទុតិយបទ. **អសង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌ដែលមិនសៅហ្មង (គឺ កិលេសមិនចូលប្រកប) តែគួរដើម្បីដល់នូវសេចក្តីសៅហ្មង (គឺ ជាអារម្មណ៍របស់កិលេសបាន) បានដល់ លោកិយកុសលចិត្ត ១៧ លោកិយវិបាក ៣២ កិរិយា-ចិត្ត ២០ ចេតសិក ៥២ រូប ២៨ ។

តតិយបទ. **អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា** ពួកធម៌ដែលមិនសៅហ្មង (គឺ កិលេសមិនចូលប្រកប) ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង (គឺ មិនជាអារម្មណ៍របស់កិលេស)។ បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និងឈ្មោះថា **និប្បទេសត្តិកៈ** ។

# អធិប្បាយសង្កិលិដ្ឋត្តិកៈ

គប្បីជ្រាបបទថា **សង្កិលិដ្ឋសង្កិលេសិកា** តទៅ មាន ២ បទ គឺ **សង្កិលិដ្ឋ** និង **សង្កិលេ-សិកា** ។ ពាក្យថា **សង្កិលិដ្ឋ** ប្រែថា ធម៌ដែលប្រកបជាមួយគ្នានឹងកិលេស បានដល់ កិលេសទាំង ១០ ឬ សំដៅយកអកុសលចិត្ត ១២ ចេតសិក ២៧ ក៏មាន ព្រោះ កិលេសជាធម្មជាតិប្រកបជាមួយគ្នានឹងកិលេស ឬ កិលេសប្រកបជាមួយគ្នានឹង អកុសលចិត្តនុ៎ះឯង ព្រោះហេតុនោះ លោកទើបពោលទុកថា៖ **សង្កិលេសេន**

**សមន្នាគតាតិ សង្កិលិដ្ឋា** ឈ្មោះថា **សង្កិលិដ្ឋ** ព្រោះមានអត្ថថា ជាសភាវធម៌ដែលប្រកបជាមួយគ្នានឹងកិលេស ឬ កើតព្រមជាមួយគ្នានឹងកិលេស ។

ពាក្យថា **សង្កិលេស** ប្រែថា ធម៌ដែលមានសភាពបៀតបៀន និងមានសភាពធ្វើឱ្យក្តៅក្រហាយបានដល់ កិលេស ១០ ប្រការនុ៎ះឯង ព្រោះហេតុនោះ ទើបឈ្មោះថា **សង្កិលេស** ។

មានវិបនត្ថៈថា៖ **សង្កិលេសេតីតិ សង្កិលេសោ** ឈ្មោះថា **សង្កិលេស** ព្រោះមានអត្ថថា រមែងបៀតបៀន និងធ្វើឱ្យក្តៅក្រហាយ ក្នុងទីនេះ លោកសម្តែងកិលិសធាតុថា មានអត្ថ ២ យ៉ាង គឺ មានសភាពបៀតបៀន និងធ្វើឱ្យក្តៅក្រហាយ (១) ។

ពាក្យថា **សង្កិលេសិក** ប្រែថា ធម៌ដ៏សមគួរដល់កិលេស គឺ ជាអារម្មណ៍ឱ្យកិលេសបាន ឬ ធម៌ដែលប្រកបជាមួយគ្នានឹងកិលេស បានដល់ ជាអារម្មណប្បច្ច័យឱ្យកិលេសនុ៎ះឯង ។

មានវិបនត្ថៈថា៖ **អត្តានំ អារម្មណំ កត្វា បវត្តនេន សង្កិលេសំ អរហន្តីតិ សង្កិលេសិកា** ឈ្មោះថា សង្កិលេសិកៈ ព្រោះមានអត្ថថា ធម៌ដ៏សមគួរដល់សង្កិលេសិកៈ ដោយការប្រព្រឹត្តិទៅធ្វើខ្លួនឱ្យជាអារម្មណ៍ ។

មួយវិញទៀត មានវិបនត្ថៈថា ៖ **សង្កិលេសេ និយុត្តា តស្ស អារម្មណភាវានតិក្កមនតោតិ សង្កិលេសិកា** ឈ្មោះថា សង្កិលេសិក ព្រោះមានអត្ថថា ធម៌ដែលប្រកបក្នុងសង្កិលេស ព្រោះប្រព្រឹត្តទៅដោយមិនកន្លងអារម្មណ៍របស់សង្កិលេស

---

(១) អដ្ឋសាលិនីសម្តែងថា **វិពាធតិ ឧបតាបេតិ ចាតិ អត្ថោ** ប្រែថា កិលិសធាតុ ប្រព្រឹត្តទៅក្នុងអត្ថ ២ យ៉ាង គឺ **វិពាធតិ** បៀតបៀន និង **ឧបតាបេតិ** ធ្វើឲ្យក្តៅក្រហាយ ។

នោះ បានដល់ លោកិយចិត្ត ៨១ ចេតសិក ៥២ រូប ២៨ ។ ពាក្យនោះ ជាឈ្មោះនៃលោកិយធម៌ដែលជាអារម្មណ៍នៃកិលេសទាំងឡាយ (១) ។

# ចប់ សង្កិលិដ្ឋត្តិកៈ

(១) អដ្ឋសាលិនីសម្ដែងថា **សង្កិលេសស្ស អារម្មណប្បច្ចយភូតានមេតំ អធិវចនំ** ប្រែថា ពាក្យនោះជាឈ្មោះរបស់លោកិយធម៌ដែលជាអារម្មណ៍របស់កិលេស ។

# ៦. សវិតក្កត្តិកៈ

បឋមបទ. **សវិតក្កសវិចារា ធម្មា** ពួកធម៌ដែលប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈ បានដល់ សវិតក្កសវិចារចិត្ត ៥៥ គឺ កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) បឋមជ្ឈានចិត្ត ១១ ចេតសិក ៥០ (វៀរវិតក្កៈ និងវិចារៈ) ។
ទុតិយបទ. **អវិតក្កវិចារមត្តា ធម្មា** ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ បានដល់ ទុតិយជ្ឈានចិត្ត ១១ ចេតសិក ៣៦ (វៀរវិចារៈ) និងវិតក្កចេតសិក ៥៥ ក្នុងសវិតក្កសវិចារចិត្ត ៥៥ ។
តតិយបទ. **អវិតក្កាវិចារា ធម្មា** ពួកធម៌គ្មានវិតក្កៈទាំងគ្មានវិចារៈ បាន-ដល់ អវិតក្កាវិចារចិត្ត ៥៥ គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈាន-ចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ ចេតសិក ៣៦ និងវិចារចេតសិក ១១ ក្នុងទុតិយជ្ឈានចិត្ត ១១ រូប ២៨ និព្វាន ។

## អធិប្បាយសវិតក្កត្តិកៈ

គប្បីជ្រាបបទថា **សវិតក្កសវិចារៈ**ដូចតទៅ មាន ២ បទ គឺ **សវិតក្កៈ + សវិចារៈ** ។

ពាក្យថា **សវិតក្កៈ** ប្រែថា ធម៌ដែលកើតព្រមជាមួយគ្នានឹងវិតក្កៈ ដោយអំណាចនៃការប្រកបមានវិបនត្ថៈថា ៖ **សម្បយោគវសេន វត្តមានេន សហ វិតក្កេន សវិតក្កា** ប្រែថា ធម៌ទាំងឡាយដែលកើតព្រមជាមួយគ្នានឹងវិតក្កៈ គឺ ប្រព្រឹត្តទៅដោយអំណាចនៃការប្រកប ឈ្មោះថា **សវិតក្កៈ** បានដល់កាមចិត្ត ៤៤ (វៀរទ្វិបញ្ច-វិញ្ញាណចិត្ត ១០), បឋមជ្ឈានចិត្ត ១១, ចេតសិក ៥១, (វៀរវិតក្កៈ) ។

ពាក្យថា **សវិចារៈ** ប្រែថា ធម៌ដែលកើតព្រមជាមួយគ្នានឹងវិចារៈ ដោយអំណាចនៃការប្រកប មានវិបនត្ថៈថា ៖ **សម្បយោគវសេន វត្តមានេន សហ វិចារេន សវិចារា** ប្រែថា ធម៌ទាំងឡាយដែលកើតព្រមជាមួយគ្នានឹងវិចារៈ គឺ ប្រព្រឹត្តទៅ

ដោយអំណាចនៃការប្រកប ឈ្មោះថា **សវិចារៈ** បានដល់ កាមចិត្ត ៤៤ (វៀរទ្វិបញ្ច-វិញ្ញាណចិត្ត ១០), បឋមជ្ឈានចិត្ត ១១, ទុតិយជ្ឈានចិត្ត ១១, ចេតសិក ៥១, (វៀរវិចារៈ) ។

ពាក្យថា **សវិតក្កសវិចារា** ប្រែថា ពួកធម៌ប្រកបដោយវិតក្កៈផង ប្រកបដោយវិចារៈផង (គឺ ធម៌ទាំងប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ) មានវិបគ្គៈថា ៖ **សវិតក្កា ច តេ សវិចារា ចាតិ សវិតក្កសវិចារា** ឈ្មោះថា **សវិតក្កសវិចារៈ** ព្រោះមានអត្ថថា គឺ ធម៌ដែលប្រកបដោយវិតក្កៈ និងប្រកបដោយវិចារៈ បានដល់ កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) បឋមជ្ឈានចិត្ត ១១ ចេតសិក ៥០ (វិតក្កៈវិចារៈ) ។

ក្នុងបទថា **សវិតក្កសវិចារៈ**នេះ លោកសំដៅយកធម៌ដែលប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈ បានទាំង ២ បទប៉ុណ្ណោះ មិនបានរាប់យកវិតក្កៈ និងវិចារៈផងទេ ។

ពាក្យថា **វិចារមត្តា** ប្រែថា ពួកធម៌មានត្រឹមតែវិចារៈ គឺ ជាធម៌មិនប្រកបដោយវិតក្កៈ ។

វិបគ្គៈរបស់ <u>**វិចារមត្តា**</u> ៖ **វិតក្កវិចារេសុ វិចារោវ មត្តា បមាណំ ឯតេសន្តិ វិចារមត្តា** ប្រែថា បណ្ដាវិតក្កៈ និងវិចារៈ ២ ដួងនោះ វិចារចេតសិក ១ ដួងប៉ុណ្ណោះ ជាប្រមាណដល់ធម៌ពួកនោះ ព្រោះហេតុនោះ ធម៌ពួកនេះឈ្មោះថា **វិចារមត្តា** បានដល់ ទុតិយជ្ឈានចិត្ត ១១ ចេតសិក ៣៦ (វៀរវិចារៈ) និងវិតក្កៈចេតសិក ៥៥ ដែលប្រកបក្នុងសវិតក្កចិត្ត ៥៥ ។

អធិប្បាយថា **វិចារមត្តានេះ** លោកសំដៅយកធម៌ដែលប្រកបដោយវិចារ ១ ដួង មិនបានយកធម៌ដែលប្រកបដោយវិតក្កឡើយ ព្រោះហេតុនោះ ក្នុងសវិចារ

ចិត្ត ៦៦ នេះ វៀរកាមចិត្ត ៥៥ បឋមជ្ឈានចិត្ត ១១ និងចំនួនចេតសិកដែលប្រកបក្នុងទុតិយជ្ឈានចិត្ត ១១ ដួង ក៏ត្រូវវៀរវិចារចេតសិកផងដែរ ។

បំណែកឯ **វិតក្កចេតសិក ៥៥** នោះ កាលកើតឡើងក្នុងចិត្ត ១ ដួងៗ ក៏មានតែវិតក្កចេតសិក ១ ដួង មិនមានវិតក្កចេតសិកដទៃៗប្រកបផងឡើយ មានត្រឹមតែវិចារចេតសិកប្រកបប៉ុណ្ណោះ ដូច្នោះហើយ ទើបឈ្មោះថា **វិចារមត្តា** គឺ មានត្រឹមតែវិចារៈ ។

វិបនត្ថៈរបស់**<u>អវិតក្កៈ</u>** ៖ **វិតក្កតោ រហិតាតិ អវិតក្កា** ពួកធម៌ដែលប្រាសចាកវិតក្កៈ ឈ្មោះថា **អវិតក្កៈ** បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣, ចេតសិក ៣៧, និងវិតក្កចេតសិក ៥៥, រូប ២៨, និព្វាន ។

អធិប្បាយថា ឈ្មោះថា **អវិតក្កៈ**នោះ យកធម៌គ្មានវិតក្កៈទាំងអស់ គឺ មិនប្រកបដោយវិតក្កៈ ដូច្នោះហើយ វិតក្កចេតសិក ៥៥ ដែលកើតឡើងជាមួយចិត្តមួយដួងៗ ក៏មិនមានវិតក្កចេតសិកដទៃៗប្រកបឡើយ ព្រោះហេតុនោះ វិតក្កចេតសិក ៥៥ នេះ ទើបមានឈ្មោះថា អវិតក្កធម៌ សម្រាប់ទ្វិបញ្ចវិញ្ញាណចិត្ត ទុតិយជ្ឈានចិត្ត តតិយជ្ឈានចិត្ត ចតុត្ថជ្ឈានចិត្ត បញ្ចមជ្ឈានចិត្ត និងចេតសិក ៣៧ រូប និព្វាន ជា-**អវិតក្កធម៌**ពិតប្រាកដហើយ ។

វិបនត្ថៈរបស់**<u>អវិចារៈ</u>** ៖ **វិចារតោ រហិតាតិ អវិចារា** ពួកធម៌ដែលប្រាសចាកវិចារៈ ឈ្មោះថា **អវិចារៈ** បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈានចិត្ត ២៣ ចេតសិក ៣៦ និងវិចារចេតសិក ៦៦ រូប ២៨ និព្វាន ។

អធិប្បាយថា ឈ្មោះថា **អវិចារៈ**នោះ យកធម៌គ្មានវិចារៈទាំងអស់ គឺ មិនប្រកបដោយវិចារៈ ដូច្នោះហើយ វិចារចេតសិក ៦៦ ដែលកើតឡើងជាមួយចិត្តមួយ ដួងៗ ក៏មិនមានវិចារចេតសិកដទៃៗ ប្រកបឡើយ ព្រោះហេតុនោះ វិចារចេតសិក ៦៦ នេះ ទើបមានឈ្មោះថា **អវិចារធម៌** ។

វិបឝត្ថៈរបស់**<u>អវិតក្កវិចារៈ</u>** ៖ **អវិតក្កា ច តេ អវិចារា ចាតិ អវិតក្កា-វិចារា** ឈ្មោះថា **អវិតក្កាវិចារៈ** ព្រោះមានអត្ថថា ជាធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១ បញ្ចមជ្ឈាន-ចិត្ត ២៣ ចេតសិក ៣៦ និងវិចារចេតសិក ១១ ក្នុងទុតិយជ្ឈានចិត្ត ១១ រូប ២៨ និព្វាន ។

អធិប្បាយថា ឈ្មោះថា **អវិតក្កាវិចារៈ**នោះ យកធម៌ដែលមិនប្រកបដោយ វិតក្កៈ និងវិចារៈទាំង ២ គឺ វិតក្កចេតសិក ៥៥ មិនមានវិតក្កចេតសិកប្រកបក៏ពិត មែន តែមានវិចារចេតសិកប្រកប ហៅថា **អវិតក្កសវិចារៈ** ទើបមិនបានរាប់យក គឺ មិនកាន់យកក្នុងបទនេះ ។

វិចារចេតសិក ៥៥ ដែលប្រកបជាមួយនឹងសវិតក្កចិត្ត ៥៥ ទោះបីមិនមាន វិចារចេតសិកប្រកប តែមានវិតក្កចេតសិកប្រកប ហៅថា **អវិចារសវិតក្កៈ** គឺរាប់ បញ្ចូលក្នុងតិកនេះមិនបាន ។

បំណែកឯវិចារចេតសិក ១១ ដែលប្រកបជាមួយទុតិយជ្ឈានចិត្ត ១១ គ្មាន វិតក្កៈ ទាំងគ្មានវិចារៈ គឺ ជា**អវិតក្កាវិចារធម៌** ។

**<u>អង្គធម៌របស់បឋមបទ</u>** បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈ ហើយ បានខន្ធ ៤, អាយតនៈ ២, ធាតុ ៣, សច្ចៈ ៣ ។

**សច្ចៈ ៣ គឺ** លោកិយសវិតក្កសវិចារចិត្ត ៤៧ ចេតសិក ៤៩ (វៀរលោភៈ) ជាទុក្ខសច្ចៈ, លោភចេតសិក ជាសមុទយសច្ចៈ, អង្គមគ្គ ៧ (វៀរសម្មាសង្កប្បៈ) ក្នុងមគ្គសវិតក្កសវិចារចិត្ត ៤ ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៨ ផលចិត្តុប្បាទ ៣៥ ជាសច្ចវិមុត្ត ។

<u>**អង្គធម៌របស់ទុតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈបានខន្ធ ៤, អាយតនៈ ២, ធាតុ ២, សច្ចៈ ២ ។

**សច្ចៈ ២ គឺ** លោកិយទុតិយជ្ឈានចិត្ត ៣ ចេតសិក ៣៣ និងលោកិយវិតក្កចេតសិក ៤៧ ជាទុក្ខសច្ចៈ, អង្គមគ្គ ៧ (វៀរសម្មាសង្កប្បៈ) ក្នុងទុតិយជ្ឈានមគ្គចិត្ត ៤ និងសម្មាសង្កប្បមគ្គ គឺ វិតក្កចេតសិក ៤ ក្នុងបឋមជ្ឈានមគ្គចិត្ត ៤ ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៨ ផលចិត្តុប្បាទ ៣៥ និងវិតក្កចេតសិក ៤ ក្នុងបឋមជ្ឈានផលចិត្ត ៤ ជាសច្ចៈវិមុត្ត ។

<u>**អង្គធម៌របស់តតិយបទ**</u> បើចែកដោយខន្ធ អាយតនៈ ធាតុ សច្ចៈហើយបានខន្ធ ៥, អាយតនៈ ១២, ធាតុ ១៧, សច្ចៈ ៣ ។

**សច្ចៈ ៣ គឺ** លោកិយអវិតក្កាវិចារចិត្ត ៣១ ចេតសិក ៣៣ និងលោកិយវិចារចេតសិក ៣ រូប ២៨ ជាទុក្ខសច្ចៈ, និព្វាន ជានិរោធសច្ចៈ, អង្គមគ្គ ៧ (វៀរសម្មាសង្កប្បៈ) ក្នុងមគ្គអវិតក្កាវិចារចិត្ត ១២ ជាមគ្គសច្ចៈ, មគ្គចិត្តុប្បាទដ៏សេស ២៨ ផលចិត្តុប្បាទ ៣៥ និងវិចារចេតសិក ៨ ក្នុងលោកុត្តរទុតិយជ្ឈានចិត្ត ៨ ជាសច្ចវិមុត្ត ។ វិចារចេតសិក ៥៥ ក្នុងសវិតក្កសវិចារចិត្ត ៥៥ មិនបានចូលក្នុងបឋមបទ ទុតិយបទ និងតតិយបទ ទើបជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និងឈ្មោះថា **សប្បទេសត្តិកៈ** ។

## ចប់ សវិតក្កត្តិកៈ

# ៧. បីតិត្តិកៈ

បឋមបទ. **បីតិសហគតា ធម្មា** ពួកធម៌ប្រកបដោយបីតិ បានដល់ បីតិសហគតចិត្ត ៥១ គឺ កាមសោមនស្សសហគតចិត្ត ១៨, បឋមជ្ឈានចិត្ត ១១, ទុតិយជ្ឈានចិត្ត ១១, តតិយជ្ឈានចិត្ត ១១, ចេតសិក ៤៦ (វៀរបីតិ) ។

ទុតិយបទ. **សុខសហគតា ធម្មា** ពួកធម៌ប្រកបដោយសុខ បានដល់ សុខសហគតចិត្ត ៦៣, ចេតសិក ៤៦ (វៀរវេទនា) ។

តតិយបទ. **ឧបេក្ខាសហគតា ធម្មា** ពួកធម៌ប្រកបដោយឧបេក្ខា បានដល់ ឧបេក្ខាសហគតចិត្ត ៥៥ ចេតសិក ៤៦ (វៀរវេទនា) ។

ទោសមូលចិត្ត ២ ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ ចេតសិក ២២ សុខវេទនាចេតសិក ១២ ក្នុងសុខសហគតកាយវិញ្ញាណចិត្ត ១ បញ្ចមជ្ឈានចិត្ត ១១ ឧបេក្ខាវេទនាចេតសិក ៥៥ ក្នុងឧបេក្ខាសហគតចិត្ត ៥៥ រូប ២៨ និព្វាន ជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សព្វទេសត្តិកៈ** ។

# អធិប្បាយបីតិត្តិកៈ

អធិប្បាយថា ទោសមូលចិត្ត ២ ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ រួម ៣ ដួងនេះ ហៅថាទុក្ខសហគតចិត្ត ៣, ចេតសិក ២២, ទុក្ខសហគតចិត្ត ៣ ដួងនេះ, ជាធម៌ប្រកបដោយទុក្ខវេទនា ទើបចាត់ចូលក្នុងបទទាំង ៣ មិនបាន ព្រោះបទទី ១ ជាធម៌ប្រកបដោយបីតិ, បទទី ២ ជាធម៌ប្រកបដោយសុខវេទនា, បទទី ៣ ជាធម៌ប្រកបដោយឧបេក្ខាវេទនា ។

ឧបេក្ខាវេទនាចេតសិក ៥៥ ក៏សង្គ្រោះចូលក្នុងបទទាំង ៣ មិនបាន គឺ ធម៌ដែលទ្រង់សម្តែងក្នុងបឋមបទនោះ ជាធម៌ប្រកបដោយបីតិ ទើបមិនអាចសង្គ្រោះចូលក្នុងបឋមបទបាន, ទុតិយបទនោះ ជាធម៌ប្រកបដោយសុខវេទនាប៉ុណ្ណោះ ឧបេក្ខាវេទនា ទើបសង្គ្រោះចូលក្នុងទុតិយបទមិនបាន, តតិយបទជាធម៌ប្រកបដោយឧបេក្ខាវេទនា ក្នុងបំនួនចេតសិកប្រកបដោយឧបេក្ខាសហគតចិត្ត ៥៥ នោះទើបវៀរឧបេក្ខាវេទនា ។

បំណែកឯសុខវេទនាចេតសិក ១២ គឺក្នុងសុខសហគតកាយវិញ្ញាណចិត្ត ១ និងក្នុងចតុត្ថជ្ឈានចិត្ត ១១ ជាតិកវិមុត្តនោះ ព្រោះសុខវេទនាទាំងនេះជានិប្បីតិកសុខ គឺ សុខមិនប្រកបដោយបីតិ ទើបចាត់ជាតិកវិមុត្តបាន ក្នុងបំនួនសុខវេទនាចេតសិក ៦៣ ដែលវៀរចាកទុតិយបទនោះ បើចែកហើយមាន ២ ប្រភេទ គឺ ៖

១. សប្បីតិកសុខវេទនា សុខវេទនាប្រកបដោយបីតិ មាន ៥១ ដួង ។

២. និប្បីតិកសុខវេទនា សុខវេទនាមិនប្រកបដោយបីតិ មាន ១២ ដួង រួមបាន ៦៣ ដួង ។

ក្នុង ២ ប្រភេទនេះ សប្បីតិកសុខវេទនា ៥១ សង្គ្រោះចូលក្នុងបឋមបទហើយ មិនចាត់ជាតិកវិមុត្ត បំណែក និប្បីតិកសុខវេទនាដ៏សេស ១២ ទៀត សង្គ្រោះចូលក្នុងបទទាំង ៣ មិនបាន ចាត់ជាតិកវិមុត្ត ។

ម្យ៉ាងទៀត បីតិចេតសិក ៥១ ដែលវៀរចាកបឋមបទនោះ សង្គ្រោះចូលក្នុងទុតិយបទហើយ ព្រោះបីតិទាំងនេះប្រកបដោយសុខវេទនា ទើបមិនជាតិកវិមុត្ត ។

## ចប់ បីតិត្តិកៈ

# ៨. ទស្សនត្តិកៈ

បឋមបទ. **ទស្សនេន បហាតព្វា ធម្មា** ពួកធម៌ដែលត្រូវលះដោយទស្សនៈ បានដល់ ទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង ចេតសិក ២២ ដោយសមុច្ឆេទប្បហានៈ ។

ឬម្យ៉ាងទៀត បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ទោសមូលចិត្ត ២ ដួង ចេតសិក ២៥ ដែលជាហេតុនាំទៅកាន់អបាយ ព្រះសោតាបន្នបុគ្គលលះបានដោយសមុច្ឆេទប្បហានៈ (១) ។

ទុតិយបទ. **ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ដែលត្រូវលះដោយភាវនា បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ទោសមូលចិត្ត ២ ចេតសិក ២៥ ដែលគ្រោតគ្រាត (ឱឡារិកៈ) <u>សកទាគាមិមគ្គ</u>គប្បីលះបានដោយអំណាចនៃការធ្វើឱ្យស្រាលស្តើង (តនុករប្បហានៈ) ។

---

(១) <u>តែតាមមតិរបស់ព្រះអាចារ្យសទ្ធម្មជោតិកៈ</u> ធម្មាចរិយៈ លោកសម្តែងថា ៖ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង, ទោសមូលចិត្ត ២ ដួង, ចេតសិក ២៥, ដែលជាហេតុនាំទៅកាន់អបាយ ព្រះសោតាបន្នបុគ្គល លះដោយតនុករប្បហានៈ <u>តែមិនប្រាកដក្នុងគម្ពីរណាឡើយ</u> ។ ពាក្យថា **តនុករប្បហានៈ**នេះ ព្រះសម្មាសម្ពុទ្ធ ព្រះអដ្ឋកថាចារ្យ និងព្រះដីកាចារ្យ លោកសម្តែងចំពោះតែព្រះសកទាគាមីប៉ុណ្ណោះ ដូចជាក្នុង<u>គម្ពីរវិសុទ្ធិមគ្គលោក</u>ពោលទុកថា **រាគ-ទោសមោហានំ តនុត្តា សកទាគាមី ហោតិ** ប្រែថា ព្រះសកទាគាមីបុគ្គលជាអ្នកធ្វើរាគៈ ទោសៈ និងមោហៈ ឲ្យស្រាលស្តើង ។ ឬ ក្នុងគម្ពីរអភិធម្មត្ថសង្គហៈ រចនាដោយព្រះអនុរុទ្ធាចារ្យ លោកសម្តែងចំពោះតែព្រះសកទាគាមី ទុកក្នុងបរិច្ឆេទទី ៩ គាថាទី ៦៩ ដូចគ្នាថា **សកទាគាមិមគ្គំ ភាវេត្វា រាគទោសមោហានំ តនុករត្តា សកទាគាមី នាម** ជាដើម ។

ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលជាប់ទាក់ទងនឹងកាមរាគៈ, ទោសមូលចិត្ត ២, ចេតសិក ២៥ <u>អនាគាមិមគ្គ</u>គប្បីលះបានដោយដាច់ខាត (សមុច្ឆេទប្បហានៈ)។

ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលជាប់ទាក់ទងនឹងរូបរាគៈ អរូបរាគៈ ឧទ្ធច្ចសម្បយុត្តចិត្ត ១ ចេតសិក ២១ <u>អរហត្តមគ្គ</u>គប្បីលះបានដោយដាច់ខាត (សមុច្ឆេទប្បហានៈ) ។

តតិយបទ. **នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ និងមិនត្រូវលះដោយភាវនា បានដល់ កុសលចិត្ត ២១ វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ រូប ២៨ និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ**។

# អធិប្បាយទស្សនត្តិកៈ

ពាក្យថា **ទស្សនេន** ប្រែថា សោតាបត្តិមគ្គបុគ្គល ពិតណាស់ សោតាបត្តិមគ្គឃើញព្រះនិព្វានជាលើកដំបូង (ធ្វើឱ្យជាអារម្មណ៍ និងប្រហារកិលេស)។

បំណែកឯ **គោត្រភូញាណ** បានឃើញព្រះនិព្វានមុនសោតាបត្តិមគ្គក៏ពិតមែន តែមិនឈ្មោះថា ទស្សនៈ ព្រោះមិនមានការប្រហារកិលេសដែលជាកិច្ចគប្បីធ្វើ (កិច្ចសំខាន់) ដូចជាបុរសដែលមកកាន់សំណាក់របស់ព្រះរាជាដោយកិច្ចណាមួយ បានឃើញព្រះរាជាប្រថាប់លើដំរីកំពុងគ្រាប់ទៅទីឆ្ងាយបើគេសួរថា <u>អ្នកបានគាល់ព្រះរាជាហើយឬនៅ</u> សូម្បីបានឃើញ ក៏ពោលថា មិនទាន់បានគាល់ឡើយ

ព្រោះមិនបានធ្វើកិច្ចដែលគប្បីធ្វើ ពិតណាស់ គោត្រភូញាណនោះ តាំងនៅក្នុងឋានៈនៃអាវជ្ជនចិត្តរបស់មគ្គ (១) ។

ពាក្យថា **ភាវនា** បានដល់ អរិយមគ្គ ៣ ដ៏សេស ព្រោះមគ្គទាំង ៣ ដ៏សេសនេះ កើតឡើងដោយភាវនា (គឺ ចម្រើនអរិយសច្ចៈ) ដែលបឋមមគ្គបានឃើញហើយនុ៎ះឯង មិនបានឃើញធម៌អ្វីៗដែលបឋមមគ្គមិនធ្លាប់បានឃើញឡើយ ព្រោះហេតុនោះ ទើបមានឈ្មោះថា ភាវនា (២) ។

តតិយបទនោះ ទ្រង់សម្ដែងដោយអំណាចនៃភាពជាបដិបក្ខចំពោះបទទាំង ២ ។

# សម្ដែងការលះអកុសលធម៌ដោយមគ្គទាំង ៤

១. ការលះអកុសលធម៌របស់សោតាបត្តិមគ្គបុគ្គល មាន ២ យ៉ាង គឺ ៖

**សមុច្ឆេទប្បហានៈ** លះបានដាច់ខាត បានដល់ ទិដ្ឋិគតសម្បយុត្តចិត្ត ៤ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ចេតសិក ២២ ។

---

(១) ទស្សនេនាតិ សោតាបត្តិមគ្គេន, សោ ហិ បឋមំ និព្វានំ ទស្សនតោ ទស្សនន្តិ វុត្តោ, គោត្រភុ បន កិញ្ចាបិ បឋមតរំ បស្សតិ ។ យថា បន រញ្ញោ សន្តិកំ កេនចិទេវ ករណីយេន អាគតោ បុរិសោ ទូរតោវ រថិកាយ ចរន្តំ ហត្ថិក្ខន្ធគតំ រាជានំ ទិស្វាបិ “ ទិដ្ឋោ តេ រាជាតិ បុដ្ឋោ ទិស្វាបិ កត្តព្វកិច្ចស្ស អកតត្តា “ ន បស្សាមីតិ អាហ ។ ឯវមេវ និព្វានំ ទិស្វាបិ កត្តព្វស្ស កិលេសប្បហានស្សាភាវា ន ទស្សនន្តិ វុច្ចតិ ។ តញ្ហិ ញាណំ មគ្គស្ស អាវជ្ជនដ្ឋានេ តិដ្ឋតិ ។

(២) ភាវនាយាតិ សេសមគ្គត្តយេន, សេសមគ្គត្តយញ្ហិ បឋមមគ្គេន ទិដ្ឋស្មឹយេវ ធម្មេ ភាវនាវសេន ឧប្បជ្ជតិ, អទិដ្ឋបុព្វំ កិញ្ចិ ន បស្សតិ, តស្មា ភាវនាតិ វុច្ចតិ ។

**តនុករប្បហានៈ** លះបានដោយធ្វើឱ្យស្រាលស្តើង បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ទោសមូលចិត្ត ២ ចេតសិក ២៥ ដែលនាំទៅកាន់អបាយ (អបាយគមនីយៈ) ⁽¹⁾ ។

២. ការលះអកុសលធម៌របស់<u>សកទាគាមិមគ្គបុគ្គល</u> មានតែធ្វើឱ្យស្រាលស្តើងប៉ុណ្ណោះ (តនុករប្បហានៈ) បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ទោសមូលចិត្ត ២ ចេតសិក ២៥ ដែលគ្រោតគ្រាត (ឱឡារិកៈ) ។

៣. ការលះអកុសលធម៌របស់<u>អនាគាមិមគ្គបុគ្គល</u> មានតែសមុច្ឆេទប្បហានៈ បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលទាក់ទងនឹងកាមរាគៈ និងទោសមូលចិត្ត ២ ចេតសិក ២៥ ។

៤.ការលះអកុសលធម៌របស់<u>អរហត្តមគ្គបុគ្គល</u> មានតែសមុច្ឆេទប្បហានៈ បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលទាក់ទងនឹងរូបរាគៈ អរូបរាគៈ និងឧទ្ធច្ចសម្បយុត្តចិត្ត ១ ចេតសិក ២១ ។

អ្នកសិក្សាគប្បីជ្រាបថា ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង មាន ៥ ប្រភេទ និង ទោសមូលចិត្ត ២ ដួង មាន ៣ ប្រភេទ ។

១. <u>ទិដ្ឋិគតវិប្បយុត្តចិត្ត ៤</u> មាន ៥ ប្រភេទ គឺ ៖

- ❖ ប្រភេទទី ១ ជាអបាយគមនីយៈដែលនាំទៅកាន់អបាយបាន ។
- ❖ ប្រភេទទី ២ ជាឱឡារិកៈ គឺ គ្រោតគ្រាតតែនាំទៅកាន់អបាយមិនបាន ។
- ❖ ប្រភេទទី ៣ ជាសុខុមៈ ដែលទាក់ទងនឹងកាមរាគៈ ។
- ❖ ប្រភេទទី ៤ ជាសុខុមៈ ដែលទាក់ទងនឹងរូបរាគៈ ។
- ❖ ប្រភេទទី ៥ ជាសុខុមៈ ដែលទាក់ទងនឹងអរូបរាគៈ ។

---

⁽¹⁾ សម្តែងតាមមតិរបស់ព្រះអាចារ្យសទ្ធម្មជោតិកៈ ធម្មាចរិយៈ ។

ក្នុង ៥ ប្រភេទនោះ ប្រភេទទី ១ លះដោយសោតាបត្តិមគ្គបុគ្គល, ប្រភេទទី ២ លះដោយសកទាគាមិមគ្គបុគ្គល, ប្រភេទទី ៣ លះដោយអនាគាមិមគ្គបុគ្គល, ប្រភេទទី ៤ និងទី ៥ លះដោយអរហត្តមគ្គបុគ្គល ។

២. ទោសមូលចិត្ត ២ មាន ៣ ប្រភេទ គឺ ៖

- ❖ ប្រភេទទី ១ ជាអបាយគមនីយៈ ។
- ❖ ប្រភេទទី ២ ជាឱឡារិកៈ ។
- ❖ ប្រភេទទី ៣ ជាសុខុមៈ ។

ក្នុង ៣ ប្រភេទនោះ ប្រភេទទី ១ លះដោយសោតាបត្តិមគ្គបុគ្គល, ប្រភេទទី ២ លះដោយសកទាគាមិមគ្គបុគ្គល, ប្រភេទទី ៣ លះដោយអនាគាមិមគ្គបុគ្គល ។

សរុបសេចក្ដីថា ទិដ្ឋិគតសម្បយុត្តចិត្ត ៤ វិចិកិច្ឆាសម្បយុត្តចិត្ត ១ លះដោយសោតាបត្តិមគ្គចិត្ត ១ ។

ឧទ្ធច្ចសម្បយុត្តចិត្ត ១ លះដោយអរហត្តមគ្គចិត្ត ។

ទោសមូលចិត្ត ២ លះដោយមគ្គចិត្តខាងក្រោម ៣ ។

ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ លះដោយមគ្គចិត្ត ទាំង ៤ ។

សម្រាប់ការលះកិលេស សំយោជនៈ នីវរណៈ ដោយមគ្គទាំង ៤ នោះ មានសម្ដែងទុកក្នុង **គម្ពីរអដ្ឋសាលិនី** គឺ ៖

# ការលះកិលេសដោយលំដាប់នៃមគ្គ

**មគ្គបដិបាដិយា សោតាបត្តិមគ្គេន ទិដ្ឋិវិចិកិច្ឆា បហីយន្តិ ។ អនាគាមិមគ្គេន ទោសោ បហីយតិ ។ អរហត្តមគ្គេន សេសា សត្ត បហីយន្តិ** ។ ទិដ្ឋិ វិចិកិច្ឆា លះ

ដោយសោតាបត្តិមគ្គចិត្ត ។ ទោសៈ លះដោយអនាគាមិមគ្គចិត្ត ។ កិលេសដ៏សេស ៧ មានលោភៈជាដើម លះដោយអរហត្តមគ្គចិត្ត ។

## ការលះសំយោជនៈដោយលំដាប់នៃកិលេស

**កិលេសបដិបាដិយា កាមរាគបដិឃសំយោជនានិ អនាគាមិមគ្គេន បហីយន្តិ, មានសំយោជនំ អរហត្តមគ្គេន, ទិដ្ឋិវិចិកិច្ឆាសីលព្វតបរាមាសា សោតាបត្តិមគ្គេន, ភវរាគសំយោជនំ អរហត្តមគ្គេន, ឥស្សាមច្ឆរិយានិ សោតាបត្តិមគ្គេន, អវិជ្ជា អរហត្តមគ្គេន ។**

កាមរាគសំយោជនៈ បដិឃសំយោជនៈ លះដោយអនាគាមិមគ្គចិត្ត, មានសំយោជនៈ លះដោយអរហត្តមគ្គចិត្ត, ទិដ្ឋិសំយោជនៈ វិចិកិច្ឆាសំយោជនៈ សីលព្វ-តបរាមាសសំយោជនៈ លះដោយសោតាបត្តិមគ្គចិត្ត, ភវរាគសំយោជនៈ លះដោយអរហត្តមគ្គចិត្ត,ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ លះដោយសោតាបត្តិមគ្គចិត្ត, អវិជ្ជាសំយោជនៈ លះដោយអរហត្តមគ្គចិត្ត ។

## ការលះសំយោជនៈដោយលំដាប់នៃមគ្គ

**ទិដ្ឋិវិចិកិច្ឆាសីលព្វតបរាមាសឥស្សាមច្ឆរិយានិ សោតាបត្តិមគ្គេន បហីយន្តិ, កាមរាគបដិឃា អនាគាមិមគ្គេន, មានភវរាគអវិជ្ជា អរហត្តមគ្គេនាតិ ។**

ទិដ្ឋិសំយោជនៈ វិចិកិច្ឆាសំយោជនៈ សីលព្វតបរាមាសសំយោជនៈ ឥស្សា-សំយោជនៈ មច្ឆរិយសំយោជនៈ លះដោយសោតាបត្តិមគ្គចិត្ត ។ កាមរាគសំយោជនៈ បដិឃសំយោជនៈ លះដោយអនាគាមិមគ្គចិត្ត ។ មានសំយោជនៈ ភវរាគសំយោជនៈ អវិជ្ជាសំយោជនៈ លះដោយអរហត្តមគ្គចិត្ត ។

# ការលះនីវរណៈដោយមគ្គទាំង ៤

**មគ្គបដិបាដិយា សោតាបត្តិមគ្គេន កុក្កុច្ចវិចិកិច្ឆា បហីយន្តិ, អនាគាមិមគ្គេន កាមច្ឆន្ទព្យាបាទា បហីយន្តិ, អរហត្តមគ្គេន ថីនមិទ្ធុទ្ធច្ចាវិជ្ជា បហីយន្តិ ។**

កុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ លះដោយសោតាបត្តិមគ្គចិត្ត ។ កាមច្ឆន្ទ-នីវរណៈ ព្យាបាទនីវរណៈ លះដោយអនាគាមិមគ្គចិត្ត។ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ លះដោយអរហត្តមគ្គចិត្ត ។

បណ្ឌិតគប្បីជ្រាបថា សូម្បីក្នុងព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់សម្តែងថា **រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ** ប្រែថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវរូបនោះចេញ [១] ។

តែក្នុងតតិយបទដែលពោលថា **នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា** ប្រែថា ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ និងមិនត្រូវលះដោយភាវនា អង្គធម៌របស់បទនេះក៏មានរូបផងដែរ តែព្រះតម្រាស់នេះមិនមែនសម្តែងឱ្យលះរូបដោយត្រង់នោះទេ (មុខ្យន័យ) គឺ សម្តែងឱ្យលះឆន្ទរាគៈដែលអាស្រ័យរូប គឺ ធ្វើរូបឱ្យជាអារម្មណ៍ មិនបានសំដៅយករូបដោយត្រង់ទេ ព្រោះរូបនោះជាអប្បហា-តព្វធម៌ (ធម៌មិនគប្បីលះ) រូបនេះជា **នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា** ។

ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យលោកសម្តែងទុកថា **រូបំ អារម្មណំ កត្វា ឧប្បន្នឆន្ទរាគំ សន្ធាយ តំ បជហថាតិ ភគវតា វុត្តំ** ។ ពាក្យថា **តំ បជហថ** ព្រះដ៏មានព្រះភាគទ្រង់សំដៅយកឆន្ទរាគៈ ដែលកើតឡើងព្រោះធ្វើរូបឱ្យជាអារម្មណ៍ ។

---

[១] សំយុត្តនិកាយ ខន្ធវារវគ្គ នតុម្ហាកវគ្គជាដើម ។

តទៅនេះនឹងសម្ដែងការលះសំយោជនៈជាដើម ដោយមគ្គទាំង ៤ ដែលប្រាកដក្នុងគម្ពីរវិសុទ្ធិមគ្គជាដើមពោលគឺ៖

## ១. ការលះសំយោជនៈដោយមគ្គទាំង ៤

**សំយោជនេសុ តាវ សក្កាយទិដ្ឋិវិចិកិច្ឆា សីលព្វតបរាមាសោ អបាយគមនីយា ច កាមរាគបដិឃាតិ ឯតេ បញ្ច ធម្មា បឋមញាណវជ្ឈា, សេសា កាមរាគបដិឃា ឱឡារិកា ទុតិយញាណវជ្ឈា, សុខុមា តតិយញាណវជ្ឈា, រូបរាគាទយោ បញ្ចបិ ចតុត្ថញាណវជ្ឈាឯវ ។**

បណ្ដាសំយោជនៈ ១០ យ៉ាងនោះ សំយោជនៈដែលត្រូវលះដោយសោតាបត្តមគ្គ មាន ៥ គឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស, កាមរាគៈ, និងបដិឃៈ ដែលនាំទៅកាន់អបាយ ។

កាមរាគៈ និងបដិឃៈ ដ៏គ្រោតគ្រាតក្រៅពីអបាយគមនីយៈនោះ (គឺ មិននាំទៅអបាយ) ត្រូវលះដោយសកទាគាមិមគ្គ ។ កាមរាគៈ បដិឃៈ ដ៏ល្អិតសុខុមនោះ ត្រូវលះដោយអនាគាមិមគ្គ ។

សំយោជនៈ ៥ មានរូបរាគៈជាដើម (រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា) ត្រូវលះដោយអរហត្តមគ្គប៉ុណ្ណោះ ។

## ២. ការលះកិលេស ១០ ដោយមគ្គទាំង ៤

**កិលេសេសុ ទិដ្ឋិវិចិកិច្ឆា បឋមញាណវជ្ឈា, ទោសោ តតិយញាណវជ្ឈោ, លោភមោហមានថីនឧទ្ធច្ចអហិរិកអនោត្តប្បានិ ចតុត្ថញាណវជ្ឈានិ ។**

បណ្ដាកិលេស ១០ យ៉ាងនោះ ទិដ្ឋិ វិចិកិច្ឆា ត្រូវលះដោយសោតាបត្តិមគ្គ,

ទោសៈ ត្រូវលះដោយអនាគាមិមគ្គ ។ លោភៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ត្រូវលះដោយអរហត្តមគ្គ ។

## ៣. ការលះមិច្ឆត្តធម៌ដោយមគ្គទាំង ៤

មិច្ឆត្តធម៌ ធម៌ដែលមានសភាពអាក្រក់មាន ១០ យ៉ាងគឺ ៖

១. **មិច្ឆាទិដ្ឋិ** ការយល់ឃើញខុស

២. **មិច្ឆាសង្កប្ប** ការត្រិះរិះខុស

៣. **មិច្ឆាវាចា** ការពោលវាចាខុស

៤. **មិច្ឆាកម្មន្ត** ការប្រកបការងារខុស

៥. **មិច្ឆាអាជីវ** ការប្រកបអាជីវៈខុស

៦. **មិច្ឆាវាយាម** សេចក្ដីព្យាយាមខុស

៧. **មិច្ឆាសតិ** សេចក្ដីរឭកខុស

៨. **មិច្ឆាសមាធិ** ការតាំងមាំនៃចិត្តខុស

៩. **មិច្ឆាវិមុត្តិ** មានការយល់ខុសថា ការប្រព្រឹត្តិទៅរបស់នេវសញ្ញានាសញ្ញាយតនព្រហ្មនេះ ឬ ការប្រព្រឹត្តិប្រតិបត្តិដូចគ្នានឹងគោមានការស៊ីស្មៅជាដើម ហើយយល់ថា ការកើតឡើងនៃនេវសញ្ញានាសញ្ញាយតនព្រហ្មនេះ ជាហេតុនាំឱ្យរួចផុតចាកទុក្ខ ឬ ធ្វើបែបនេះហើយ នឹងជាហេតុនាំឱ្យរួចផុតចាកទុក្ខ ។

១០. **មិច្ឆាញាណ** មោហៈដែលប្រព្រឹត្តដោយអាការៈថា កម្មមានបាណាតិបាតជាដើមអាត្មាអញបានធ្វើល្អហើយ (១) ។

(១) មិច្ឆាញាណន្តិ បាបកិរិយាសុ ឧបាយចិន្តាវសេន បាបំ កត្វា សុកតំ មយាតិ បច្ចវេក្ខណាការេន ឧប្បន្នោ មោហោ ។

**មិច្ឆត្តេសុ មិច្ឆាទិដ្ឋិ មុសាវាទោ មិច្ឆាកម្មន្តោ មិច្ឆាអាជីវោតិ ឥមេ បឋមញាណវជ្ឈា, មិច្ឆាសង្កប្បោ បិសុណវាចា ផរុសវាចាតិ ឥមេ តតិយញាណ-វជ្ឈា, ចេតនាយេវ ចេត្ថ វាចាតិ វេទិតព្វា, សម្ផប្បលាបមិច្ឆាវាយាមសតិសមាធិវិមុត្តិញាណានិ ចតុត្ថញាណវជ្ឈានិ ។**

បណ្ដាមិច្ឆត្តធម៌ទាំងនោះ មិច្ឆត្តធម៌ ៤ គឺ មិច្ឆាទិដ្ឋិ មុសាវាទ មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ ត្រូវលះដោយសោតាបត្តិមគ្គ ។

មិច្ឆត្តធម៌ ៣ គឺ មិច្ឆាសង្កប្បៈ បិសុណវាចា ផរុសវាចា ត្រូវលះដោយអនាគាមិមគ្គ ។ ចេតនាប៉ុណ្ណោះ គប្បីជ្រាបថា វាចា ក្នុងទីនេះ ។

សម្ផប្បលាបៈ មិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ មិច្ឆាវិមុត្ត មិច្ឆាញាណៈ ត្រូវលះដោយអរហត្តមគ្គ ។

# ៤. ការលះលោកធម៌ដោយមគ្គទាំង ៤

**លោកធម្មេសុ បដិឃោ តតិយញាណវជ្ឈោ, អនុនយោ ចតុត្ថញាណវជ្ឈោ, យសេ ច បសំសាយ អនុនយោ ចតុត្ថញាណវជ្ឈោតិ ឯកេ ។**

បណ្ដាលោកធម៌ទាំងនោះ បដិឃៈដែលកើតឡើងដោយអាស្រ័យការឥត-លាភ ឥតយស និន្ទា និងទុក្ខ ត្រូវលះដោយអនាគាមិមគ្គបុគ្គល ។ តណ្ហាដែលកើតឡើងដោយអាស្រ័យការបានលាភ យស សរសើរ និងសុខ ត្រូវលះដោយអរហត្ត-មគ្គបុគ្គល ។

អាចារ្យពួកខ្លះពោលថា តណ្ហាដែលកើតឡើងដោយអាស្រ័យការបានយស និងសរសើរទាំង ២ នេះ ត្រូវលះដោយអរហត្តមគ្គ, សម្រាប់តណ្ហាដែលកើតឡើងដែលអាស្រ័យលាភ និងសេចក្ដីសុខនោះ ត្រូវលះដោយអនាគាមិមគ្គ ។

# ៩. ការលះមច្ឆរិយៈ ៥ ដោយមគ្គ

**មច្ឆរិយានិ បឋមញាណវជ្ឈានេវ** ។ ព្រះសោតាបន្នបុគ្គលជាអ្នកលះមច្ឆរិយៈទាំង ៥ ប្រការ ។

មច្ឆរិយៈ ៥ យ៉ាង គឺ៖

១. **អាវាសមច្ឆរិយៈ** កំណាញ់អាវាស

២. **កុលមច្ឆរិយៈ** កំណាញ់ត្រកូល

៣. **លាភមច្ឆរិយៈ** កំណាញ់លាភ

៤. **វណ្ណមច្ឆរិយៈ** កំណាញ់សេចក្តីសរសើរ

៥. **ធម្មមច្ឆរិយៈ** កំណាញ់ធម៌ ។

អធិប្បាយថា ការមិនចង់ឱ្យបុគ្គលដទៃមកនៅអាស្រ័យក្នុងទីកន្លែងនោះៗ ដែលជាសម្បត្តិរបស់ខ្លួនដោយហេតុត្រឹមតែហួងហែងទីនៅអាស្រ័យប៉ុណ្ណោះ មិនបានសម្លឹងដល់ទោសណាមួយ ដែលគប្បីមានក្តី, ការមិនចង់ឱ្យបុគ្គលដទៃចូលទៅអាស្រ័យក្នុងទីកន្លែង ជាទីសាធារណៈដល់បុគ្គលដទៃ ព្រោះសេចក្តីលោភលន់ក្នុងទីនៅប្រើនកន្លែងជាដើមក្តី ឬ អារាមទាំងអស់ក្តី បរិវេណក្តី បន្ទប់មួយក្តី ទីសម្រាកពេលថ្ងៃ និងសម្រាកពេលយប់ក្តី កាលបុគ្គលដទៃមកដល់ហើយក៏មានតែសេចក្តីប្រាថ្នាចង់ឱ្យទៅវិញឆាប់ ៗ ឈ្មោះថា **អាវាសមច្ឆរិយៈ** ។ តែភិក្ខុមិនប្រាថ្នាការនៅរបស់បុគ្គលដែលធ្វើការវិវាទគ្នា មិនឈ្មោះថា អាវាសមច្ឆរិយៈទេ ។

ត្រកូលមាន ២ យ៉ាង គឺ ត្រកូលឧបដ្ឋាក និងត្រកូលញាតិ ការដែលភិក្ខុមានសេចក្តីប្រាថ្នាចង់ឱ្យត្រកូលឧបដ្ឋាករបស់ខ្លួន ដែលទំនុកបំរុង ឬ គោរពបូជាខ្លួនតែម្នាក់ឯង មិនចង់ឱ្យទំនុកបំរុង ឬ គោរពបូជាភិក្ខុដទៃទៀត គ្រប់គ្រាដែលមានភិក្ខុដទៃចូលទៅកាន់ត្រកូលឧបដ្ឋាក រមែងមិនសប្បាយចិត្ត ឈ្មោះថា **កំណាញ់ត្រកូល**

**ឧបដ្ឋាក** បំណែកឯ ការដែលមិនត្រេកអរក្នុងពេលដែលមានភិក្ខុចូលទៅកាន់ត្រកូលញាតិរបស់ខ្លួន ព្រោះហេតុទំនងដូចគ្នានុ៎ះឯង ឈ្មោះថា **កំណាញ់ត្រកូលញាតិ** ។

តែភិក្ខុមិនប្រាថ្នាឱ្យបុគ្គលដែលមានចិត្តបាបឋោកទាប ចូលទៅរកត្រកូលនោះហើយ តែងតែពោលពាក្យឱ្យអស់សទ្ធា ស្ងប់ហាមយ៉ាងនេះ មិនឈ្មោះថា **កុលមច្ឆរិយៈ** ។ ប្រសិនបើភិក្ខុដទៃជាអ្នកមានសីលល្អ គួរជាទីជ្រះថ្លារបស់ត្រកូលបាន តែភិក្ខុនោះមានចិត្តកំណាញ់ មិនឱ្យភិក្ខុដែលមានសីល និងអាចារៈល្អបែបនេះចូលទៅកាន់ត្រកូលដែលមានសទ្ធាជ្រះថ្លា ឈ្មោះថា **កុលមច្ឆរិយៈ** ។

បើបុគ្គលមិនឱ្យវត្ថុដែលគួរឱ្យដល់បុគ្គលដទៃ ឬ មិនត្រេកអរក្នុងការបែករំលែកដល់បុគ្គលដទៃ ដោយហេតុត្រឹមតែហួងហែងវត្ថុរបស់ខ្លួន ឬ ខ្លាចវិនាសប៉ុណ្ណោះ ឈ្មោះថា **លាភមច្ឆរិយៈ** ។ ប្រសិនបើភិក្ខុមានលាភមច្ឆរិយៈ ស្ងប់ជាអ្នកដល់ព្រមដោយលាភ បានបិណ្ឌបាតច្រើនជាដើម ក៏មិនត្រេកអរក្នុងការលះបង់ ឬបែករំលែកដល់ភិក្ខុដទៃឡើយ ។ វត្ថុដែលគួរបាន ដើម្បីជាប្រយោជន៍ និងសេចក្ដីងាយស្រួលក្នុងការទ្រទ្រង់ជីវិត លោកហៅថា "**លាភ**" ព្រោះជាវត្ថុគប្បីបាន គឺ បច្ច័យ ៤ នុ៎ះឯង ។ កាលភិក្ខុដទៃ មានសីលាចារវត្តល្អ បានបច្ច័យ ៤ មកដោយអាការៈបែបនេះ ភិក្ខុអ្នកមានចិត្តបាបនឹកកំណាញ់ក្នុងចិត្តថា "**កុំឱ្យលាភនេះកើតឡើងដល់បុគ្គលនេះឡើយ**" សេចក្ដីកំណាញ់លាភ ដូចបានពោលមកនេះ ឈ្មោះថា **លាភមច្ឆរិយៈ** ។

ឈ្មោះថា "**វណ្ណៈ**" បានដល់ ពាក្យសរសើរ ។ វត្ថុដែលគួរសរសើរនោះមាន ២ យ៉ាងគឺ ពណ៌សម្បុរកាយ និងគុណធម៌ ។

អធិប្បាយថា សម្រាប់បុគ្គលមានសេចក្ដីកំណាញ់នែពណ៌សម្បុរកាយ កាលបុគ្គលដទៃកំពុងសរសើរថា "**អ្នកនេះមានរូបស្អាត គួរឱ្យចង់ពិតពិលរមិលមើល**" ជាដើម ក៏មិនប្រាថ្នាក្នុងការពោលយ៉ាងនោះ ទើបមិនបញ្ចេញវាចាពោលពាក្យសរសើរ

នេះឈ្មោះថា **វណ្ណមច្ឆរិយៈ “កំណាញ់ពាក្យសរសើរនៃសម្បុរកាយ”** ។ ម្យ៉ាងទៀត កាលដឹងថា “បុគ្គលនេះជាអ្នកដល់ព្រមដោយសីល ធុតង្គបដិបទាជាដើមក្តី ឬដឹងថា **“បុគ្គលនេះជាពហុស្សូត”** ជាដើមក្តី ក៏រមែងមិនចង់បញ្ចេញវាចាពោលសរសើរគុណធម៌របស់បុគ្គលនោះឡើយ នេះឈ្មោះថា **កំណាញ់ពាក្យសរសើរគុណធម៌** ។ ដូចបានពោលមកនេះ ឈ្មោះថា **វណ្ណមច្ឆរិយៈ**។

ពាក្យថា **“ធម៌”** ក្នុងទីនេះ សំដៅយកបរិយត្តិធម៌ប៉ុណ្ណោះ មិនបានសំដៅយកបដិវេធធម៌ទេ ព្រោះបដិវេធធម៌ទាំងឡាយ ជាសម្បត្តិរបស់ព្រះអរិយបុគ្គលដែលលោកជាអ្នកកាត់ផ្តាច់នូវមច្ឆរិយៈបានហើយ ។ ព្រះអរិយបុគ្គលទាំងឡាយ មិនមានសេចក្តីកំណាញ់ក្នុងបដិវេធធម៌ឡើយ ដោយប្រការទាំងពួង ។

មែនពិត ព្រះអរិយបុគ្គលទាំងឡាយ រមែងចង់ឱ្យសត្វលោកដឹងច្បាស់នូវធម៌ដែលលោកបានដឹងហើយ ទើបត្រេកអរក្នុងការពន្យល់ និងសម្តែងនូវបដិបទា ដែលប្រព្រឹត្តទៅដើម្បីការដឹងច្បាស់នូវបដិវេធធម៌ទាំងនោះ ។ ភិក្ខុជាបុថុជ្ជនខ្លះ ជាអ្នកច្រើនដោយពហុស្សូតក្នុងព្រះបរិយត្តិធម៌ មិនចង់ឱ្យភិក្ខុដទៃមានបំណោះបេះដឹងក្នុងព្រះបរិយត្តិធម៌នោះច្រើនជាងខ្លួន ឬ ស្មើនឹងខ្លួនឡើយ ទើបមិនត្រេកអរក្នុងការប្រាប់សម្តែងធម៌ដែលខ្លួនដឹងហើយដល់ភិក្ខុដទៃ សូម្បីមានការប្រាប់ខ្លះ ក៏មួយបំណែកប៉ុណ្ណោះ មិនប្រាប់នូវបំណែកដ៏សេសឡើង ទើបបាត់ថា**ជាអ្នកកំណាញ់បំណោះដឹង** ។ ម្យ៉ាងទៀត វិជ្ជាផ្លូវលោកដែលឥតមានទោស តែប្រព្រឹត្តទៅដើម្បីការនៅជាសុខក្នុងជីវិតបច្ចុប្បន្ននេះ ក៏សង្គ្រោះចូលដោយពាក្យថា **“ធម៌”** ក្នុងទីនេះបាន បុគ្គលខ្លះមិនចង់ឱ្យអ្នកដទៃប្រសើរជាងខ្លួន ឬ ស្មើនឹងខ្លួនដោយបំណោះដឹងក្នុងវិជ្ជានោះ ៗ ទើបមិនត្រេកអរក្នុងការប្រាប់អ្នកដទៃឡើយ សេចក្តីកំណាញ់ព្រះបរិយត្តិធម៌ និងសេចក្តីកំណាញ់បំណោះដឹងក្នុងវិជ្ជាផ្លូវលោក ដូចពោលមកនេះ ឈ្មោះថា **ធម្មមច្ឆរិយៈ**។

# សម្តែងទោសនៃមច្ឆរិយៈទាំង ៥ ប្រការ

បណ្តាមច្ឆរិយៈ ទាំង ៥ យ៉ាងនោះ បុគ្គលណា **កំណាញ់អាវាស** ក្រោយអំពីស្លាប់ទៅ បុគ្គលនោះ នឹងកើតជាយក្ខ ឬ ប្រេត ដូចជាយកកាកសំណល់ទូលលើក្បាលហើយ ក៏ត្រាច់ទៅ ។ ឬ បុគ្គលដែលកំណាញ់អាវាសនេះ រមែងឆេះនៅក្នុងខ្ទះទង់ដែង ។ សម្រាប់បុគ្គលដែល**កំណាញ់ត្រកូល** បើឃើញមនុស្សក្នុងត្រកូលនោះជាអ្នកមានសទ្ធាធ្វើបុណ្យឱ្យទានជាដើម បំពោះភិក្ខុដទៃៗ ក៏អន់ចិត្តថា ត្រកូលនេះមិនឱ្យអ្វីដល់អាត្មាអញទេ ប្រហែលជាអន់ចិត្ត ឬ ស្អប់ខ្ពើមបំពោះអាត្មាអញហើយ គិតទៅក៏អន់ចិត្ត រហូតដល់ក្អួតបេញឈាម ពោះវៀនតូចធំនឹងដាច់ជាចម្រៀកតូចធំចេញមក ។ បុគ្គលដែលកំណាញ់ត្រកូលនេះ កើតជាតិណាៗ ជាអ្នកមិនមានលាភសក្ការៈ ។

សម្រាប់បុគ្គលដែលកំណាញ់លាភ បើលាភនោះ ជារបស់សង្ឃក្តី ឬ គណៈក្តីប្រើប្រាស់ដូចជារបស់បុគ្គល ក្រោយអំពីស្លាប់ទៅ ក៏តែងតែទៅកើត ជាយក្ខ ប្រេត ឬ ពស់ថ្លាន់ ។

ទោសនៃការកំណាញ់លាភ គឺ ទៅកើតក្នុងគូថនរក (នរកលាមក) ។ សម្រាប់បុគ្គលដែល**កំណាញ់ពាក្យសរសើរ** ក្រោយអំពីស្លាប់ទៅ ជាអ្នកមានរូបអាក្រក់, សម្បុរក៏ខ្មៅ, ជាមនុស្ស-គ, មនុស្សឆ្កួត ឬជាមនុស្សឆ្កួតជ្រូក ។ ឯផលក្នុងសម្បរាយិកភពវិញ មានគេនិន្ទា ជេរប្រទេចផ្តាសា មិនមានអ្នកលើកតម្កើងពោលសរសើរ ឆោតល្ងង់ខ្លៅ គ្មានបញ្ញា ។

បំណែកឯ **ធម្មមច្ឆរិយៈ** បុគ្គលណាកំណាញ់ធម៌ដែលមិនមានទោស គឺ មានគុណតែម្យ៉ាង ទាំងផ្លូវលោក ទាំងផ្លូវធម៌ ក្រោយអំពីស្លាប់ទៅ បុគ្គលនោះរមែងទៅ

កើតក្នុងនរកផ្ទះក្តៅ រងទុក្ខវេទនាអស់កាលដ៏យូរ (១) ។

## ៦. ការលះវិបល្លាសធម៌ដោយមគ្គទាំង ៤

**វិបល្លាសេសុ អនិច្ចេ និច្ចំ, អនត្តនិ អត្តាតិ ច សញ្ញាចិត្តទិដ្ឋិវិបល្លាសា, ទុក្ខេ សុខំ, អសុភេ សុភន្តិ ទិដ្ឋិវិបល្លាសោ ចាតិ ឥមេ បឋមញាណវជ្ឈា, អសុភេ សុភន្តិ សញ្ញាចិត្តវិបល្លាសា តតិយញាណវជ្ឈា, ទុក្ខេ សុខន្តិ សញ្ញាចិត្តវិបល្លាសា ចតុត្ថញាណវជ្ឈា ។**

បណ្តាវិបល្លាសធម៌ វិបល្លាសទាំងនេះ គឺ សញ្ញាវិបល្លាស ចិត្តវិបល្លាស និងទិដ្ឋិវិបល្លាសថាទៀង ក្នុងធម៌ដែលមិនទៀង, ថាជាអត្តា ក្នុងធម៌ដែលជាអនត្តា, ទិដ្ឋិវិបល្លាសថាសុខ ក្នុងធម៌ដែលជាទុក្ខ, ថាជាសុភៈ ក្នុងធម៌ដែលជាអសុភៈ ត្រូវលះដោយសោតាបត្តិមគ្គបុគ្គល ។

សញ្ញាវិបល្លាស និង ចិត្តវិបល្លាសថាសុភៈ ក្នុងធម៌ជាអសុភៈ ត្រូវលះដោយអនាគាមិមគ្គបុគ្គល ។

សញ្ញាវិបល្លាស និង ចិត្តវិបល្លាសថាជាសុខ ក្នុងធម៌ដែលជាទុក្ខ ត្រូវលះដោយអរហត្តមគ្គបុគ្គល ។

## ៧. ការលះអគតិ ៤ ដោយមគ្គ

**អគតិ បឋមញាណវជ្ឈាវ ។**

អគតិ ៤ គឺ ឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទាំងអស់នេះ ត្រូវលះដោយសោតាបត្តិមគ្គនោះឯង គប្បីយល់ថា អគតិទាំងនេះ មិនបានសំដៅយកអង្គ

---

(១) កន្លែងនេះ ប្រែអធិប្បាយទាំងអដ្ឋកថាអដ្ឋសាលិនី និង សារត្ថសង្គហៈ ភាគ ២ ទំព័រ ៨៦ ជាដើម ផ្សំចូលគ្នា ។

ធម៌ដែលជាលោភៈ ទោសៈ និងមោហៈ ដោយត្រង់ឡើយ សំដៅយកការប្រព្រឹត្តិប្រតិបត្តិដោយកាយវាចាខុសចាកសីលធម៌ ដោយអាស្រ័យលោភៈ ទោសៈ និងមោហៈ ជាមូលប៉ុណ្ណោះ តែការបដិបត្តិខុសនេះ ជាហេតុនាំទៅកាន់អបាយបាន ត្រូវតែលះដោយសោតាបត្តិមគ្គ ។

## ៨. ការលះអកុសលកម្ម ១០ ដោយមគ្គទាំង ៤

**អកុសលកម្មបថេសុ បាណាតិបាតោ អទិន្នាទានំ កាមេសុ មិច្ឆាចារោ មុសាវាទោ មិច្ឆាទិដ្ឋីតិ ឥមេ បឋមញាណវជ្ឈា, បិសុណវាចា ផរុសវាចា ព្យាបាទោតិ តយោ តតិយញាណវជ្ឈា, សម្ផប្បលាបាភិជ្ឈា បតុត្ថញាណវជ្ឈា ។**

បណ្តាអកុសលកម្មបថ ១០ ទាំងនោះ អកុសលកម្មបទ ៥ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ មិច្ឆាទិដ្ឋិ ត្រូវលះដោយសោតាបត្តិមគ្គ ។

អកុសលកម្មបថ ៣ គឺ បិសុណវាចា ផរុសវាចា ព្យាបាទ ត្រូវលះដោយអនាគាមិមគ្គ, សម្ផប្បលាបៈ និងអភិជ្ឈាទាំង ២ នេះ ត្រូវលះដោយអរហត្តមគ្គ ។

## ចប់ ទស្សនត្តិកៈ

# ៩. ទស្សនហេតុត្តិកៈ

បឋមបទ. **ទស្សនេន បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ បានដល់ ទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង ចេតសិក ២២ (វៀរមោហៈចេ. ក្នុងវិចិកិច្ឆាសម្បយុត្ត) លះបានដោយសមុច្ឆេទប្បហានៈ ។

ឬម្យ៉ាងទៀត បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ទោសមូលចិត្ត ២ ដួង ចេតសិក ២៥ ដែលជាហេតុនាំទៅកាន់អបាយ (អបាយគមនីយៈ) ព្រះសោតាបន្ន លះបានដោយសមុច្ឆេទប្បហានៈ ។

ទុតិយបទ. **ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលត្រូវលះដោយភាវនា បានដល់ ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ទោសមូលចិត្ត ២ ដួង ចេតសិក ២៥ ។

-ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ទោសមូលចិត្ត ២ ចេតសិក ២៥ ដែលគ្រោតគ្រាត (ឱឡារិកៈ) ព្រះ<u>សកទាគាមិមគ្គ</u> លះបានដោយអំណាចនៃការធ្វើឱ្យស្រាលស្តើង (តនុករប្បហានៈ) ។

-ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃកាមរាគៈ ទោសមូលចិត្ត ២ ចេតសិក ២៥ ព្រះ<u>អនាគាមិមគ្គ</u> លះបានដោយដាច់ខាត (សមុច្ឆេទប្បហានៈ) ។

-ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃរូបរាគៈ អរូបរាគៈ ឧទ្ធច្ចសម្បយុត្តចិត្ត ១ ចេតសិក ២១ (វៀរមោហៈចេ.ក្នុងឧទ្ធច្ចសម្បយុត្តចិត្ត) ព្រះ<u>អរហត្តមគ្គ</u> លះបានដោយដាច់ខាត (សមុច្ឆេទប្បហានៈ) ។

តតិយបទ. **នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា បាន ដល់ កុសលចិត្ត ២១ វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ និងមោហៈចេ. ក្នុងមោហមូលចិត្ត ២ រូប ២៨ និព្វាន ។

<u>**អង្គធម៌របស់បឋមបទ**</u> បែកដូចគ្នានឹងបឋមបទនៃ**ទស្សនត្តិកៈ** ។

<u>**អង្គធម៌របស់ទុតិយបទ**</u> បែកដូចគ្នានឹងទុតិយបទនៃ**ទស្សនត្តិកៈ** ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## អធិប្បាយទស្សនហេតុត្តិកៈ

វិបនត្ថៈរបស់<u>បឋមបទ</u> ៖

**ទស្សនេន បហាតព្វោ ហេតុ ឯតេសន្តិ ទស្សនេនបហាតព្វហេតុកា** ។ ប្រែថា ហេតុដែល ត្រូវលះដោយសោតាបត្តិមគ្គមានដល់ធម៌ទាំងនុ៎ះ ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា **ទស្សនេនបហាតព្វហេតុកា** អធិប្បាយថា ធម៌ដែលព្រះពុទ្ធអង្គទ្រង់សម្តែងក្នុងបឋមបទនោះ ជាធម៌ដែលមានហេតុ (គឺប្រកបដោយហេតុ) គប្បីលះដោយសោតាបត្តិមគ្គ សម្រាប់ការវៀរមោហៈចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្តនោះ ព្រោះជាចិត្តមិនមានហេតុប្រកបដែលសោតាបត្តិមគ្គគប្បីលះ ។

វិបនត្ថៈរបស់<u>ទុតិយបទ</u> ៖

**ភាវនាយ បហាតព្វោ ហេតុ ឯតេសន្តិ ភាវនាយបហាតព្វហេតុកា** ។ ប្រែថា ហេតុដែលគប្បីលះដោយអរិយមគ្គ ៣ ខាងលើ មានដល់ធម៌ទាំងនុ៎ះ ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា **ភាវនាយបហាតព្វហេតុកា** អធិប្បាយថា ធម៌ដែលព្រះពុទ្ធអង្គទ្រង់សម្តែងក្នុងទុតិយបទនោះ ជាធម៌ដែលមានហេតុគប្បីលះដោយអរិយមគ្គ

៣ ខាងលើ សម្រាប់ការវៀរមោហៈចេតសិកក្នុងឧទ្ធច្ចសម្បយុត្តចិត្តនោះ ព្រោះមិនមានហេតុដែលអរិយមគ្គ ៣ ខាងលើ គប្បីលះ ។

វិបឥត្ថៈរបស់តតិយបទ ៖

**នេវទស្សនេន នភាវនាយ បហាតព្វោ ហេតុ ឯតេសត្តិ នេវ ទស្សនេន ភាវនាយ បហាតព្វហេតុកា ។** ប្រែថា ហេតុដែលគប្បីលះដោយសោតាបត្តិមគ្គ និងអរិយមគ្គ ៣ មិនមានដល់ធម៌ទាំងនុ៎ះ ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា **នេវទស្សនេន នភាវនាយ បហាតព្វហេតុកា** អធិប្បាយថា ធម៌ដែលព្រះពុទ្ធអង្គទ្រង់សម្តែងក្នុងតតិយបទនោះ ជាធម៌ដែលមិនមានហេតុគប្បីលះដោយសោតាបត្តិមគ្គ និងអរិយមគ្គ ៣ ខាងលើ សម្រាប់មោហចេតសិកក្នុងមោហៈមូលចិត្ត ២ ដួងនោះ មិនមានហេតុដែលគប្បីលះដោយសោតាបត្តិមគ្គ និងអរិយមគ្គ ៣ ខាងលើ ព្រោះដូច្នោះ ទើបសង្គ្រោះចូលក្នុងតតិយបទនេះបាន ។

## ចប់ ទស្សនហេតុត្តិកៈ

## ១០. អាចយគាមិត្តិកៈ

បឋមបទ. **អាចយគាមិនោ ធម្មា** ពួកធម៌ដល់នូវការសន្សំកពូនឡើង ដោយកម្មក្កិលេស បានដល់ អកុសលចិត្ត ១២ លោកិយកុសលចិត្ត ១៧ ចេ. ៥២ ។

ទុតិយបទ. **អបចយគាមិនោ ធម្មា** ពួកធម៌មិនដល់នូវការសន្សំកពូនឡើង បានដល់ មគ្គចិត្ត ៤ ចេ. ៣៦ ។

តតិយបទ. **នេវាចយគាមិនាបចយគាមិនោ ធម្មា** ពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង បានដល់ វិបាកចិត្ត ៣៦, កិរិយាចិត្ត ២០, ចេ ៣៨, រូប ២៨, និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និងឈ្មោះថា **និប្បទេសត្តិកៈ** ។

## អធិប្បាយអាចយគាមិត្តិកៈ

បណ្ឌិតគប្បីជ្រាបរូបវិគ្គហៈដូចតទៅ **កម្មកិលេសេហិ អាចិយតីតិ អាចយោ បដិសន្ធិចុតិគតិប្បវត្តានំ ឯតំ នាមំ** ប្រែថា ឈ្មោះថា **អាចយៈ** ព្រោះមានអត្ថថា ត្រូវកម្មនិងកិលេសកសាងទុក ពាក្យនេះ ជាឈ្មោះនៃបដិសន្ធិ ចុតិ និងភពដែលប្រព្រឹត្តទៅជាប់តគ្នា ។

ពាក្យថា **អាចយៈ** នេះ គឺ ធម៌ដែលជាហេតុនៃបដិសន្ធិ ចុតិ និងភព ដោយសភាពញុំាងផលឱ្យសម្រេច ។ បើពោលដោយ**បុគ្គលាធិដ្ឋាន**ហើយ ជាឈ្មោះនៃសត្វទាំងឡាយដែលមានសភាពវិលវល់ក្នុងវដ្តទុក្ខដោយអំណាចនៃការកើត និងការស្លាប់ ។

ឬ ញ៉ាំងសត្វដែលមានធម៌នោះៗ (គឺ អកុសលចិត្ត ១១ លោកិយកុសលចិត្ត ១៧) ឱ្យដល់បដិសន្ធិ ចុតិ និងភព ។ ពាក្យថា **អាចយគាមី**នេះ ជាឈ្មោះរបស់កុសល និងអកុសលដែលជាអារម្មណ៍នៃអាសវៈ (សាសវកុសលាកុសលានំ ឯតំ នាមំ អធិ-វចនំ) ។

**តតោឯវ អាចយសង្ខាតា ចយា អបេតត្តា និព្វានំ អបេតំ ចយាតិ អបចយោ** ។ ប្រែថា ព្រះនិព្វានដែលប្រាសចាកសភាវៈ គឺ កម្ម និងកិលេសកសាង ទុក ព្រោះប្រាសចាកសភាវៈដែលត្រូវកសាង គឺ បដិសន្ធិ ចុតិ និងភពនោះឯង បាន ដល់ ព្រះនិព្វាន ។

**តំ អារម្មណំ កត្វា បវត្តនតោ អបចយំ គច្ឆន្តីតិ អបចយគាមិនោ** ពាក្យថា អបចយគាមី គឺ ធម៌ដែលដល់អបចយៈ គឺ ព្រះនិព្វាន ព្រោះប្រព្រឹត្តទៅដោយធ្វើព្រះ និព្វាននោះឱ្យជាអារម្មណ៍ ។ នេះជាឈ្មោះនៃអរិយមគ្គទាំង ៤ ដោយអំណាចនៃកិច្ច ទាំង ៤ (អរិយមគ្គានមេតំ អធិវចនំ) ។

អធិប្បាយថា សភាវធម៌ដែលជាហេតុឱ្យដល់ព្រះនិព្វាននោះ មិនមែនមានតែ បំពោះលោកុត្តរកុសលប៉ុណ្ណោះទេ សូម្បីលោកិយកុសលក៏ជាហេតុឱ្យដល់ព្រះនិព្វាន បានដូចគ្នា តែជាហេតុឆ្ងាយ (ទូរការណៈ) និងមិនទាន់ទៀងទាត់, សម្រាប់មគ្គចិត្ត ៤ នោះ ជាហេតុជិត និងទៀងទាត់, ក្នុងបទនេះ ព្រះពុទ្ធអង្គទ្រង់សំដៅយកធម៌ដែលឱ្យ ដល់ព្រះនិព្វាន ដោយជាហេតុជិតនិងទៀងទាត់ ។ ព្រោះហេតុនោះ អង្គធម៌ទើបបាន ដល់ មគ្គចិត្ត ៤ ចេតសិក ៣៦ ប៉ុណ្ណោះ ។

សម្រាប់តតិយបទនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយអំណាចនៃការ បដិបក្ខបំពោះបទទាំង ២ ។

## ចប់ អាចយគាមិត្តិកៈ

# ១១. សេក្ខត្តិកៈ

បឋមបទ. **សេក្ខា ធម្មា** ពួកធម៌ជារបស់សេក្ខបុគ្គល បានដល់ លោកុត្តរ-
ចិត្ត ៧ (វៀរអរហត្តផលចិត្ត ១), ចេតសិក ៣៦ ។

ទុតិយបទ. **អសេក្ខា ធម្មា** ពួកធម៌ជារបស់អសេក្ខបុគ្គល បានដល់ អរហត្ត-
ផលចិត្ត ១ ចេតសិក. ៣៦ ។

តតិយបទ. **នេវសេក្ខានាសេក្ខា ធម្មា** ពួកធម៌មិនមែនជារបស់សេក្ខ-
បុគ្គល មិនមែនជារបស់អសេក្ខបុគ្គល បានដល់ លោកិយចិត្ត ៨១, ចេតសិក ៥២,
រូប ២៨, និព្វាន ។

ត្តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## អធិប្បាយសេក្ខត្តិកៈ

វិបនត្ថៈរបស់បឋមបទ ៖

១. **តីសុ សិក្ខាសុ ជាតាតិ សេក្ខា** ។ ឈ្មោះថា សេក្ខៈ ព្រោះមានអត្ថថា ជាធម៌កើតក្នុងសិក្ខាទាំង ៣ ។ ឬ បុគ្គលពួកណាកំពុងបដិបត្តិក្នុងសិក្ខា ៣ ព្រោះហេតុនោះ បុគ្គលពួកនោះ ឈ្មោះថា សេក្ខៈ បានដល់ ព្រះសេក្ខបុគ្គល ៧ ពួក ។

២. **អបរិយោសិតសិក្ខត្តា សយមេវ សិក្ខន្តីតិបិ សេក្ខា** ។ បុគ្គលពួកណារមែងបដិបត្តិធម៌ដែលខ្លួនឯងគប្បីធ្វើ ព្រោះមានការបដិបត្តិមិនទាន់ចប់ ព្រោះហេតុនោះ បុគ្គលពួកនោះ ឈ្មោះថា សេក្ខៈ បានដល់ ព្រះសេក្ខបុគ្គល ៧ ពួក ។

៣. **សត្តន្នំ សេក្ខានំ ឯតេតិបិ សេក្ខា** ធម៌ទាំងឡាយណាជារបស់សេក្ខបុគ្គល ៧ ពួក ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា សេក្ខៈ បានដល់ លោកុត្តរចិត្ត ៧ (អរហត្តផលចិត្ត) ។ បណ្ឌិតគប្បីជ្រាបថា សូម្បីកល្យាណបុថុជ្ជន ក៏បានឈ្មោះថា

សេក្ខៈបុគ្គលដូចគ្នា ព្រោះប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ⑴ ។

វិបនត្ថៈរបស់ទុតិយបទ ៖

១. **ឧបរិ សិក្ខិតព្វាភាវតោ ន សេក្ខាតិ អសេក្ខា** បុគ្គលពួកណាមិនមែនជាសេក្ខបុគ្គល ព្រោះមិនមានធម៌ដែលត្រូវបដិបត្តិតទៅទៀត ព្រោះហេតុនោះ បុគ្គលពួកនោះ ឈ្មោះថា អសេក្ខៈ បានដល់ អរហត្តផលបុគ្គល ។

២. **វុឌ្ឍិប្បត្តា វា សេក្ខាតិបិ អសេក្ខា** បុគ្គលដែលកំពុងបដិបត្តិក្នុងសិក្ខា ៣ ពួកនោះ ដល់នូវសេចក្តីចម្រើនហើយ គឺ បដិបត្តិចប់ហើយ ព្រោះហេតុនោះ បុគ្គលពួកនោះ ឈ្មោះថា អសេក្ខៈ ។

**អរហត្តផលធម្មានំ ឯតំ អធិវចនំ** ពាក្យថា អសេក្ខៈនេះ ជាឈ្មោះនៃធម៌ គឺ អរហត្តផល ។

ហសិតុប្បាទចិត្ត ១ មហាកិរិយាចិត្ត ៨ មហគ្គតកិរិយាចិត្ត ៩ បានដល់ ១៨ ដួងនេះកើតឡើង ចំពោះក្នុងសន្តានរបស់ព្រះអរហន្តក៏ពិតមែន តែចិត្ត ១៨ ដួងនេះមិនឈ្មោះថា អសេក្ខធម៌ទេ ក្នុងបទនេះ ព្រះពុទ្ធអង្គទ្រង់សំដៅយកធម៌ដែលឈ្មោះថាអសេក្ខធម៌ដោយចំពោះប៉ុណ្ណោះ ដូច្នោះហើយ ចិត្ត ១៨ ដួងនេះ ទើបមិនសង្គ្រោះចូលក្នុងទុតិយបទ ។

សម្រាប់តតិយបទនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយអំណាចនៃភាពជាបដិបក្ខចំពោះបទទាំង ២ ។

## ចប់ សេក្ខត្តិកៈ

⑴ បដិសម្ភិទាមគ្គជាដើម ។

# ១២. បរិត្តត្តិកៈ

បឋមបទ. **បរិត្តា ធម្មា** ពួកធម៌មានសភាពតូចឆ្មារ បានដល់ កាមចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ ។

ទុតិយបទ. **មហគ្គតា ធម្មា** ពួកធម៌ដល់នៅសភាពធំ ឬ ដែលឈានលាភីបុគ្គលដ៏ប្រសើរទាំងឡាយចូលដល់ បានដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ ។

តតិយបទ. **អប្បមាណា ធម្មា** ពួកធម៌ប្រមាណមិនបាន ឬ ជាធម៌បដិបក្ខបំពោះកិលេស មានរាគៈជាដើមដែលធ្វើឱ្យមានប្រមាណ បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## អធិប្បាយបរិត្តត្តិកៈ

វិបនត្ថៈរបស់<u>បឋមបទ</u>៖

**សមន្តតោ ខណ្ឌិតត្តា អប្បមត្តកំ បរិត្តន្តិ វុច្ចតិ, បរិត្តំ គោមយបិណ្ឌន្តិ-អាទីសុ វិយ ។ ឥមេបិ អប្បានុភាវតាយ បរិត្តា វិយាតិ បរិត្តា, កាមាវចរធម្មានមេតំ អធិវចនំ** ។ វត្ថុមានប្រមាណតិចតួច ឈ្មោះថា បរិត្តៈ ព្រោះត្រូវកាត់ដោយជុំវិញ ដូចឧទាហរណ៍ថា **បរិត្តំ គោមយបិណ្ឌំ** (ដុំអាចម៍គោតូចជាដើម) សូម្បីកាមាវចរធម៌ទាំងនេះ ក៏ប្រៀបដូចនឹងវត្ថុដ៏តិចតួច ព្រោះមានអានុភាពតិច ។ ពាក្យថា បរិត្តៈនេះ ជាឈ្មោះនៃកាមាវចរធម៌ទាំងឡាយ ។

វិបនត្ថៈរបស់<u>ទុតិយបទ</u>៖

**កិលេសវិក្ខម្ភនសមត្ថតាយ, វិបុលផលតាយ, ទីឃសន្តានតាយ, ច មហន្តភាវំ គតា, មហន្តេហិ វា ឧឡារច្ឆន្ទវីរិយចិត្តបញ្ញេហិ គតា បដិបន្នាតិ មហគ្គតា** ។ ធម៌ទាំង

ឡាយដល់នូវភាពប្រសើរ (ឬ បរិបូរណ៍) ព្រោះអាចគ្របសង្កត់កិលេសបាន ១, ព្រោះមានផលដ៏ក្រៃលែង ១, ព្រោះកើតជាប់តគ្នាអស់ការដ៏យូរ ១, ឬធម៌ដែលបុគ្គលដ៏ប្រសើរ គឺ អ្នកមានឆន្ទៈ វីរិយៈ ចិត្តៈ និងបញ្ញាដ៏ក្រៃលែង បានសម្រេចហើយ ព្រោះហេតុនោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា មហគ្គតៈ ។

អធិប្បាយបទថា **កិលេសវិក្ខម្ភនសមត្ថតាយ** ព្រោះអាចគ្របសង្កត់កិលេសបាន, និងគ្របសង្កត់វិតក្កៈជាដើមបានផង (១) ។ បទនេះ សំដៅយកមហគ្គតកុសល ។

បទថា **វិបុលផលតាយ** ព្រោះមានផលដ៏ក្រៃលែង គឺ មហគ្គតកុសលឱ្យផលទៅបដិសន្ធិជាព្រហ្មច្រើនកោដិកប្ប, បទនេះ សំដៅយកមហគ្គតកុសល ។

បទថា **ទីឃសន្តានតាយ** ព្រោះកើតជាប់តគ្នាអស់ការដ៏យូរ គឺ មានការកើតជាប់តគ្នាដោយអំណាចនៃការចូលឈានសមាបត្តិ (មហគ្គតកុសល), ចំណែកឯវិបាកដែលជាភវង្គក្នុងព្រហ្មលោកនោះកើតជាប់តគ្នាអស់ជាច្រើនកប្ប,ឯមហគ្គតកិរិយាវិញ កើតជាប់តគ្នាអស់កាលដ៏យូរដោយអំណាចនៃការចូលឈានសមាបត្តិ (ព្រះអរហន្ត), ៣ បទនេះ សំដៅយកមហគ្គតកុសល, វិបាក និងកិរិយា (២) ។

វិបនត្ថៈរបស់<u>តតិយបទ</u>៖

**បមាណករា ធម្មា រាគាទយោ បមាណំ នាម, អារម្មណតោ វា សម្បយោគតោ វា នត្ថិ ឯតេសំ បមាណំ បមាណស្ស ច បដិបក្ខាតិ អប្បមាណា ។**

(១) ធម្មសង្គណីអនុដីកា៖ វិតក្កាទិវិក្ខម្ភនសមត្ថាបិ ហេត្ថ លព្ភតិ ។

(២) ធម្មសង្គណីមូលដីកា៖ កិលេសវិក្ខម្ភនសមត្ថតាយ, វិបុលផលតាយ, ទីឃសន្តានតាយាតិ អត្ថត្តយម្បិ កុសលេសុ យុជ្ជតិ ។ វិបាកកិរិយេសុ ទីឃសន្តានតាវ ។

ធម៌មានរាគៈជាដើម ខណៈធ្វើការប្រៀបធៀបគ្នា (ឬ មានភាពខុសគ្នា) ឈ្មោះថា បមាណធម៌,បមាណធម៌មិនមានដល់ធម៌ទាំងនោះដោយការកាន់យកជាអារម្មណ៍ ឬ ដោយការប្រកប ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា អប្បមាណៈ,ម្យ៉ាងទៀត ធម៌ពួកនេះជាបដិបក្ខបំពោះបមាណធម៌ ព្រោះហេតុនោះទើបឈ្មោះថា **អប្បមាណៈ** ។

# ចប់ បរិត្តត្តិកៈ

## ១៣. បរិត្តារម្មណត្តិកៈ

បឋមបទ. **បរិត្តារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍តូចឆ្មារ (មានបរិត្តធម៌ជាអារម្មណ៍តែម្យ៉ាង) (ឯកន្តៈ), ឬ ពួកធម៌មានអារម្មណ៍តូចឆ្មារ (មានបរិត្តធម៌ជាអារម្មណ៍) (អនេកន្តៈ), បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០, មនោធាតុ ៣, សន្តីរណចិត្ត ៣, មហាវិបាកចិត្ត ៨, ហសិតុប្បាទចិត្ត ១, ចេតសិក ៣៣ ខណៈធ្វើបរិត្តធម៌ឱ្យជាអារម្មណ៍<u>ដោយទៀងទាត់</u> ។ អកុសលចិត្ត ១២, មនោទ្វារាវជ្ជនចិត្ត ១, មហាកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨, អភិញ្ញាចិត្ត ២, ចេតសិក ៥០, (វៀរអប្បមញ្ញា) ខណៈធ្វើបរិត្តធម៌ឱ្យជាអារម្មណ៍ ។

ទុតិយបទ. **មហគ្គតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ដល់នូវសភាវៈធំ (មានមហគ្គតធម៌ជាអារម្មណ៍តែម្យ៉ាង) (ឯកន្តៈ), ឬ ពួកធម៌មានអារម្មណ៍ដល់នូវសភាវៈធំ (មានមហគ្គតធម៌ជាអារម្មណ៍) (អនេកន្តៈ), បានដល់ វិញ្ញាណញ្ចាយតនជ្ឈាន ៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣, ចេតសិក ៣០ ខណៈធ្វើមហគ្គតធម៌ឱ្យជាអារម្មណ៍<u>ដោយទៀងទាត់</u> ។ អកុសលចិត្ត ១២, មនោទ្វារាវជ្ជនចិត្ត ១, មហាកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨, អភិញ្ញាចិត្ត ២, ចេតសិក ៤៧, (វៀរវិរតិ និងអប្បមញ្ញា) ខណៈធ្វើមហគ្គតធម៌ឱ្យជាអារម្មណ៍ ។

តតិយបទ. **អប្បមាណារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន (មានអប្បមាណធម៌ជាអារម្មណ៍តែម្យ៉ាង) (ឯកន្តៈ), ឬ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន (មានអប្បមាណធម៌ជាអារម្មណ៍) (អនេកន្តៈ), បានដល់ លោកុត្តរចិត្ត ៨, ចេតសិក ៣៦, ខណៈធ្វើអប្បមាណធម៌ឱ្យជាអារម្មណ៍<u>ដោយទៀងទាត់</u> ។ មនោទ្វារាវជ្ជនចិត្ត ១, មហាកុសលញាណសម្បយុត្តចិត្ត ៤, មហាកិរិយាញាណ

សម្បយុត្តចិត្ត ៤, អភិញ្ញាចិត្ត ២, ចេតសិក ៣៣, (វៀរវិរតិ និងអប្បមញ្ញា) ខណៈធ្វើអប្បមាណធម៌ឱ្យជាអារម្មណ៍ ។

រូបាវចរចិត្ត ១៥ (វៀរអភិញ្ញា) អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣, ចេតសិក ៣៥, ដែលធ្វើបញ្ញត្តិឱ្យជាអារម្មណ៍ដោយទៀងទាត់ ។ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១, មហាកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨, អភិញ្ញាចិត្ត ២, ចេតសិក ៤៩, (វៀរវិរតិ) ក្នុងខណៈដែលធ្វើបញ្ញត្តិឱ្យជាអារម្មណ៍ ។ រូប ២៨, និព្វាន ជាតិកវិមុត្តិ ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## ចប់ បរិត្តារម្មណត្តិកៈ

## ១៤. ហីនត្តិកៈ

បឋមបទ. **ហីនា ធម្មា** ពួកធម៌ដ៏ថោកទាប បានដល់ អកុសលចិត្ត ១២, ចេតសិក ២៧ ។

ទុតិយបទ. **មជ្ឈិមា ធម្មា** ពួកធម៌យ៉ាងកណ្ដាល ឬ ពួកធម៌ដែលប្រព្រឹត្តទៅក្នុងចន្លោះធម៌ដ៏ថោកទាប និងដ៏ឧត្ដម បានដល់ លោកិយកុសលចិត្ត ១៧, លោកិយ-វិបាកចិត្ត ៣២, កិរិយាចិត្ត ២០, ចេតសិក ៣៨, រូប ២៨ ។

តតិយបទ. **បណីតា ធម្មា** ពួកធម៌ដ៏ឧត្ដម បានដល់ លោកុត្តរចិត្ត ៨, ចេតសិក ៣៦, និព្វាន ។

ត្រិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និងឈ្មោះថា **និប្បទេសត្តិកៈ** ។

## អធិប្បាយហីនត្តិកៈ

វចនត្ថៈរបស់<u>បឋមបទ</u>៖

**ហីនាតិ លាមកា, អកុសលា ធម្មា** ។ ពាក្យថា ហីនៈ មានន័យថា លាមក បានដល់ អកុសលធម៌ ។

វចនត្ថៈរបស់<u>ទុតិយបទ</u>៖

**ហីនប្បណីតានំ មជ្ឈេ ភវាតិ មជ្ឈិមា, អវសេសា តេភូមិកា ធម្មា** ។ ធម៌ដែលនៅក្នុងចន្លោះកណ្ដាលនៃធម៌ដ៏ថោកទាប និងដ៏ឧត្ដម ព្រោះហេតុនោះ ឈ្មោះថា មជ្ឈិមៈ បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសអំពីធម៌ដ៏ថោកទាប និងឧត្ដម ។

វចនត្ថៈរបស់<u>តតិយបទ</u>៖

**ឧត្តមដ្ឋេន អតប្បកដ្ឋេន ច បណីតា, លោកុត្តរា ធម្មា** ។ ធម៌ដ៏ប្រណីត

ព្រោះអត្ថថា ខ្ពង់ខ្ពស់ ១, ព្រោះអត្ថថា មិនបេះផ្អែត ១, (គឺ មិនធុញទ្រាន់) បានដល់ លោកុត្តរធម៌ ។

ពាក្យថា **អតប្បកដ្ឋេន** ព្រោះអត្ថថា មិនបេះផ្អែត មានសេចក្ដីថា លោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលពិចារណាអស់ទៅមួយថ្ងៃ ក៏មិនបេះផ្អែតដែរ ព្រោះជាធម៌ស្ងប់ (១) ។

## ចប់ ហីនត្តិកៈ

(១) ធម្មសង្គណីមូលដីកា ។

## ១៥. មិច្ឆត្តិកៈ

បឋមបទ. **មិច្ឆត្តនិយតា ធម្មា** ពួកធម៌មានសភាពខុស និងទៀង បានដល់ ជវនៈដួងទី ៧ របស់ទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង, ចេតសិក ២១ ដួង, ដែលកើតឡើងដោយអំណាចនៃនិយតមិច្ឆាទិដ្ឋិ និងជវនៈដួងទី ៧ របស់ទោសមូលចិត្ត ២ ដួង, ចេតសិក ២២ ដួង, ដែលកើតឡើងដោយអំណាចនៃបញ្ចានន្តរិយកម្ម គឺ សង្ឃភេទ លោហិតុប្បាទ អរហន្តឃាត មាតុឃាត និង បិតុឃាត ។

ទុតិយបទ. **សម្មត្តនិយតា ធម្មា** ពួកធម៌មានសភាពត្រូវ និងទៀង បានដល់ មគ្គចិត្ត ៤, ចេតសិក ៣៦ ។

តតិយបទ. **អនិយតា ធម្មា** ពួកធម៌មិនទៀង បានដល់ អកុសលចិត្ត ១២ (វៀរជវនៈដួងទី ៧ របស់ទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដែលកើតឡើងដោយអំណាចនៃនិយតមិច្ឆាទិដ្ឋិ និងជវនៈដួង ទី ៧ របស់ទោសមូលចិត្ត ២ ដែលកើតឡើងដោយអំណាចនៃបញ្ចានន្តរិយកម្ម) លោកិយកុសលចិត្ត ១៧, វិបាកចិត្ត ៣៦, កិរិយាចិត្ត ២០, ចេតសិក ៥២, រូប ២៨, និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## អធិប្បាយមិច្ឆត្តិកៈ

វិចនត្ថៈរបស់<u>បឋមបទ</u>៖

**ហិតសុខាវហា មេ ភវិស្សន្តីតិ ឯវំ អាសីសិតាបិ តថា អភាវតោ, អសុភាទីសុយេវ សុភន្តិអាទិវិបរិតប្បវត្តិតោ ច មិច្ឆាសភាវាតិ មិច្ឆត្តា ។**

ពាក្យថា **មិច្ឆត្តៈ** គឺ ធម៌មានសភាពខុស ឬ មានសភាពមិនពិត (មុសាសភាវៈ) ព្រោះបុគ្គល សូម្បីប្រាថ្នាទុកយ៉ាងនេះថា ធម៌ទាំងនេះ (មានការសម្លាប់មាតាជាដើម) នឹងនាំប្រយោជន៍ និងសេចក្ដីសុខមកឱ្យអាត្មាអញ តែក៏មិនអាចសម្រេចតាមសេចក្ដីប្រាថ្នាយ៉ាងនេះដែរ, និងព្រោះប្រព្រឹត្តទៅដោយអំណាចនៃការយល់ខុសថា ស្អាតក្នុងវត្ថុមិនស្អាតជាដើម ។

**វិបាកទានេ សតិ ខន្ធភេទានន្តរមេវ វិបាកទានតោ និយតា ។**

ពាក្យថា **និយតៈ** (គឺ ឱ្យផលទៀងទាត់) ព្រោះបើមានកាលឱ្យផល គឺ នាំទៅបដិសន្ធិក្នុងអបាយភូមិ ក៏នឹងឱ្យផលក្នុងលំដាប់នៃចុតិប៉ុណ្ណោះ ។ អធិប្បាយថា បើបុគ្គលបានធ្វើអនន្តរិយកម្មច្រើនយ៉ាង អនន្តរិយកម្មដែលមានកម្លាំងនឹងឱ្យផលមុនគេទាំងអស់ កម្មក្រៅពីនេះ ជាអហោសិកម្ម ព្រោះហេតុនោះ នរណាៗ ក៏មិនអាចនឹងពោលបានថា អនន្តរិយកម្មនេះជាសភាវៈទៀងទាត់ ដោយសភាពជាអ្នកធ្វើវិបាកឱ្យកើតឡើងតែម្យ៉ាង ព្រោះហេតុនោះ លោកទើបពោលថា **វិបាកទានេ សតិ**[១] ។

**មិច្ឆត្តា ច តេ និយតា ចាតិ មិច្ឆត្តនិយតា ។**

ពាក្យថា **មិច្ឆត្តនិយតៈ** គឺ ធម៌ទាំងឡាយនេះមានសភាពខុស និងឱ្យផលទៀងទាត់ក្នុងលំដាប់នៃចុតិ អធិប្បាយថា បើនឹងឱ្យផល ធម៌ទាំងនេះនឹងឱ្យផលទៀងទាត់ក្នុងលំដាប់នៃចុតិ គឺ ការអស់ទៅនៃជីវិតមិនមានចន្លោះ ទើបបានឈ្មោះថា **និយតៈ** ។

---

[១] ធម្មសង្គណីមូលដីកា ទំព័រ ៧៤ ថា ៖ អានន្តរិយេសុ កតេសុ យំ តត្ថ ពលវំ, តំ វិបច្ចតិ, ន ឥតរានីតិ ឯកន្តវិបាកជនកតាយ និយតា ន សក្កា វត្តុន្តិ **វិបាកទានេ សតី**តិ អាទិមាហ ។

**មិច្ឆត្តនិយតធម៌** បានដល់ និយតមិច្ឆាទិដ្ឋិកម្ម ៣ និង បញ្ចានន្តរិយកម្ម ៥ អកុសលកម្មដទៃៗ ក្រៅអំពីកម្មទាំង ២ នេះ មិនអាចឱ្យផលទៀងទាត់ក្នុងលំដាប់នៃចុតិបានឡើយ ។

**និយតមិច្ឆាទិដ្ឋិកម្ម** គឺ សត្វទាំងឡាយដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិ មានការយល់ឃើញខុស ដែលជាហេតុនាំទៅកាន់នរកដោយទៀងទាត់ ក្នុងលំដាប់នៃចុតិបាន មាន ៣ ប្រការ គឺ **នត្ថិកទិដ្ឋិ** (បដិសេធផល) មានការយល់ឃើញថា សត្វទាំងឡាយដែលបានទទួលសេចក្តីសុខ ឬ សេចក្តីទុក្ខក្នុងអនាគត មិនមែនជាផលនៃបុណ្យ និងបាបក្នុងបច្ចុប្បន្ននេះឡើយ, **អកិរិយទិដ្ឋិ** (បដិសេធកម្ម) មានការយល់ឃើញថា សត្វទាំងឡាយ ទោះបីធ្វើកុសលក៏មិនឈ្មោះថាជាកុសល ធ្វើអកុសលក៏មិនឈ្មោះថាជាអកុសល, **អហេតុកទិដ្ឋិ** (បដិសេធផល និងកម្ម) មានការយល់ឃើញថា សត្វកំពុងបានទទួលសេចក្តីសុខ ឬសេចក្តីទុក្ខ ក៏មិនឈ្មោះថាជាផលរបស់កម្ម, សេចក្តីសុខ ឬ សេចក្តីទុក្ខ គឺ សត្វទាំងឡាយបានទទួលក្នុងបច្ចុប្បន្នភពនេះ មិនមែនជាផលរបស់បុណ្យ និងបាបឡើយ ។ ទោះបីមានព្រះសម្មាសម្ពុទ្ធ ១០០ អង្គកើតឡើងក្នុងលោកក៏ដោយ មិនអាចធ្វើនិយតមិច្ឆាទិដ្ឋិកបុគ្គលនេះ ឱ្យសម្រេចគុណធម៌បានទេ ព្រោះជាធម៌ហាមឃាត់សួគ៌ (សគ្គាវរណៈ) និងហាមមគ្គ(មគ្គាវរណៈ) សមដូចព្រះអដ្ឋកថាចារ្យពោលទុកថា **ឥមានិ ទ្វេ សគ្គមគ្គានំ អាវរណតោ អាវរណានិ** [១] ប្រែថា កម្ម ២ យ៉ាងនេះ គឺ បញ្ចានន្តរិយកម្ម និងនិយតមិច្ឆាទិដ្ឋិកម្ម ឈ្មោះថា **អាវរណៈ** ព្រោះជាគ្រឿងរារាំងមិនឱ្យដល់នូវឋានសួគ៌ និងការសម្រេចមគ្គ ជាបុគ្គលអភ័ព្វ ។ និយតមិច្ឆាទិដ្ឋិកបុគ្គលនេះ លោកហៅថា **វដ្ដខាណុ** ប្រែថា ជាដង្គត់នៃវដ្ដៈ ឬ ជាអ្នក

---

[១] សទ្ធម្មប្បកាសិនី ជាអដ្ឋកថារបស់បដិសម្ភិទាមគ្គ ។

រក្សាផែនដី (បឋវីគោបកោ) គឺ ដោយច្រើន មិនអាចរួចផុតអំពីវដ្ដៈបានឡើយ(១) ។ អធិប្បាយថា មិច្ឆាទិដ្ឋិខ្លះ ហាមឋានសួគ៌ និងហាមមគ្គ ។ មិច្ឆាទិដ្ឋិខ្លះ ហាមតែមគ្គ មិនហាមឋានសួគ៌ ។ មិច្ឆាទិដ្ឋិខ្លះ មិនហាមឋានសួគ៌ និងមិនហាមមគ្គ (២) ។

បណ្ដាទិដ្ឋិទាំង ៣ នេះ គឺ បុគ្គលណាកាន់យកទិដ្ឋិនេះរួចហើយ អង្គុយស្វាធ្យាយ ពិចារណាទាំងយប់ទាំងថ្ងៃ មិច្ឆាសតិរបស់បុគ្គលនោះ ក៏តាំងមាំដោយល្អថា ការឱ្យទានមិនមានផល, ការបូជាតូច និងបូជាធំ មិនមានផល, ឋានសួគ៌មិនមាន, នរកមិនមាន, លោកនេះ និងបរលោកមិនមាន, ការប្រព្រឹត្តិបដិបត្តិបំពោះមាតាបិតាមិនមានផល, បុគ្គលកើតមកមានតែត្រឹមជាតិនេះ ក្រោយអំពីស្លាប់ហើយ ក៏សូន្យទទេ មិនកើតទៀតឡើយ, ធ្វើល្អ និងអាក្រក់មានប៉ុនណាក៏ដោយ ក៏កំណត់ត្រឹមស្លាប់ប៉ុណ្ណោះ <u>អជិតកេសកម្ពល</u> ជាអ្នកប្រកាន់**នត្ថិកទិដ្ឋិ** ។ បុគ្គលធ្វើបាបក៏មិនឈ្មោះថាបាប ធ្វើបុណ្យក៏មិនមានបុណ្យ សូម្បីធ្វើបុណ្យ និងបាបប៉ុនណាក៏ដោយ គ្មានបុណ្យនិងបាបទេ ដូចជាអាត្មាអញ នៅស្ងៀមៗដល់ពេលក៏សម្រេចជាព្រះអរហន្តឯងៗ លាភសក្ការៈកើតយ៉ាងច្រើន ព្រោះហេតុមិនស្លៀកដណ្ដប់សំពត់ជាបច្ច័យ <u>បូរណកស្សបៈ</u> ជាអ្នកប្រកាន់**អកិរិយទិដ្ឋិ** ។ សត្វទាំងឡាយបរិសុទ្ធ និងសៅហ្មងបានមិនបាច់មានហេតុមានបច្ច័យទេ <u>មក្ខលិគោសាល</u> ជាអ្នកប្រកាន់**អហេតុកទិដ្ឋិ** (៣) ។

---

(១) ឧបរិបណ្ណាសកៈអដ្ឋកថា ៖ វដ្ដខាណុ នាមេសោ សត្តោ បឋវីគោបកោ យេភុយ្យេន ឯវរូបស្ស ភវតោ វុដ្ឋានំ នត្ថិ ។

(២) ឯកនិបាតអង្គុត្តរនិកាយពោលថា ៖ ឯកច្ចា មិច្ឆាទិដ្ឋិ សគ្គាវរណា ចេវ ហោតិ មគ្គាវរណា ច, ឯកច្ចា មគ្គាវរណាវ, ន សគ្គាវរណា, ឯកច្ចា នេវ សគ្គាវណា, ន មគ្គាវរណា ។

(៣) កន្លែងនេះ ប្រែទាំងព្រះបាឡី, អដ្ឋកថា, និងសារត្ថសង្គហៈ ភាគ ២ ផ្សំចូលគ្នា ។

ចិត្តជាឯកគ្គតាក្នុងអារម្មណ៍នោះតែមួយ ជវនៈចិត្តទាំងឡាយក៏ស្ទុះទៅ, ក្នុងជវនៈដួងទី ១ ដល់ ទី ៦ អាចកែបាន (សតេកិច្ឆា), បើដល់ជវនៈដួងទី ៧ ហើយ សូម្បីព្រះសម្មាសម្ពុទ្ធក៏ជួយមិនបានដែរ(អតេកិច្ឆា) ដូចជាព្រះអរិដ្ឋៈនិងសាមណេរកណ្ឌកៈ, ពាក្យនេះ ត្រឹមតែជាការសម្ដែងសភាវៈធម៌ប៉ុណ្ណោះ តែខណៈនោះ នរណាៗ មិនអាចនឹងជួយបុគ្គលនេះបានឡើយ(១) ។

**បញ្ចានន្តរិយកម្ម** គឺ អកុសលធម៌ ៥ យ៉ាង ដែលនឹងនាំទៅកាន់និរយភូមិក្នុងលំដាប់នៃចុតិមិនមានចន្លោះ ៥ យ៉ាងនោះ បានដល់ **សង្ឃភេទ** បំបែកសង្ឃ, **លោហិតុប្បាទ** ធ្វើលោហិតព្រះពុទ្ធឱ្យពុរពង, **អរហន្តឃាត** សម្លាប់ព្រះអរហន្ត, **មាតុឃាត** សម្លាប់មាតា, **បិតុឃាត** សម្លាប់បិតា ។

ក្នុងកម្មទាំង ២ យ៉ាងនោះ បើពោលដោយប្រភេទហើយក៏មាន ៨ យ៉ាង បុគ្គលណាក៏ដោយ បានធ្វើកម្មទាំង ៨ យ៉ាងនោះណាមួយក្តី **មរណាសមយេ** ក្នុងកាលអស់ទៅនៃជីវិត បុគ្គលនោះ ត្រូវតែបានទទួលផលនៃកម្មនោះជាបន្ទាន់ ទោះបីកាលមុននឹងស្លាប់ បុគ្គលនេះ បានកសាងព្រះចេតិយមាសខ្ពស់ប៉ុនភ្នំសុមេរុ និងបានប្រគេនចង្ហាន់ចំពោះព្រះសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធានដែលមាននៅក្នុងចក្រវាឡនេះទាំងអស់ គឺ ពេញចក្រវាឡ មកថ្វាយបច្ច័យ ៤ គ្រប់ៗព្រះអង្គ ដរាបអស់នៃជីវិត ក៏មិនអាចនឹងហាមវិបាករបស់កម្មដោយកុសលនោះបានឡើយ ប៉ុន្តែ អនន្តរិយកម្មដែលមានកម្លាំង ក៏នឹងហាមអនន្តរិយកម្មដទៃបាន ព្រោះហេតុនោះ និយតមិច្ឆាទិដ្ឋិ

(១) អដ្ឋកថាសាមញ្ញសូត្រជាដើមពោលថា៖ បឋមជវនេ សតេកិច្ឆា ហោន្តិ, តថា ទុតិយាទីសុ, សត្តមេ ពុទ្ធានម្បិ អតេកិច្ឆា អរិដ្ឋកណ្ឌកសទិសា ។ ដីកាអធិប្បាយថា ៖ បឋមជវនេ សតេកិច្ឆា ហោន្តិ តថា ទុតិយាទីសូតិ ធម្មសភាវទស្សនមត្តមេវ ។ ន បន តស្មឹ ខណេ តេសំ សតេកិច្ឆាភាវាបាទានំ កេនចិ សក្កា កាតុំ ។

កម្ម និងអនន្តរិយកម្ម ឈ្មោះថា មិច្ឆត្តនិយតធម៌ ព្រោះនាំទៅបដិសន្ធិក្នុងនិរយភូមិ ដោយមិនមានចន្លោះ ព្រោះកម្មទាំងនេះ ជាអ្នកហាមមិនឱ្យសម្រេចមគ្គផល និងមហគ្គតៈ(១) ។ សរុបបានថា អង្គធម៌របស់បឋមបទ បានត្រឹមតែនិយតមិច្ឆាទិដ្ឋិកម្ម និងបញ្ចានន្តរិយកម្មប៉ុណ្ណោះ ។ អធិប្បាយថា បុគ្គលណាបានធ្វើនិយតមិច្ឆាទិដ្ឋិកម្មណាមួយ ឬ ទាំង ៣ យ៉ាងក្តី ការឱ្យផលរបស់កម្មទាំងនោះ រមែងស្មើគ្នាទាំងអស់ គឺ មានកម្លាំងស្មើគ្នា និងឱ្យផលស្មើគ្នា (សមានពលតំ, សមានផលតញ្ច) បំណែកឯ បញ្ចានន្តរិយកម្មទាំង ៥ យ៉ាងនោះ កម្មណាមួយឱ្យផលហើយ កម្មដ៏សេសក៏ជាអហោសិកម្ម តែទោះជាយ៉ាងណាក៏ដោយ បញ្ចានន្តរិយកម្មដ៏សេសដែលជាអហោសិកម្មនេះ នឹងសង្គ្រោះចូលជាអង្គធម៌របស់តតិយបទមិនបានទេ ត្រូវតែជាអង្គធម៌របស់បឋមបទនោះឯង ព្រោះការឱ្យផលរបស់បញ្ចានន្តរិយកម្មដែលហៅថា អហោសិកម្មនេះ បើនឹងឱ្យផលត្រូវតែឱ្យក្នុងលំដាប់នៃចុតិប៉ុណ្ណោះ នឹងឱ្យផលក្នុងកាលដទៃៗ មិនបានឡើយ ។

អធិប្បាយថា អនន្តរិយកម្ម ៥ នេះ ប្រសិនបើ បុគ្គលណាបានធ្វើទាំង ៥ ប្រការ បុគ្គលនោះក្រោយអំពីស្លាប់ ទោសនៃសង្ឃភេទនេះ ជាតួតាក់តែងបដិសន្ធិឱ្យកើតឡើងក្នុងអវីចិមហានរកអស់កាលដ៏យូរ ដរាបអស់វិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។ កម្ម ៤ យ៉ាង ដ៏សេសទៀត ជាអហោសិកម្ម គឺ មិនមានផល មិនមានវិបាក(២) ។ ក៏អហោសិកម្មមាន ៣ ប្រការ គឺ កម្មបានសម្រេចហើយ វិបាករបស់កម្មនោះ មិនបានឱកាសឱ្យផល, កម្មបានសម្រេចហើយ វិបាករបស់កម្ម នឹងមិនមានឱកាសឱ្យផល,

---

(១) មោហវិច្ឆេទនី ។

(២) សារត្ថសង្គហៈ ភាគ ២ ទំព័រ ៤២ ។

កម្មបានសម្រេចហើយ វិបាករបស់កម្មនោះ រមែងមិនមានឱកាសឱ្យផល(១) ។ មានន័យថា កម្មនោះនៅមាន ពោលគឺ កម្មដែលសត្វបានធ្វើរួចហើយ ជាអតីត ឬ បច្ចុប្បន្ន បានដល់ ចេតនាក្នុងជវនៈដួងទី ១ មានឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ឬ ជវនៈដួងទី ៧ ដែលមានឈ្មោះថា ឧបបជ្ជវេទនីយកម្ម សមគួរឱ្យផលក្នុងបច្ចុប្បន្ន តែមិនមានឱកាសឱ្យផល, ឬ មានតែកម្ម មិនបានការឱ្យផល គឺ កម្មដែលសត្វបានធ្វើរួចហើយ ជាអតីត ឬ បច្ចុប្បន្ន សមគួរនឹងឱ្យផលក្នុងអនាគត តែក៏ឱ្យផលមិនបាន ព្រោះអស់ឱកាស ឬ ហួសឱកាស ឈ្មោះថា អហោសិកម្ម(២) ។

បើបុគ្គលមិនបានធ្វើសង្ឃភេទ ធ្វើតែអនន្តរិយកម្ម ៤ ដ៏សេសទៀត លោហិតុប្បាទជាអ្នកឱ្យផលនាំទៅបដិសន្ធិក្នុងអវីចិមហានរក កម្ម ៣ ដ៏សេស ក៏ជាអហោសិកម្ម ។ បើមិនបានធ្វើសង្ឃភេទនិងលោហិតុប្បាទ ធ្វើតែអនន្តរិយកម្ម ៣ ដ៏សេស គឺ អរហន្តឃាត, មាតុឃាត, និងបិតុឃាត បុគ្គលនោះក្រោយអំពីស្លាប់ អរហន្តឃាតនេះ ជាអ្នកឱ្យផលនាំទៅបដិសន្ធិក្នុងអវីចិមហានរក កម្ម ២ ដ៏សេសទៀត ក៏ជាអហោសិកម្ម ។ បណ្ឌិតគប្បីជ្រាបថា បើសម្លាប់ព្រះសោតាបន្ន សកទាគាមី និង អនាគាមីបុគ្គល មិនជាអនន្តរិយកម្មទេ តែកម្មនេះធ្ងន់ គឺ ស្មើនឹងអនន្តរិយកម្មដូចគ្នា (៣) ។

---

(១) សទ្ធម្មប្បកាសិនី ជាអដ្ឋកថារបស់បដិសម្ភិទាមគ្គថា ៖ **អហោសិ កម្មំ នាហោសិ កម្មវិបាកោ, ន ភវិស្សតិ កម្មវិបាកោ, នត្ថិ កម្មវិបាកោតិ ឥមស្ស តិកស្ស វសេន អហោសិកម្មំ នាម ហោតិ** ។

(២) កន្លែងនេះ ប្រែទាំងអដ្ឋកថាតិកនិបាតជាដើម, ដីកា, និងសារត្ថសង្គហៈ ផ្សំចូលគ្នា ។

(៣) សារត្ថសង្គហៈ ភាគ ២ ទំព័រ ២៤, ឬ អដ្ឋកថាឧបរិបណ្ណាសកៈពោលថា ៖ សេសរិយបុគ្គលេ មារេន្តស្ស អានន្តរិយំ នត្ថិ, កម្មំ បន ភារិយំ អានន្តរិយសទិសមេវ ។

ប្រសិនបើបុគ្គលបានធ្វើអនន្តរិយកម្មទាំង ២ គឺ មាតុឃាត, និងបិតុឃាត ក្រោយអំពីស្លាប់ទៅ ជួនកាលមាតុឃាត ជាអ្នកឲ្យផល, ជួនកាលបិតុឃាត ជាអ្នកឲ្យផលដោយអំណាចនៃបដិសន្ធិក្នុងអវីចិមហានរក(១) ។ សមដូចព្រះអដ្ឋកថាចារ្យពោលទុកថា ៖

**សចេ បិតា សីលវា ហោតិ, មាតា ទុស្សីលា, តោ វា តថា សីលវតី, បិតុឃាតោ <u>បដិសន្ធិវសេន វិបច្ចតិ</u>, សចេ មាតាបិតុឃាតោ, ទ្វីសុបិ សីលេន វា ទុស្សីលេន វា សមានេសុ មាតុឃាតោវ <u>បដិសន្ធិវសេន វិបច្ចតិ</u>, មាតា ហិ ទុក្ករការិនី ពហូបការា ច បុត្តានំ** (២) ។

ប្រែថា ប្រសិនបើ បិតាមានសីល រក្សាសីលមានល្អ, ឯមាតាជាអ្នកទ្រុស្តសីល មិនបានរក្សាសីល បើយ៉ាងនេះ បិតុឃាត ជាអ្នកឲ្យផល ដោយអំណាចនៃបដិសន្ធិក្នុងអវីចិមហានរក រងទុក្ខវេទនាដ៏ក្រៃលែង, បើមាតា និងបិតាមានសីលស្មើគ្នាក្តី ឬទ្រុស្តសីលដូចគ្នាក្តី មាតុឃាតប៉ុណ្ណោះ ជាអ្នកឲ្យផល ដោយអំណាចនៃបដិសន្ធិក្នុងអវីចិមហានរក ។ ពិតណាស់ មាតានិងបិតានោះ សូម្បីលោកទាំង ២ ជាមនុស្សអាក្រក់ ជាអ្នកទ្រុស្តសីលដូចគ្នាក៏ដោយ, មាតុឃាតនេះ មានកម្លាំងជាងបិតុឃាត ព្រោះថាមាតានោះ មានគុណច្រើនជាងក្នុងការចិញ្ចឹមកូនប្រុសស្រី មានសេចក្តីលំបាកជាងបិតា ចាប់ផ្តើមតាំងតែកូនមកចុះចាប់បដិសន្ធិនៅក្នុងផ្ទៃមាតា បានសេចក្តី

---

(១) <u>បណ្ឌិតគប្បីជ្រាបថា</u> ពាក្យថា **អហោសិកម្ម** ប្រែថា មិនមានផល មិនមានវិបាកនេះ លោកសំដៅយកតែក្នុងបដិសន្ធិកាលប៉ុណ្ណោះ គឺ មិនឲ្យផល ក្នុងបដិសន្ធិកាល ព្រោះមានពាក្យអធិប្បាយទុកក្នុងគម្ពីរអដ្ឋកថា ឧបរិបណ្ណាសកៈថា ៖ **បដិសន្ធិវសេន វិបច្ចតិ** ប្រែថា ឲ្យផលបានតែក្នុងបដិសន្ធិកាល ។ ឯបវត្តិកាលវិញ ឈ្មោះថា មិនឲ្យផលមិនមានឡើយ ព្រោះថា កម្មឲ្យផលបាន ២ កាល គឺ បដិសន្ធិកាល និងបវត្តិកាល ។

(២) ឧបរិបណ្ណាសកអដ្ឋកថា ។

លំបាកជាច្រើន សោយទុក្ខវេទនាជានិច្ចកាលរាល់កិច្ចទាំងអស់ ដែលមាតាសង្គ្រោះដល់កូនប្រុសស្រីនោះ អ្នកដទៃមិនអាចធ្វើបានឡើយ ព្រោះហេតុនោះ បើមាតានិងបិតា ជាអ្នកទ្រុស្តសីលស្មើគ្នា មាតុឃាតនេះ ជាអ្នកឱ្យផលនាំទៅបដិសន្ធិក្នុងអវីចីមហានរក ឯបិតុឃាតវិញ ជាអហោសិកម្ម មិនមានផល មិនមានវិបាក ក្នុងបដិសន្ធិកាល(១) ។

អនន្តរិយកម្ម ៤ ប្រការខាងដើម គឺ លោហិតុប្បាទ អរហន្តឃាត មាតុឃាត និងបិតុឃាតជាសាធារណៈទូទៅដល់គ្រហស្ថ និងបព្វជិត អធិប្បាយថា ទាំងគ្រហស្ថ ទាំងបព្វជិតក៏ធ្វើបាន ។ ឯសង្ឃភេទវិញ ជាអសាធារណៈ គឺ ធ្វើបានតែបំពោះព្រះសង្ឃប៉ុណ្ណោះ ក្រៅអំពីព្រះសង្ឃធ្វើមិនបានឡើយ តែកម្មនេះ មានទោសស្មើនឹងអនន្តរិយកម្ម ព្រោះចិត្តជាអកុសល, ដោយពាក្យថា **ជាដើម** (អាទិសទ្ទ) គប្បីជ្រាបថាកម្មនេះទាំងអស់ កើតឡើងដោយកម្លាំងនៃសេចក្តីក្រោធ និងដោយអំណាចនៃសេចក្តីវង្វេង ទើបកើតឡើងតែក្នុងទោសមូលចិត្តប៉ុណ្ណោះ មានវេទនាជាទោមនស្សសម្បយុត្តដោយទោសមូល និងមោហមូល (២) ។

វិបនត្ថៈរបស់ទុតយបទ ៖

**វុត្តវិបរីតេន អត្ថេន សម្មាសភាវាតិ សម្មត្តា ។**

(១) កន្លែងនេះ ប្រែទាំងអដ្ឋកថាឧបរិបណ្ណាសកៈ និងសារត្ថសង្គហៈ ភាគ ២ / ៤៥ ផ្សំចូលគ្នា។

(២) ឧបរិបណ្ណាសកៈអដ្ឋកថា ៖ បុរិមានិ ចត្តារិ សព្វេសំបិ គហដ្ឋបព្វជិតានំបិ សាធារណានិ, សង្ឃភេទោ បន ន ខោ ឧបាលិ ភិក្ខុនី សង្ឃំ ភិន្ទតិ, ន សិក្ខមានា, ន សាមណេរី, ន សាមណេរា, ន ឧបាសកា, ន ឧបាសិកា, សង្ឃំ ភិន្ទតិ, ភិក្ខុ ខោ ឧបាលិ បកតត្តោ សមានសំវាសោ សមានសីមាយំ ឋិតោ សង្ឃំ ភិន្ទតិ, **អាទិសទ្ទេន** សព្វេបិ តេ ទុក្ខវេទនាសហគតា ទោសមោហសម្បយុត្តា ច ។

ឈ្មោះថា **សម្មត្តៈ** ព្រោះមានអត្ថថា ជាធម៌ដែលមានសភាវៈដ៏ល្អ គឺ ត្រឹមត្រូវ ដោយអត្ថផ្ទុយគ្នានឹងមិច្ឆត្តានុ៎ះឯង ។

**សម្មត្តា ច តេ និយតា ច អនន្តរមេវ ផលទានេនាតិ សម្មត្តនិយតា ។** ឈ្មោះថា **សម្មត្តនិយតៈ** ព្រោះមានអត្ថថា ជាធម៌ដែលមានសភាពល្អ និងឱ្យផលទៀងទាត់ ដោយការឱ្យផលមិនមានចន្លោះ គឺ ក្រោយអំពីខ្លួនរលត់ទៅនុ៎ះឯង បានដល់ មគ្គចិត្ត ៤, ចេតសិក ៣៦ ។

អធិប្បាយថា **សម្មត្តនិយតធម៌**នេះ ជាធម៌មានសភាពល្អ និងឱ្យផលទៀងទាត់ក្នុងលំដាប់នៃខ្លួននោះ មានតែមគ្គចិត្ត ៤, ចេតសិក ៣៦ ប៉ុណ្ណោះ បានដល់ ផលចិត្ត ៤ នោះឯង ។ ចំណែកឯ លោកិយកុសល ជាធម៌ដែលមានសភាពល្អ និងឱ្យផលទាំងភពនេះ និងបរលោកបាន ក៏ពិតមែន តែការឱ្យផលនៃលោកិយកុសលនេះ មិនទៀង-ទាត់, និងប្រព្រឹត្តទៅជាប់ទាក់ទងនឹងកាល, ទើបមិនអាចជាអង្គធម៌របស់ទុតិយបទបានទេ ។

វិបន្តៈរបស់តតិយបទ ៖

**ឧភយថាបិ ន និយតាតិ អនិយតា ។**

ឈ្មោះថា **អនិយតៈ** ព្រោះមានអត្ថថា ជាធម៌ឱ្យផលមិនទៀងទាត់ ដោយអាការទាំង ២ ប្រការនោះឯង ។

## ចប់ មិច្ឆត្តត្តិកៈ

## ១៦. មគ្គារម្មណត្តិកៈ

បឋមបទ. **មគ្គារម្មណា ធម្មា** ពួកធម៌មានមគ្គជាអារម្មណ៍ បានដល់ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ កុសលអភិញ្ញាចិត្ត ១ ចេតសិក ៣៣ (វិរតិ និងអប្បមញ្ញា) របស់ព្រះសោតាបន្នបុគ្គលដែលធ្វើសោតាបត្តិមគ្គឱ្យជាអារម្មណ៍ ។

មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ កុសលអភិញ្ញាចិត្ត ១ ចេតសិក ៣៣ (វិរតិ និងអប្បមញ្ញា) របស់ព្រះសកទាគាមិបុគ្គលដែលធ្វើសោតាបត្តិមគ្គ និងសកទាគាមិមគ្គឱ្យជាអារម្មណ៍ ។

មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ កុសលអភិញ្ញាចិត្ត ១ ចេតសិក ៣៣ (វិរតិ និងអប្បមញ្ញា) របស់ព្រះអនាគាមិបុគ្គលដែលធ្វើសោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គឱ្យជាអារម្មណ៍ ។

មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ កិរិយាអភិញ្ញាចិត្ត ១ ចេតសិក ៣៣ (អប្បមញ្ញា) របស់ព្រះអរហន្តបុគ្គលដែលធ្វើមគ្គទាំង ៤ ឱ្យជាអារម្មណ៍ ។

ទុតិយបទ. **មគ្គហេតុកា ធម្មា** ពួកធម៌មានមគ្គជាហេតុ ព្រោះមានអង្គមគ្គ ៨ ជាបច្ច័យមានសម្បយុត្តប្បច្ច័យជាដើមដោយពិសេស ។ ឬ ធម៌ដែលមានហេតុប្រកបដោយមគ្គ ឬ ធម៌មានហេតុដែលតាំងហើយក្នុងមគ្គ [១] ។

---

[១] កន្លែងនេះ ក្នុងសៀវភៅមាតិកាជោតិកៈ មានការសម្ដែងដល់ ៣ ន័យ ហើយទាំង ៣ ន័យនេះ សម្ដែងអង្គធម៌ផ្សេងៗគ្នា គឺ៖

តាមន័យទី ១ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ២៨ (អង្គមគ្គ ៨)

តាមន័យទី ២ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ៣៤ (អលោភៈ និងអទោសៈ)

មួយវិញទៀត ធម៌មានហេតុ គឺ មគ្គ ព្រោះសម្មាទិដ្ឋិ ខ្លួនឯង ជាមគ្គផង ជាហេតុផង ។

-តាមន័យទី ១ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ២៨ (អង្គមគ្គ ៨)

-តាមន័យទី ២ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ៣៣ (អលោភៈ អទោសៈ និងអមោហៈ)

-តាមន័យទី ៣ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ៣៥ (អមោហៈ) ⑴ ។

---

តាមន័យទី ៣ អង្គធម៌ គឺ មគ្គចិត្ត ៤, ចេតសិក ៣៥ (បញ្ញា) ។

បណ្ឌិតគប្បីជ្រាបថា ពាក្យនេះ មិនស្របតាមព្រះបាឡីក្នុងគម្ពីរធម្មសង្គណីដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងថា៖ **អរិយមគ្គសមង្គិស្ស អលោភោ អទោសោ អមោហោ ឥមេ ធម្មា មគ្គហេតូ, តំសម្បយុត្តោ វេទនាក្ខន្ធោ ។បេ។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គហេតុកា ។** ប្រែថា ធម៌ទាំងនេះ គឺ អលោភៈ អទោសៈ អមោហៈ របស់បុគ្គលដែលដល់ព្រមដោយអរិយមគ្គ ឈ្មោះថា មគ្គហេតុ ។ អធិប្បាយថា ហេតុ គឺ អលោភៈ និងអទោសៈដែលប្រកបដោយមគ្គ, និងហេតុ គឺ អមោហៈ ដែលតាំងហើយក្នុងមគ្គ, វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយហេតុនោះ ធម្មទាំងនេះ ឈ្មោះថា មគ្គហេតុកៈ (មានហេតុដែលប្រកបដោយមគ្គ និងមានហេតុដែលតាំងហើយក្នុងមគ្គ) ។

សរុបសេចក្តីថា តាមព្រះបាឡីដែលបានសាធកៈមកនេះ សមគួរប្រែ និងសម្តែងអង្គធម៌ក្នុងបទតែមួយប៉ុណ្ណោះ ។

⑴ កន្លែងនេះ ក្នុងសៀវភៅមាតិកាជោតិកៈ មិនបានសម្តែងន័យនេះទេ តែសមគួរនឹងមានព្រោះមានព្រះបាឡីក្នុងគម្ពីរធម្មសង្គណី សម្តែងទុកថា ៖ អរិយមគ្គសមង្គិស្ស សម្មាទិដ្ឋិ

តតិយបទ. **មគ្គាធិបតិនោ ធម្មា** ពួកធម៌មានមគ្គជាអធិបតី ព្រោះមានមគ្គជាអារម្មណាធិបតី, ឬ មានមគ្គជាសហជាតាធិបតី, ឬ មគ្គនោះឯង ជាសហជាតាធិបតិប្បច្ច័យ ⑵ ។

-<u>តាមន័យទី</u> ១ អង្គធម៌ គឺ មហាកុសលញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៣ (វិរតិ,អប្បមញ្ញា) របស់ព្រះសោតាបន្នបុគ្គលដែលធ្វើសោតាបត្តិមគ្គឱ្យជាអារម្មណ៍ដោយអារម្មណាធិបតី ។

មហាកុសលញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៣ (វៀរវិរតិ អប្បមញ្ញា) របស់ព្រះសកទាគាមិបុគ្គលដែលធ្វើសកទាគាមិមគ្គឱ្យជាអារម្មណ៍ ដោយអារម្មណាធិបតី ។

មហាកុសលញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៣ (វិរតិ អប្បមញ្ញា) របស់ព្រះអនាគាមិបុគ្គលដែលធ្វើអនាគាមិមគ្គឱ្យជាអារម្មណ៍ ដោយអារម្មណាធិបតី ។

មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៣ (វិរតិ និងអប្បមញ្ញា) របស់

---

<u>មគ្គោ</u> ចេវ <u>ហេតុ</u> ច សម្មាទិដ្ឋី ឋបេត្វា តំសម្បយុត្តោ វេទនាក្ខន្ធោ ។ល។ វិញ្ញាណក្ខន្ធោ ឥមេ ធម្មា មគ្គហេតុកា ។ សម្មាទិដ្ឋិ ជាមគ្គផង ជាហេតុផង របស់បុគ្គលដែលព្រមដោយអរិយមគ្គ, វេទនាខន្ធ ។ល។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយហេតុនោះ វៀរសម្មាទិដ្ឋិ ធម្មទាំងនេះ ឈ្មោះថា មគ្គហេតុកៈ ។ <u>ធម្មសង្គណីមូលដីកាអធិប្បាយថា</u> ៖ អរិយមគ្គសមង្គិស្ស សម្មាទិដ្ឋិ មគ្គោ ចេវ ហេតុ ចាតិអាទិនា បន វុត្តនយំ ទស្សេតុំ សម្មាទិដ្ឋិ សយន្តិអាទិមាហ ។ ប្រែថា ព្រះអដ្ឋកថាចារ្យពោលថា សម្មាទិដ្ឋិ សយំ ជាដើម ដើម្បីសម្តែងន័យដែលបានពោលហើយ ដោយពាក្យថា អរិយមគ្គសមង្គិស្ស សម្មាទិដ្ឋិ មគ្គោ ចេវ ហេតុ ច ។ (សម្មាទិដ្ឋិ ជាមគ្គផង ជាហេតុផង របស់បុគ្គលដែលព្រមដោយអរិយមគ្គជាដើម) ។

⑵ ត្រង់នេះ ប្រែផ្សំជាមួយគ្នានឹងធម្មសង្គណីមូលដីកា ទាក់ទងនឹងអារម្មណាធិប្បតី និងសហជាតាធិប្បតី ។

ព្រះអរហន្តបុគ្គលដែលធ្វើអរហត្តមគ្គឱ្យជាអារម្មណ៍ដោយអារម្មណាធិបតី ។

-<u>តាមន័យទី</u> ២ អង្គធម៌ គឺ មគ្គចិត្ត ៤ ចេតសិក ៣៥ (វៀរវីរិយៈ ឬ បញ្ញា ខណៈជាអធិបតី) ។

-<u>តាមន័យទី</u> ៣ អង្គធម៌ គឺ វីរិយចេតសិក និងបញ្ញាចេតសិកខណៈជាអធិបតី ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## អធិប្បាយមគ្គារម្មណត្តិកៈ

ពាក្យថា មគ្គ មានវិបនត្ថៈថា៖ **និព្វានំ មគ្គតិ គវេសតីតិ មគ្គោ** ឈ្មោះថា មគ្គ ព្រោះមានអត្ថថា ស្វែងរកព្រះនិព្វាន ។

ឬមួយវិញទៀត៖ **កិលេសេ មារេន្តោ គច្ឆតីតិ មគ្គោ** ឈ្មោះថា មគ្គ ព្រោះមានអត្ថថា សម្លាប់ កិលេសហើយ ក៏ទៅរកព្រះនិព្វាន ។

ឬ **និព្វានត្ថិកេហិ មគ្គីយតីតិ មគ្គោ** ឈ្មោះថា មគ្គ ព្រោះមានអត្ថថា អ្នកដែលប្រាថ្នាព្រះនិព្វានត្រូវតែស្វែងរក (មគ្គប៉ុណ្ណោះ) អង្គធម៌វិបនត្ថៈទាំង ៣ នេះ បានដល់អរិយមគ្គមានអង្គ ៨ នុ៎ះឯង ។

វិបនត្ថៈរបស់<u>បឋមបទ</u>៖

**មគ្គោ អារម្មណំ ឯតេសន្តិ មគ្គារម្មណា** ឈ្មោះថា **មគ្គារម្មណៈ** ព្រោះមានអត្ថថា ជាធម៌ដែលមានមគ្គជាអារម្មណ៍ ។

ការសម្តែងអង្គធម៌ ក្នុងបឋមបទដែលចាំបាច់ញែកព្រះអរិយបុគ្គលចេញជា-មួយៗនោះ ព្រោះហេតុថា ព្រះអរិយបុគ្គលថ្នាក់ក្រោមៗ មិនអាចធ្វើអរិយមគ្គខាងលើឱ្យជាអារម្មណ៍បានទេ ។

បំណែកឯ ព្រះអរិយបុគ្គលថ្នាក់លើ រមែងធ្វើអរិយមគ្គខាងក្រោមឱ្យជាអារម្មណ៍បាន ពោលគឺ ព្រះសោតាបន្នបុគ្គល ធ្វើសោតាបត្តិមគ្គរបស់ខ្លួន និងដទៃឱ្យ

ជាអារម្មណ៍បាន ដោយបំពោះប៉ុណ្ណោះ, ព្រះសកទាគាមិបុគ្គល ធ្វើសកទាគាមិមគ្គរបស់ខ្លួន និងសោតាបត្តិមគ្គឱ្យជាអារម្មណ៍បាន, ព្រះអនាគាមិបុគ្គល ធ្វើអនាគាមិមគ្គរបស់ខ្លួន និងសោតាបត្តិមគ្គ សកទាគាមិមគ្គឱ្យជាអារម្មណ៍បាន, សម្រាប់ព្រះអរហន្តបុគ្គលនោះ ធ្វើមគ្គទាំង ៤ ឱ្យជាអារម្មណ៍បានទាំងអស់ ព្រោះថា ព្រះអរិយៈថ្នាក់លើធ្លាប់បានអរិយមគ្គខាងក្រោមមកហើយនោះឯង ។ សម្រាប់បុថុជ្ជន មិនអាចជ្រាបចិត្តរបស់ព្រះអរិយបុគ្គលបានឡើយ គឺ មិនអាចជ្រាបលោកុត្តរចិត្តរបស់លោកបានទេ។

## ចែកចិត្តដែលមានមគ្គជាអារម្មណ៍ដោយបុគ្គល

បណ្ឌិតគប្បីជ្រាបថា ចិត្តដែលមានមគ្គជាអារម្មណ៍បាននេះ ជាចិត្តរបស់-ព្រះសេក្ខបុគ្គល និងអសេក្ខបុគ្គលប៉ុណ្ណោះ មាន ១១ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១, មហាកុសលញាណសម្បយុត្តចិត្ត ៤, មហាកិរិយាញាណសម្បយុត្តចិត្ត ៤, អភិញ្ញាចិត្ត ២, ចេតសិក ៣៣ (វៀរវិរតិ អប្បមញ្ញា) ។

អធិប្បាយថា មនោទ្វារាវជ្ជនចិត្ត ដែលប្រព្រឹត្តទៅក្នុងគ្រាពិចារណាមគ្គ ឈ្មោះថា មគ្គារម្មណៈ គឺ មានមគ្គជាអារម្មណ៍ ។

មហាកុសលញាណសម្បយុត្តចិត្ត ៤, មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដែលប្រព្រឹត្តទៅក្នុងគ្រាពិចារណាមគ្គរបស់ខ្លួននិងមគ្គអ្នកដទៃ ឈ្មោះថា មគ្គារម្មណៈ គឺ មានមគ្គជាអារម្មណ៍ ។

អភិញ្ញាចិត្ត ២ គឺ កុសល និងក្រិយា ដែលប្រព្រឹត្តទៅ ដោយអំណាចនៃចេតោ-បរិយញ្ញាណ,បុព្វេនិវាសញ្ញាណ, និងអនាគតង្សញ្ញាណ ក្នុងគ្រាមានមគ្គជាអារម្មណ៍ តែមិនមែនជាមគ្គហេតុកៈទេ ព្រោះមិនបានកើតឡើងព្រមជាមួយគ្នានឹងមគ្គ, និងមិនមែនជាមគ្គាធិបតី ព្រោះមិនយកមគ្គជាអធិបតី សួរថា ព្រោះហេតុអ្វី បានមិនយកមគ្គជាអធិបតី ? ឆ្លើយថា ព្រោះខ្លួនជាមហគ្គតៈ (ព្រោះខ្លួនជាធំ) ។

ពាក្យថា វៀរវិរតិ និងអប្បមញ្ញានោះ គប្បីជ្រាបថា ព្រោះវិរតិ មានអារម្មណ៍ជាវិរមិតព្វវត្ថុ គឺ ជាកាមធម៌តែម្យ៉ាងប៉ុណ្ណោះដោយទៀងទាត់, ឯអប្បមញ្ញានោះ មានសត្វបញ្ញត្តិជាអារម្មណ៍ដោយទៀងទាត់ដូចគ្នា ព្រោះហេតុនេះ ទើបវៀរវិរតិ និងអប្បមញ្ញា ។

## ទុតិយបទ មាន ៣ ន័យ គឺ

វិបនត្ថៈរបស់<u>ទុតិយបទ</u> តាមន័យទី ១ៈ

**អដ្ឋង្គិកោបិ មគ្គោ បច្ចយដ្ឋេន ឯតេសំ ហេតូតិ មគ្គហេតុកា** ឈ្មោះថា មគ្គហេតុកៈ ព្រោះមានអត្ថថា ជាធម៌ដែលមានហេតុ គឺ អង្គមគ្គ ៨ ព្រោះមានអង្គមគ្គជាបច្ច័យ (ដោយសម្បយុត្តប្បច្ច័យជាដើម) ។ អរិយមគ្គទាំង ៤ ប៉ុណ្ណោះ លោកហៅថា មគ្គ ព្រោះមានកិច្ច គឺ ការកំណាត់ដឹងទុក្ខជាដើម ជាកិច្ចដែលសម្រេចបរិបូរណ៍ក្នុងមគ្គនុ៎ះឯង (មូលដីកា) ។

អង្គធម៌តាមប្រែន័យទី ១ នេះ ដែលវៀរអង្គមគ្គ ៨ នោះ ព្រោះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកក្នុងបទនេះ គឺ ធម៌មានហេតុ ហើយហេតុនោះ បានដល់អង្គមគ្គ ៨ ដែលមានឈ្មោះថា **សម្បាបកហេតុ** គឺ ហេតុធ្វើឱ្យដល់ព្រះនិព្វាន (អរិយមគ្គោ និព្វានស្ស សម្បាបការណំ) មិនមែនជាតួហេតុប្បច្ច័យទេ ព្រោះហេតុនោះ អង្គធម៌ បានត្រឹមតែមគ្គចិត្ត ៤ ចេតសិក ២៨ ប៉ុណ្ណោះ វៀរអង្គមគ្គ ៨ ។

បណ្ឌិតគប្បីជ្រាបថា ពាក្យថា ហេតុ លោកបានសម្ដែងទុកក្នុងគម្ពីរនេត្តិ មានច្រើនប្រភេទ ក៏ពិតមែន តែក្នុងឋានៈនេះ នឹងសម្ដែងហេតុ ៣ ប្រការប៉ុណ្ណោះ គឺ សម្បាបកហេតុ, និព្វត្តកហេតុ, និង ញាបកហេតុ ។

អធិប្បាយថា បុគ្គលនឹងទៅកាន់ព្រះនិព្វានបាន មិនមែនអាស្រ័យហេតុ ឬ ផ្លូវដទៃទេ តែអាស្រ័យអង្គមគ្គទាំង ៨ នេះឯង ព្រោះហេតុនោះ អរិយមគ្គ ទើបបានឈ្មោះថា ជាហេតុធ្វើឱ្យដល់ ព្រះនិព្វាន បានដល់ **សម្បាបកហេតុ** ។ ពូជជាហេតុធ្វើឱ្យកើតឡើងនៃពន្លក ឈ្មោះថា **និព្វត្តកហេតុ** ។ សង្ខតធម៌ ដែលកើតឡើងអំពីបច្ច័យជាដើម ឬ ហៅថា ផលនុ៎ះឯង ជាហេតុធ្វើឱ្យដឹង គឺ ឱ្យជ្រាបថាសង្ខតធម៌ទាំងអស់នេះ មានសភាពជាត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ឈ្មោះថា **ញាបកហេតុ** ⑴ ។

វិបន្តរៈរបស់ទុតិយបទ តាមន័យទី ២ ៖

**មគ្គសម្បយុត្តា ហេតូតិ មគ្គហេតូ** ឈ្មោះថា មគ្គហេតុ ព្រោះមានអត្ថថា ហេតុដែលប្រកបជាមួយគ្នានឹងមគ្គ គឺ អលោភៈហេតុ និងអទោសៈហេតុ ។ ឬ **មគ្គេ ហេតូតិ មគ្គហេតូ** ឈ្មោះថា មគ្គហេតុ ព្រោះមានអត្ថថា ជាហេតុដែលតាំងហើយក្នុងមគ្គ គឺ អមោហៈហេតុ ។

អង្គធម៌តាមប្រៃន័យទី ២ នេះ ដែលវៀរអលោភៈ អទោសៈ និងអមោហៈនោះ ព្រោះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដៅយកក្នុងបទនេះ គឺ ធម៌ដែលមានហេតុប្រកបជាមួយគ្នានឹងអរិយមគ្គ បានដល់ អលោភៈ អទោសៈ និងអមោហៈ ព្រោះហេតុនោះ អង្គធម៌ បានត្រឹមតែមគ្គចិត្ត ៤ ចេតសិក ៣៣ ប៉ុណ្ណោះ វៀរអលោភៈជាដើម ។

វិបន្តរៈរបស់ទុតិយបទ តាមន័យទី ៣ ៖

---

⑴ សីលខន្ធវគ្គដីកា ៖ អរិយមគ្គោ និព្វានស្ស សម្បាបកំ ការណំ, ពីជំ អង្កុរស្ស និព្វត្តកំ ការណំ, បច្ចុប្បន្នតាទយោ អនិច្ចតាទីនំ ញាបកំ ការណំ ។

**សម្មាទិដ្ឋិ សយំ មគ្គោ ចេវ ហេតុ ច, ឥតិ មគ្គភូតោ ហេតុ ឯតេសន្តិ មគ្គហេតុកា** ។ ឈ្មោះថា មគ្គហេតុកៈ ព្រោះមានអត្ថថា សម្មាទិដ្ឋិ ខ្លួនឯង ជាមគ្គផង ជាហេតុផង, គឺ ធម៌ដែលមានមគ្គជាហេតុ បានដល់ លោកុត្តរប៉ុណ្ណោះ ។

អង្គធម៌តាមប្រែន័យទី ៣ នេះ ដែលវៀរបញ្ញាចេតសិកនោះ ព្រោះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដៅយកក្នុងបទនេះ បានដល់ អមោហៈហេតុ ដែលតាំងនៅក្នុងឋានៈ ២ ប្រការ គឺ មគ្គ និងហេតុ ព្រោះហេតុនោះ ទើបវៀរបញ្ញាចេតសិក ។

## តតិយបទ មាន ៣ ន័យ គឺ

វិបត្ថៈរបស់<u>តតិយបទ</u>៖

**អភិភវិត្វា បវត្តនដ្ឋេន មគ្គោ អធិបតិ <u>អារម្មណភូតោ</u>, <u>សហជាតោ</u> វា ឯតេសន្តិ មគ្គាធិបតិនោ** ។ ឈ្មោះថា មគ្គាធិបតិ ព្រោះមានអត្ថថា ធម៌ពួកនេះមានមគ្គជាអធិបតី គឺ <u>ជាអារម្មណាធិបតី</u> <u>ឬ</u> <u>ជាសហជាតាធិបតី</u> ព្រោះអត្ថថា ជាអ្នកគ្របសង្កត់ហើយ ឱ្យប្រព្រឹត្តទៅ ក្នុងអំណាចរបស់ខ្លួន ។ បានដល់ ធម៌ជាលោកិយៈ និងលោកុត្តរៈ ។

អង្គធម៌តាមប្រែន័យទី ១ ដែលញែកព្រះអរិយបុគ្គលទាំង ៤ និងមគ្គ ទាំង ៤ ចេញដោយបំពោះៗនោះ ព្រោះព្រះអរិយបុគ្គលដែលធ្វើមគ្គឱ្យជាអារម្មណាធិបតីបាននោះ ត្រូវតែជាមគ្គរបស់ខ្លួនប៉ុណ្ណោះ មិនអាចទៅយកមគ្គរបស់អ្នកដទៃឱ្យជាអារម្មណាធិបតីបានទេ ព្រោះហេតុនោះ ចាំបាច់ត្រូវតែញែកព្រះអរិយបុគ្គលទាំង ៤ ចេញជានីមួយៗ ។ អធិប្បាយថា កាមាវចរជវនៈដែលសម្បយុត្តជាមួយញាណ ៨ ដួង ជាមគ្គារម្មណៈក៏មាន ក្នុងគ្រាពិចារណាមគ្គរបស់ខ្លួន និងអ្នកដទៃ ។ ជាមគ្គាធិបតីក៏មាន ក្នុងគ្រាពិចារណាមគ្គរបស់ខ្លួនប៉ុណ្ណោះ ព្រោះហេតុនោះ ធម៌ដែលមានមគ្គជាអារម្មណាធិបតីនោះ ជាបរិត្តធម៌ប៉ុណ្ណោះ ។ ជានវត្តព្វាក៏មាន (មិនគប្បីពោល) គឺ

អាចមានរូបារម្មណ៍ជាដើមបាន ព្រោះមិនប្រព្រឹត្តទៅយ៉ាងនោះ ។ ពិតណាស់ ព្រះ-អរិយបុគ្គលទាំងឡាយ ពិចារណាមគ្គផលរបស់ព្រះអរិយបុគ្គលដទៃបាន ត្រឹមតែជាអារម្មណ៍ធម្មតាប៉ុណ្ណោះ សូម្បីមគ្គផលនោះ ជារបស់ព្រះសម្មាសម្ពុទ្ធក៏ដោយ ។

សមដូចព្រះអដ្ឋកថាចារ្យសម្ដែងទុកថា ៖

**អរិយសាវកានំ ហិ អត្តនោ មគ្គំ គរុំ កត្វា បច្ចវេក្ខណកាលេ អារម្មណាធិបតិ លព្ភតិ។** ក្នុងគ្រាដែលព្រះអរិយបុគ្គលទាំងឡាយ ពិចារណាមគ្គរបស់ខ្លួនដោយអាការៈបុះស៊ប់ ឬ ដោយអាការៈធ្វើឱ្យធ្ងន់ អារម្មណាធិបតីក៏កើតឡើង ក្នុងខណៈនោះ [១] ។

អង្គធម៌តាមប្រែន័យទី ២ ដែលវៀរវីរិយចេតសិក ឬ បញ្ញាចេតសិកណាមួយនោះ ព្រោះមគ្គ មានអង្គ ៨ អង្គមគ្គដែលជាសហជាតាធិបតិប្បច្ច័យបាន មាន ២ ប៉ុណ្ណោះ គឺ វីរិយចេតសិកដែលមានឈ្មោះថា វីរិយាធិបតី និងបញ្ញាចេតសិកដែលមានឈ្មោះថា វិមំសាធិបតី ។

ធម៌ដែលព្រះពុទ្ធអង្គទ្រង់សំដៅយកក្នុងបទនេះ គឺ ធម៌ដែលមានបច្ច័យជាសហ-ជាតាធិបតី បានដល់ វីរិយាធិបតី ឬ វិមំសាធិបតីជាតួមគ្គ ដូច្នោះហើយ អង្គធម៌បានដល់ មគ្គចិត្ត ៤ ចេតសិក ៣៥ វៀរវីរិយៈ និងបញ្ញាណាមួយ ខណៈជាសហជាតា-ធិបតី ។

អង្គធម៌តាមប្រែន័យទី ៣ បានដល់ វីរិយៈ និងបញ្ញា ខណៈជាអធិបតី ព្រោះធម៌ដែលព្រះពុទ្ធអង្គទ្រង់សំដៅយកក្នុងបទនេះ គឺ មគ្គនោះឯង ជាសហជាតាធិបតិ-ប្បច្ច័យ អង្គមគ្គដែលជាសហជាតាធិបតិប្បច្ច័យនោះមានតែ ២ ប៉ុណ្ណោះ បានដល់ វីរិយៈ និងបញ្ញា ។

---

[១] អដ្ឋសាលិនី ។

## អធិប្បាយតិកាវិមុត្ត

បណ្ឌិតគប្បីជ្រាបថា ចិត្តដែលមិនអាចធ្វើមគ្គឱ្យជាអារម្មណ៍បាននោះ មាន ២ ប្រភេទ គឺ ដោយទៀងទាត់ ១ និងមិនទៀងទាត់ ១ ។

១. **ដោយទៀងទាត់** (ឯកន្តៈ) បានដល់ អកុសលចិត្ត ១២ អហេតុកចិត្ត ១៧ (វៀរមនោទ្វារាវជ្ជនចិត្ត) មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាវិបាកចិត្ត ៨ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ រូបាវចរចិត្ត ១៥ (វៀរអភិញ្ញាចិត្ត ២) អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៨ ចេតសិក ៥២ ។

## ចិត្តដែលមិនអាចធ្វើមគ្គឱ្យជាអារម្មណ៍ដោយទៀងទាត់

អកុសលចិត្ត ១២ មិនអាចយកមគ្គជាអារម្មណ៍បាននោះ ព្រោះអកុសលចិត្តទាំងឡាយ ជាធម្មជាតិដែលសៅហ្មង មិនសមគួរដល់អារម្មណ៍ គឺ លោកុត្តរៈដែលជាធម៌បរិសុទ្ធប្រាសចាកភាពសៅហ្មងដោយប្រការទាំងពួង ។

អហេតុកចិត្ត ១៧ គឺ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ទាំង ២ ផ្នែក ១ ដួងៗ ក៏មានបំពោះរូបជាដើម តែម្យ៉ាងប៉ុណ្ណោះ ជាអារម្មណ៍ ។

ចិត្ត ៣ ដួង គឺ បញ្ចទ្វារាវជ្ជនៈ ១ សម្បដិច្ឆនៈ ២ ឈ្មោះថា **មនោធាតុ** ព្រោះជាធាតុត្រឹមតែដឹងអារម្មណ៍ប៉ុណ្ណោះ មិនមានអាការៈដឹងពិសេសក្នុងអារម្មណ៍នោះៗ ដូចជាពួកមនោវិញ្ញាណធាតុទាំងឡាយឡើយ មនោធាតុទាំង ៣ នេះ ដឹងអារម្មណ៍បាន ៥ យ៉ាង គឺ ៖

បញ្ចទ្វារាវជ្ជនៈ ពេលដែលប្រព្រឹត្តទៅតាមចក្ខុទ្វារ ក្នុងគ្រាដែលមានរូបារម្មណ៍មកដល់គន្លងចក្ខុទ្វារ ជាបុរេចារិក (ប្រព្រឹត្តទៅមុន) នៃចក្ខុវិញ្ញាណ រមែងមានរូបជាអារម្មណ៍ជាដើម ។

សម្បដិច្ឆនៈទាំង ២ ពេលដែលកើតឡើងទទួលអារម្មណ៍ គឺ រូបារម្មណ៍ដែលចក្ខុវិញ្ញាណនោះឃើញហើយ ឈ្មោះថា មានរូបជាអារម្មណ៍ជាដើម បានន័យថា មនោធាតុ ៣ នេះ ដឹងអារម្មណ៍បាន ៥ យ៉ាង វៀរធម្មារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ។

កាមាវចរវិបាកចិត្តទាំងឡាយ គឺ សន្តីរណៈ ៣ ដួង មហាវិបាក ៨ ដួង រួមជា ១១ ដួង ។ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ មានរូបារម្មណ៍ជាដើម ដោយកិច្ច គឺ សន្តីរណៈតាមបញ្ចទ្វារ និងតទាលម្ពនៈ តាមទ្វារទាំង ៦ ។ អារម្មណ៍ទាំង ៦ នុ៎ះឯង ជារបស់វិបាកចិត្តទាំងនេះសុទ្ធតែជាកាមាវចរៈ ព្រោះវិបាកទាំងអស់នេះ កើតឡើងអំពីកម្មដែលសម្រេចដោយកាមតណ្ហាជាបច្ច័យ ។

ហសនចិត្ត (ហសិតុប្បាទចិត្ត) រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ សុទ្ធតែជាកាមាវចរៈ តាមទ្វារទាំង ៦ ដល់ព្រះខីណាស្រព ។

មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ព្រោះជវនចិត្តដែលប្រាសចាកបញ្ញាទាំងឡាយ សូម្បីមិនមែនជាធម្មជាតិសៅហ្មង ព្រោះជាសោភណចិត្ត ទោះបីយ៉ាងនោះ ក៏មានអានុភាពតិច ព្រោះមិនមានបញ្ញាចូលប្រកប ទើបមិនគួរដល់អារម្មណ៍ដែលជាលោកុត្តរៈ ជាធម៌មានអានុភាពប្រើនគួរដល់បញ្ញាប៉ុណ្ណោះ ។

រូបាវចរចិត្ត ១៥ រមែងមានបញ្ញត្តិ មានបឋវីកសិណនិមិត្តជាដើម ជាអារម្មណ៍តាមសមគួរដល់កម្មដ្ឋាននោះៗ ។

អរូបាវចរចិត្ត ១២ មានបញ្ញត្តិ និងមហគ្គតៈជាអារម្មណ៍ ព្រោះអរូបដួងទី ១ មានបញ្ញត្តិ គឺ អាកាសដែលបើកកសិណជាអារម្មណ៍, អរូបដួងទី ៣ ក៏មានបញ្ញត្តិ គឺ ភាវៈមិនមាននៃអរូបដួងទី ១ ជាអារម្មណ៍ ។ អរូបាវចរចិត្តដួងទី ២ និងដួងទី ៤ ឈ្មោះថា មានមហគ្គតធម៌ជាអារម្មណ៍ ព្រោះអរូបាវចរចិត្តដួងទី ២ គឺ វិញ្ញាណញ្ចាយតនៈ មាន

មហគ្គតធម៌ គឺអាកាសានញ្ចាយតនវិញ្ញាណជាអារម្មណ៍, និងអរូបាវចរចិត្តដួងទី ៤ គឺនេវសញ្ញានាសញ្ញាយតនៈ មានមហគ្គតធម៌ គឺ អាកិញ្ចញ្ញាយតនៈជាអារម្មណ៍ ។

លោកុត្តរចិត្ត ៨ មានព្រះនិព្វានជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ។

## ចិត្តដែលធ្វើមគ្គឱ្យជាអារម្មណ៍ដោយមិនទៀងទាត់

២. **ដោយមិនទៀងទាត់** (អនេកន្តៈ) បានដល់ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អភិញ្ញាចិត្ត ២ ចេតសិក ៣៨ ខណៈដែលមិនបានធ្វើមគ្គឱ្យជាអារម្មណ៍ បំណែក រូប ២៨ និងនិព្វាននោះ ប្រាកដច្បាស់ហើយ ។

មនោទ្វារាវជ្ជនចិត្ត មានមគ្គជាអារម្មណ៍ ក្នុងគ្រាពិចារណាមគ្គរបស់ព្រះអរិយបុគ្គលទាំងឡាយព្រោះត្រាប់ទៅមុនបច្ចវេក្ខណញ្ញាណនឹងកើត តែមិនយកមគ្គជាអធិបតី (មគ្គាធិបតី) ព្រោះមិនកើតឡើងធ្វើមគ្គឱ្យជាអធិបតី ។

សួរថា ព្រោះហេតុអ្វី បានមិនយកមគ្គជាអធិបតី ? ឆ្លើយថា ព្រោះខ្លួនជាអហេតុកៈ ថោកទាប ជាធម្មជាតិខ្លៅ ដូចជា ប្រជាជនទាំងអស់ធ្វើនូវការគោរពកោតក្រែងចំពោះព្រះរាជា ឯជនជាបរិវារដែលពិការរាងកាយ មានខ្វិនកោង និងខ្វាក់ជាដើម មិនធ្វើនូវសេចក្តីគោរពកោតក្រែង ដូចជាបណ្ឌិតទេ ព្រោះខ្លួនជាមនុស្សខ្លៅយ៉ាងណាមិញ ។ ចិត្តនេះក៏យ៉ាងនោះដែរ ជាធម្មជាតិខ្លៅ គឺ មិនដឹងគុណតម្លៃក្នុងអារម្មណ៍ ។

មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ប្រព្រឹត្តទៅក្នុងសន្តានរបស់ព្រះសេក្ខបុគ្គលប៉ុណ្ណោះ ប្រារព្ធមគ្គរបស់ខ្លួន និងអ្នកដទៃ ក្នុងគ្រាដែលប្រព្រឹត្តទៅដោយអំណាចនៃបច្ចវេក្ខណញ្ញាណ ឈ្មោះថា មានមគ្គជាអារម្មណ៍ ។ ប្រារព្ធមគ្គរបស់ខ្លួន ក្នុង

គ្រាដែលប្រព្រឹត្តទៅដោយអំណាចនៃបច្ចវេក្ខណញ្ញាណ ឈ្មោះថា មានមគ្គជាអធិបតី ។ ប្រារព្ធអារម្មណ៍ដទៃក្រៅអំពីនេះ ជានវត្តព្វារម្មណ៍ (មិនគប្បីពោល គឺ អាចមានរូបា-រម្មណ៍ជាដើមបាន) ឈ្មោះថា មាននវត្តព្វជាអារម្មណ៍ ។

មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ត្រឹមតែប្រព្រឹត្តទៅក្នុងសន្តានរបស់ព្រះអសេក្ខបុគ្គលប៉ុណ្ណោះ សេចក្ដីផ្សេងពីនេះដូចគ្នា ។

អភិញ្ញាចិត្ត ២ គឺ កុសល និងក្រិយា ដែលប្រព្រឹត្តទៅ ដោយអំណាចនៃ **ចេតោបរិយញ្ញាណ** ក្នុងគ្រាមានមគ្គរបស់អ្នកដទៃជាអារម្មណ៍ ឬក្នុងគ្រាមានកាមា-វចរៈរបស់អ្នកដទៃ ឈ្មោះថា មានបរិត្តធម៌ជាអារម្មណ៍, ឬ ក្នុងគ្រាមានរូបាវចរៈ និងអរូបាវចរៈរបស់អ្នកដទៃ ឈ្មោះថា មានមហគ្គតធម៌ ជាអារម្មណ៍ ។ **បុព្វេនិវាសា-នុស្សតិញ្ញាណ** មានអារម្មណ៍ជាបរិត្តៈ, មហគ្គតៈ, និងអប្បមាណៈ ។

បណ្ឌិតគប្បីជ្រាបថា ក្នុងគ្រាដែលរឭកកាមាវចរខន្ធ ឈ្មោះថា មានបរិត្តធម៌ជាអារម្មណ៍,ក្នុងគ្រាដែលរឭករូបាវចរៈ និងអរូបាវចរខន្ធ ឈ្មោះថា មានមហគ្គតធម៌ជាអារម្មណ៍, ក្នុងគ្រាដែលរឭកដល់មគ្គរបស់ខ្លួន និងអ្នកដទៃ បានបម្រើនហើយក្នុងអតីត ឈ្មោះថា មានអប្បមាណៈ ជាអារម្មណ៍ជាដើម ។ **អនាគតង្សញ្ញាណ** មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងអប្បមាណៈដូចគ្នា គឺ ក្នុងកាលអនាគត បុគ្គលនេះនឹងកើតក្នុងកាមាវចរភូមិ ឈ្មោះថា មានបរិត្តធម៌ជាអារម្មណ៍, ក្នុងកាលអនាគតនឹងកើតក្នុងរូបាវចរៈ និងអរូបាវចរភូមិ ឈ្មោះថា មានមហគ្គតធម៌ជាអារម្មណ៍, ក្នុងកាលអនាគត បុគ្គលនេះ នឹងបម្រើនមគ្គ ធ្វើផលឱ្យជាក់ច្បាស់ ហើយនឹងបរិនិព្វានដោយនិព្វានធាតុ ឈ្មោះថា មានអប្បមាណៈ ជាអារម្មណ៍ជាដើម ។ តែបណ្ឌិតគប្បីជ្រាបថា ញាណទាំង ៣ នេះ មិនបានយកមគ្គជាអធិបតីអារម្មណ៍ទេ ។

ប្រសិនបើមានសំណួរសួរថា ព្រោះហេតុអ្វី ញាណទាំង ៣ នេះ បានមិនយក មគ្គជាអធិបតី ? ឆ្លើយថា ព្រោះខ្លួនជាមហគ្គតៈ (ព្រោះខ្លួនជាធំ) ។ ដូចជា ប្រជាជនទាំងអស់ធ្វើនូវការគោរពកោតក្រែងចំពោះព្រះរាជា បំណែកឯ ព្រះមាតា និងព្រះបិតាមិនចាំបាច់គោរពព្រះរាជា មានការក្រោកទទួល ឬ ធ្វើអញ្ជលីកម្មជាដើម ត្រាស់ហៅព្រះរាជា ដូចសម័យព្រះអង្គទ្រង់ជារាជកុមារនោះឯង យ៉ាងណាមិញ ។ សូម្បីញាណទាំង ៣ នេះ ក៏យ៉ាងនោះដែរ មិនយកមគ្គជាអធិបតី ព្រោះខ្លួនជាមហគ្គតៈ ។

## ចប់ មគ្គារម្មណត្តិកៈ

## ១៧. ឧប្បន្នត្តិកៈ

បឋមបទ. **ឧប្បន្នា ធម្មា** ពួកធម៌កើតឡើងហើយ ឬ ពួកធម៌កំពុងដល់នូវខណៈទាំង ៣ គឺ ធម៌ដែលប្រព្រឹត្តទៅចាប់តាំងតែអំពីឧប្បាទក្ខណៈរហូតដល់ភង្គ-ខណៈ ។ ឈ្មោះថា **ឧប្បន្នា ធម្មា**នេះ ជាសព្ទសម្ដែងសភាវៈធម៌ជាប់ទាក់ទងនឹងកាល ២ ប្រការ គឺ អតីត និងបច្ចុប្បន្ន សមដូចគម្ពីរ **អនុដីកា**បានសម្ដែងទុកថា ភាវៈនៃធម៌ដែលដល់ខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើម ឈ្មោះថា **ឧប្បន្នា ធម្មា** ព្រោះហេតុនោះ សូម្បីធម៌ជាអតីត លោកក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា [១] ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ដែលកើតឡើងហើយ ឬ កំពុងដល់នូវខណៈទាំង ៣ ។

ទុតិយបទ. **អនុប្បន្នា ធម្មា** ពួកធម៌មិនទាន់កើតឡើង ឬ ធម៌មិនទាន់ដល់នូវខណៈទាំង ៣ បានដល់ អនាគតនុ៎ះឯង ។ បានដល់ អកុសលចិត្ត ១២ កុសលចិត្ត ២១ កិរិយាចិត្ត ២០ ចេតសិក ៥២ ចិត្តជរូប ១៧ ឧតុជរូប ១៥ អាហារជរូប ១៤ ដែលនឹងកើតឡើង ។

តតិយបទ. **ឧប្បាទិនោ ធម្មា** ពួកធម៌ដែលប្រុងនឹងកើតឡើង ព្រោះមានហេតុមួយចំណែកដែលសម្រេចហើយ (បរិនិដ្ឋិតការណេកទេសត្តា) អធិប្បាយថា វិបាក និងកម្មជរូប ដែលជាអនាគតនឹងកើតឡើងបាន ក៏ព្រោះកម្ម ជាអតីត ឬ អនាគត បានសម្រេចរួចហើយនុ៎ះឯង គឺ ការកើតឡើងនៃហេតុជាសភាពប្រាកដមុន

---

[១] ធម្មសង្គណីអនុដីកាពោលថា ៖ ឧប្បន្នភាវោ ឧប្បាទាទិប្បត្តា តេន អតីតាបិ សង្គហិតា ហោន្តិ ។

ដោយជាហេតុធ្វើផលឱ្យកើតឡើង ⁽១⁾ ។ បានដល់ វិបាកចិត្ត ៣៦ ចេតសិក ៣៨ កម្មជរូប ២០ ដែលនឹងកើតឡើង ។ បទទាំង ២ នេះ លោកសម្ដែងថា ជាអនាគតន៉ុះឯង ។ ពិតណាស់ តិកៈនេះ លោកសម្ដែងអទ្ធា ២ ប្រការ គឺ បច្ចុប្បន្ន និងអនាគត ⁽២⁾ ។ តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## អធិប្បាយតិកវិមុត្ត

ព្រះនិព្វានដែលជាតិកវិមុត្តនោះ ព្រោះព្រះនិព្វានជាកាលវិមុត្ត គឺ ផុតចាកកាលទាំង ៣ សភាពព្រះនិព្វាននេះ កំពុងកើត នឹងកើត ឬ កើតហើយក៏មិនមែន ព្រោះសភាពរបស់ព្រះនិព្វាន គឺ ការអស់ទៅនៃចិត្ត ចេតសិក និងរូបរបស់ព្រះអរហន្តបុគ្គលដែលជាការរលត់គ្រាចុងក្រោយមិនមានការបដិសន្ធិតទៅទៀត នេះឯងឈ្មោះ-ថា ព្រះនិព្វាន ដូចជាព្រះពុទ្ធអង្គទ្រង់សម្ដែងទុកថា **និព្វានំ ន វត្តព្វំ ឧប្បន្នន្តិបិ អនុប្បន្នន្តិបិ ឧប្បាទីតិបិ** ព្រះនិព្វាននោះ មិនអាចពោលបានថា កំពុងកើត នឹងកើត ឬ កើតហើយ ⁽៣⁾ ។

## ចប់ ឧប្បន្នត្តិកៈ

---

⁽១⁾ មូលដីកាពោលថា៖ អនាគតានិ វិបាកកដត្តារូបានិ អតីតេ អនាគតេ វា កម្មេ បុរិម-និប្ផន្នេ ឯវ ឧប្បជ្ជិស្សន្តិ ។

<u>អដ្ឋសាលិនីយោជនាពោលថា</u>៖ បរិនិដ្ឋិតការណេកទេសត្តាតិ ការណស្ស ឯកទេសោ ការណេកទេសោ, បរិនិដ្ឋិតោ ការណេកទេសោ ឯតេសន្តិ បរិនិដ្ឋិតការណេកទេសោ, តេសំ ភាវោ បរិនិដ្ឋិតការណេកទេសត្តំ ។

⁽២⁾ មោហវិច្ឆេទនីពោលថា៖ ឧភយេនាបិ អនាគតាវ ទស្សិតា, អយំ ហិ តិកោ ទ្វិន្នំ អទ្ធានំ វសេន បវត្តោ ទស្សិតោ ។

⁽៣⁾ ព្រះត្រៃបិដកខ្មែរលេខ ៧៩, ទំព័រ ២៥៥ ។

## ១៨. អតីតត្តិកៈ

បឋមបទ. **អតីតា ធម្មា** ពួកធម៌ជាអតីត (កន្លងទៅហើយ) ឈ្មោះថា អតីត គឺ ធម៌ដែលកន្លងសភាវៈរបស់ខ្លួន ឬ កន្លងខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើម ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

ទុតិយបទ. **អនាគតា ធម្មា** ពួកធម៌ជាអនាគត (មិនទាន់មកដល់) ឈ្មោះថា អនាគត គឺ ធម៌មិនទាន់មកដល់ ដោយអាការៈ ទាំង ២ ប្រការនោះ គឺ សភាវៈរបស់ខ្លួន ឬ ខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើម ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

តតិយបទ. **បច្ចុប្បន្នា ធម្មា** ពួកធម៌ជាបច្ចុប្បន្ន (កើតឡើងចំពោះមុខ) ឈ្មោះថា បច្ចុប្បន្ន គឺ ធម៌ដែលអាស្រ័យហេតុនោះៗហើយក៏កើតឡើង ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

បណ្ឌិតគប្បីជ្រាបថា នាមធម៌ និងរូបធម៌ (ចិត្ត, ចេតសិក, រូប) ទាំងអស់នេះ ឈ្មោះថា ជាសង្ខតៈ ។

បណ្ដាសង្ខតធម៌ ដែលមិនជាប់ទាក់ទងនឹងកាលទាំង ៣ នោះ មិនមានឡើយ សុទ្ធតែប្រព្រឹត្តទៅក្នុងកាលទាំងអស់ ។ បំណែកឯព្រះនិព្វាន មិនគប្បីពោលយ៉ាងនោះ គឺ មិនជាប់ទាក់ទងនឹងកាលឡើយ [១] ។

ព្រះនិព្វាន ជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## ចប់ អតីតត្តិកៈ

---

[១] មោហវិច្ឆេទនី ។

## ១៩. អតីតារម្មណត្តិកៈ

បឋមបទ. **អតីតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាអតីតតែម្យ៉ាង ឬ ពួកធម៌ដែលធ្វើអតីតឱ្យជាអារម្មណ៍ ។ បានដល់ វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣, នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣, ចេតសិក ៣០ ដែលធ្វើអតីតធម៌ឱ្យជាអារម្មណ៍ដោយទៀងទាត់ (ឯកន្តៈ) មនោទ្វារាវជ្ជនចិត្ត ១, កាមជវនចិត្ត ២៩, តទាលម្ពនចិត្ត ១១, អភិញ្ញាចិត្ត ២, ចេតសិក ៤៧ (វៀរវិរតិ អប្បមញ្ញា) ខណៈធ្វើអតីតធម៌ឱ្យជាអារម្មណ៍ (អនេកន្តៈ) ។

ទុតិយបទ. **អនាគតារម្មណា ធម្មា** ពួកធម៌មានអនាគតជាអារម្មណ៍ (អនេកន្តៈតែម្យ៉ាង) ។ បានដល់ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត ១១ អភិញ្ញាចិត្ត ២ ចេតសិក ៥០ (វៀរអប្បមញ្ញា) ខណៈដែលធ្វើអនាគតធម៌ឱ្យជាអារម្មណ៍ ។

តតិយបទ. **បច្ចុប្បន្នារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ឬ ពួកធម៌ដែលធ្វើបច្ចុប្បន្នធម៌ឱ្យជាអារម្មណ៍ ។ បានដល់ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ អញ្ញសមានចេតសិក ១០ (វៀរវីរិយៈ បីតិ ឆន្ទៈ) ដែលធ្វើបច្ចុប្បន្នធម៌ឱ្យជាអារម្មណ៍ដោយទៀងទាត់ (ឯកន្តៈ) មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពនចិត្ត ១១ អភិញ្ញាចិត្ត ២ ចេតសិក ៥០ (វៀរអប្បមញ្ញា) ខណៈដែលធ្វើបច្ចុប្បន្នធម៌ឱ្យជាអារម្មណ៍ ។

បញ្ញត្តារម្មណចិត្ត **ឯកន្តៈ** ២១ ចេតសិក ៣៥, បញ្ញត្តារម្មណចិត្ត **អនេកន្តៈ** ៣១ ចេតសិក ៤៩, (វៀរវិរតី) និងអប្បមាណារម្មណចិត្ត **ឯកន្តៈ** ៨ ចេតសិក ៣៦,

អប្បមាណារម្មណចិត្ត **អនេកន្តៈ** ១១ ចេតសិក ៣៣ (វៀរវិរតិ និងអប្បមញ្ញា), រូប ២៨, និព្វាន ជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## ចប់ អតីតារម្មណត្តិកៈ

## ២០. អជ្ឈត្តត្តិកៈ

បឋមបទ. **អជ្ឈត្តា ធម្មា** ពួកធម៌ជាខាងក្នុង (សន្តានខ្លួន) ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

ទុតិយបទ. **ពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្រៅ (សន្តានខ្លួន) ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ និព្វាន បញ្ញត្តិ ។

តតិយបទ. **អជ្ឈត្តពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្នុង និងខាងក្រៅ ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## អធិប្បាយអជ្ឈត្តត្តិកៈ

គ្រាដំបូង បណ្ឌិតគប្បីជ្រាបថា អជ្ឈត្តៈសព្ទនេះ មាន ៤ ប្រការ គឺ៖

១. គោចរជ្ឈត្តៈ គឺ អារម្មណ៍

២. និយកជ្ឈត្តៈ គឺ ធម៌ដែលកើតឡើងក្នុងខ្លួន

៣. អជ្ឈត្តជ្ឈត្តៈ គឺ អាយតនៈខាងក្នុងទាំង ៦

៤. វិសយជ្ឈត្តៈ គឺ ផលសមាបត្តិ ។

បណ្តាអជ្ឈត្តៈទាំង ៤ នោះ ក្នុងអជ្ឈត្តត្តិកៈនេះ លោកសំដៅយក **និយកជ្ឈត្តៈ** ប៉ុណ្ណោះ អជ្ឈត្តៈ ៣ ដ៏សេសអ្នកសិក្សា គប្បីស្វែងរកក្នុងឋានៈនោះៗ ។

បណ្តាធម៌ទាំង ៣ នេះ គឺ ចិត្ត ចេតសិកទាំងអស់ និងឥន្ទ្រិយពទ្ធរូប គឺ រូបជាប់ទាក់ទងដោយឥន្ទ្រិយ (គឺ រាងកាយរបស់សត្វដែលកើតអំពីកម្ម) បានទាំង ៣ បទ មានសេចក្តីថា ធម៌ដែលតាំងនៅក្នុងសរីរៈ ទោះបីកើតអំពីកម្ម ឬ មិនកើតអំពីកម្មក៏ដោយ លោកក៏ហៅថា រូបដែលជាប់ទាក់ទងដោយឥន្ទ្រិយ ព្រោះមានការប្រកាន់ថា

ជារបស់អាត្មាអញជាដើម។ អធិប្បាយថា បើកើតខាងក្នុងរបស់ខ្លួន ក៏ហៅថា អជ្ឈត្ត-ធម៌, បើកើតខាងក្នុងរបស់អ្នកដទៃ ក៏ហៅថា ពហិទ្ធធម៌ ។

សម្រាប់អនិន្ទ្រិយពទ្ធរូប (គឺ ឧតុជរូបដែលមានខាងក្រៅ) រូបដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ និព្វាន និងបញ្ញត្តិ ជាពហិទ្ធធម៌តែម្យ៉ាងប៉ុណ្ណោះ (ឯកន្តៈ) ឈ្មោះថា ពហិទ្ធា ជាធម៌ខាងក្រៅ ព្រោះមិនមានហេតុដើម្បីឱ្យសម្រេចជាធម៌ខាងក្នុង ដូចជារូបដែលជាប់ទាក់ទងដោយឥន្ទ្រិយ ។

បណ្ឌិតគប្បីជ្រាបថា ពួកធម៌ជាខាងក្រៅ ដែលមាននៅក្នុងសន្តានរបស់អ្នកដទៃ ក៏ឈ្មោះថា ជាធម៌ខាងក្នុង ព្រោះជាប់ទាក់ទងដោយអំណាចខ្សែនៃនាមរូបរបស់ខ្លួន [១] ។

សូម្បីបញ្ញត្តិ មិនបានសម្តែងទុកក្នុងកុសលត្តិកៈ ក៏ពិតមែន តែបានសម្តែងទុកក្នុងតិកៈនេះ ព្រោះជាអារម្មណ៍ខាងក្រៅ ។

## ចប់ អជ្ឈត្តត្តិកៈ

---

[១] កន្លែងនេះ ប្រែទាំងអដ្ឋកថាអដ្ឋសាលិនី និងមោហវិច្ឆេទនី ផ្សំចូលគ្នា ។

## ២១. អជ្ឈត្តារម្មណត្តិកៈ

បឋមបទ. **អជ្ឈត្តារម្មណា ធម្មា.** ពួកធម៌មានអារម្មណ៍ខាងក្នុង (តែម្យ៉ាង) ឬ ធ្វើធម៌ខាងក្នុងឱ្យជាអារម្មណ៍ ។ បានដល់ វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ នេវសញ្ញា-នាសញ្ញាយតនជ្ឈានចិត្ត ៣ ចេតសិក ៣០ ខណៈធ្វើធម៌ខាងក្នុងឱ្យជាអារម្មណ៍ដោយទៀងទាត់,កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ ចេតសិក ៤៩ (វៀរឥស្សា និងអប្បមញ្ញា) ខណៈធ្វើធម៌ខាងក្នុងឱ្យជាអារម្មណ៍ (អនេកន្តៈ) ។

ទុតិយបទ. **ពហិទ្ធារម្មណា ធម្មា.** ពួកធម៌មានអារម្មណ៍ខាងក្រៅ (តែម្យ៉ាង) ឬ ធ្វើធម៌ខាងក្រៅឱ្យជាអារម្មណ៍ ។ បានដល់ រូបាវចរចិត្ត ១៥ (វៀរអភិញ្ញាចិត្ត ២) អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ លោកុត្តរចិត្ត ៨ ចេតសិក ៣៨ ខណៈធ្វើខាងក្រៅឱ្យជាអារម្មណ៍ដោយទៀងទាត់, កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ ចេតសិក ៥២ ខណៈធ្វើធម៌ខាងក្រៅឱ្យជាអារម្មណ៍ដោយមិនទៀងទាត់ ។

តតិយបទ. **អជ្ឈត្តពហិទ្ធារម្មណា ធម្មា.** ពួកធម៌មានអារម្មណ៍ខាងក្នុង និងខាងក្រៅ ឬធ្វើធម៌ខាងក្នុង និងខាងក្រៅឱ្យជាអារម្មណ៍ ។ បានដល់ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ ចេតសិក ៤៩ (វៀរឥស្សា និងអប្បមញ្ញា) ។

នត្ថិភាវបញ្ញត្តារម្មណចិត្តដោយទៀងទាត់ មាន ៣ គឺ អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ចេតសិក ៣០, និងនត្ថិភាវបញ្ញត្តារម្មណចិត្តដោយមិនទៀងទាត់ មាន ៣១ គឺ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អភិញ្ញាចិត្ត ២ ចេតសិក ៤៥ (វៀរវិរតិ អប្បមញ្ញា ឥស្សា និង មច្ឆរិយៈ) រូប ២៨ និព្វាន ជាតិកវិមុត្ត ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **សប្បទេសត្តិកៈ** ។

## អធិប្បាយតិកវិមុត្ត

នត្ថិភាវបញ្ញត្តិ មានសេចក្តីថា សភាពដែលសន្មតក្នុងការប្រព្រឹត្តិទៅដោយភាពមិនមានអ្វី ឈ្មោះថា **នត្ថិភាវបញ្ញត្តិ** ជាអជ្ឈត្តធម៌ ឬ ជាពហិទ្ធធម៌ក៏មិនមែន ដោយហេតុនេះ ចិត្តចេតសិកដែលមានអារម្មណ៍ជានត្ថិភាវបញ្ញត្តិ ដោយទៀងទាត់ និងមិនទៀងទាត់ ទាំង ២ យ៉ាងនេះ ជាអង្គធម៌របស់បឋមបទ ទុតិយបទ និងតតិយបទមិនបាន ទើបជាតិកវិមុត្ត។

សម្រាប់អភិញ្ញាចិត្ត ២ ដែលជាតិកវិមុត្តនោះ សំដៅយកអភិញ្ញាចិត្តដែលកើតឡើងដោយធ្វើ**បុព្វេនិវាសានុស្សតិញ្ញាណ** និង **អនាគតង្សញ្ញាណ** ខណៈដែលធ្វើនត្ថិភាវបញ្ញត្តិឱ្យជាអារម្មណ៍ប៉ុណ្ណោះ គឺ បុព្វេនិវាសានុស្សតិញ្ញាណ មានការរឭកដល់បុគ្គលដែលបានបរិនិព្វានកន្លងទៅហើយ គឺជាអតីត ។ អនាគតង្សញ្ញាណ មានការរឭកដល់បុគ្គលដែលនឹងបរិនិព្វានក្នុងកាលខាងមុខ ។

## ចប់ អជ្ឈត្តារម្មណត្តិកៈ

# ២២. សនិទស្សនត្តិកៈ

បឋមបទ. **សនិទស្សនសប្បដិឃា ធម្មា** ពួកធម៌ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ ។ បានដល់ រូបារម្មណ៍ ។

ទុតិយបទ. **អនិទស្សនសប្បដិឃា ធម្មា** ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ។ បានដល់ ឱឡារិករូប ១១ (វៀររូបារម្មណ៍) ។

តតិយបទ. **អនិទស្សនាប្បដិឃា ធម្មា** ពួកធម៌មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ។ បានដល់ ចិត្ត ៨៩ ចេតសិក ៥២ សុខុមរូប ១៦ និព្វាន ។

តិកៈនេះឈ្មោះថា **អាទិលទ្ធនាមត្តិកៈ** និង **និប្បទេសត្តិកៈ** ។

## ចប់ សនិទស្សនត្តិកៈ

# ចែកតិកៈ ២២ ដោយអាទិលទ្ធនាមត្តិកៈ និងសព្វលទ្ធនាមត្តិកៈ

ក្នុងតិកៈ ២២ នេះ **វេទនាត្តិកៈ** ប៉ុណ្ណោះ ជា**សព្វលទ្ធនាមត្តិកៈ** តិកៈ ២១ ដ៏សេស ជា**អាទិលទ្ធនាមត្តិកៈ** ។

# ចែកតិកៈ ២២ ដោយសប្បទេសត្តិកៈ និងនិប្បទេសត្តិកៈ

តិកៈ ២២ នោះ **សប្បទេសត្តិកៈ** មាន ៩ តិកៈ គឺ **វេទនាត្តិកៈ, សវិតក្កត្តិកៈ, បីតិត្តិកៈ, ឧប្បន្នត្តិកៈ, អតីតត្តិកៈ, បរិត្តារម្មណត្តិកៈ, មគ្គារម្មណត្តិកៈ, អតីតារម្មណត្តិកៈ អជ្ឈត្តារម្មណត្តិកៈ** ។

បំណែកតិកៈដ៏សេស ១៣ ទៀត ជា**និប្បទេសត្តិកៈ** ។

តិកមាតិកាវណ្ណនា និដ្ឋិតា

ចប់ ការអធិប្បាយតិកមាតិកា

វិនយោ កិច្ចគម្ភីរោ   អភិធម្មោ សភាវតោ

សុត្តន្តោ អត្ថគម្ភីរោ   តិមេ តយោ សុគម្ភិរា ។

ជម្រៅទាំងឡាយ ៣ យ៉ាងនេះគឺ

ព្រះវិនយបិដកមានជម្រៅដោយកិច្ច,

ព្រះសុត្តន្តបិដកមានជម្រៅដោយអត្ថាធិប្បាយ,

ព្រះអភិធម្មបិដកមានជម្រៅដោយសភាវៈ, ជាជម្រៅយ៉ាងសំខាន់ ។

(គម្ពីរជិនសារត្ថសង្គហៈ)

© រក្សាសិទ្ធិ